**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal De Droit Et Des Sciences Economiques

ROYAL UNIVERSITY OF LAW AND ECONOMICS


# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ស៊ុំ ណាវីន**

**សែម ច័ន្ទមករា**

សាស្ត្រាចារ្យណែនាំ

**សាស្ត្រាចារ្យ ឃឹម ម៉ាណែត**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតឆ្នាំទី៤ជំនាន់ទី**២២** ថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ ៖

លោកឪពុកអ្នកម្តាយ ដែលជាអ្នកមានគុណ និងជាអ្នកដែលបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សាអប់រំប្រៀនប្រដៅ រហូតដល់បានចំរើនជ័យ និងមានចំណេះដឹងដល់សព្វថ្ងៃនេះ។

ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្រ្តាចារ្យ ប្រធានដេប៉ាតឺម៉ង់ ប្រធានការិយាល័យ មន្ត្រីរាជការ និង បុគ្គលិកដែលបម្រើការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ទាំងអស់ ហើយជាពិសេសទៅទៀតនោះគឺ លោកស្រី សាស្រ្តាចារ្យ **ឃឹម ម៉ាណែត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្រៀន បង្ហាត់បង្ហាញ និងណែនាំលើកិច្ចការសារណានេះដល់យើងខ្ញុំ ចាប់តាំងពីពេលអនុវត្តដំបូងរហូតដល់កិច្ចការមួយនេះត្រូវបានបញ្ចប់ជាស្ថាពរ ។

និស្សិតច្បងទាំងអស់ដែលបានខិតខំចងក្រងទុកជាឯកសារ ដ៏មានតម្លៃដល់ពួកយើងខ្ញុំជំនាន់ក្រោយដើម្បីបានជាទុនក្នុងការសិក្សាស្រាវជ្រាវបន្ថែម និង បណ្ណាគ្រឹះស្ថានមួយចំនួនទៀតដែលបានចងក្រងនិងរៀបចំជាឯកសារពាក់ព័ន្ធ ហើយផ្តល់មកឲ្យយើងខ្ញុំ។

មិត្តរួមថ្នាក់ និងញាតិមិត្តទាំងអស់ដែលបានស្រឡាញ់រាប់អាន និងជួយជាកំលាំងចិត្តដល់យើងខ្ញុំទាំងអស់គ្នាដ៏ដូចជាមិត្តៗទាំងអស់គ្នា ដែលមានវត្តមានក្នុងក្លឹបសិក្សា ដែលទាំងអស់នេះជាកត្តាមួយដែលបានជួយជំរុញឲ្យការសិក្សាស្រាវជ្រាវ យើងខ្ញុំកាន់តែមានសន្ទុះឡើង ។

ជាចុងក្រោយយើងខ្ញុំសូមទុកស្នាដៃនេះជូនដល់មិត្តនិស្សិតជំនាន់ក្រោយ ដើម្បីទុកជាឯកសារ និងជូនពរអ្នកទាំងអស់គ្នាឲ្យជួបប្រទះតែនឹងសេចក្តីសុខចំរើន និងសុភមង្គលក្នុងក្រុមគ្រួសារព្រមទាំងការរីកចម្រើនជាអមតៈហើយសូមឲ្យជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អារម្ភកថា

យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងទៅនឹងការអនុវត្តដោយបង្ខំត្រូវបាន បែងចែកជា៣ប្រភេទធំៗគឺការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់ ការអនុវត្តដោយបង្ខំដែល គ្មានគោលបំណងសងជាប្រាក់ និង ការអនុត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ។ ដោយឡែកការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលគឺ ស្ថិតនៅក្នុងប្រភេទនៃការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់។

ចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ជានីតិវិធីមួយដែលម្ចាស់បំណុលនៃការអនុវត្ត បាន ដាក់ពាក្យសុំរឹបអូសយកសិទ្ធិលើបំណុលរបស់កូនបំណុលនៃការអនុវត្តដើម្បីទូទាត់ប្រាក់ដែលបានជំពាក់ខ្លួន។ សិទ្ធិលើបំណុលដែលម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំបានមានដូចជា លុយដែលបានផ្ញើរទុកក្នុង ធនាគារ ប្រាក់ខែសិទ្ធិលើបំណុលដែលកូនបំណុលមានលើកូនបំណុលទី៣។ យោងទៅតាមក្រមនីតិវិធីរដ្ឋ ប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានពីរប្រភេទគឺ ការអនុវត្ត ដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងប្រាក់ និង សិទ្ធិលើបំណុលដែលមានកម្មវត្ថុជា ការប្រគល់ចលនវត្ថុ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលជាសមត្ថកិច្ចរបស់តុលាការក្នុងការអនុវត្ត ហើយការអនុវត្ត នេះ ត្រូវបានចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ចំណែកនីតិវិធីនៃការអនុវត្ត ដោយបង្ខំចំពោះសិទ្ធិលើបំណុលត្រូវចាប់ផ្តើមពីការដាក់ពាក្យសុំ ការពិនិត្យពាក្យសុំ ការរឹបអូសសិទ្ធិលើបំណុល ការផ្ទេរជាប្រាក់នៃសិទ្ធិលើបំណុល និងការប្រមូលបំណុល ហើយនីតិវិធីនេះមានពន្យល់ លំអិតនៅក្នុងសារណា មួយនេះស្រាប់។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១

**១.លំនាំបញ្ហា** ............ ១

**២.ចំណោទបញ្ហា** ............ ២

**៣.គោលបំណងនៃការស្រាវជ្រាវ** ............ ២

**៤.ដែនកំណត់ និងទំហំនៃការស្រាវជ្រាវ** ............ ២

**៥.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ............ ៣

**ជំពូកទី១ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ** ............ ៤

**១.១.ស្ថាប័នអនុវត្តដោយបង្ខំ** ............ ៥

**១.១.១.តុលាការអនុវត្ត** ............ ៥

**១.១.២.អាជ្ញាសាលា** ............ ៦

១.១.២.១.ប្រវត្តិ និងការវិវត្តនៃអាជ្ញាសាលា ............ ៦

១.១.២.២.លក្ខខណ្ឌដើម្បីក្លាយជាអាជ្ញាសាលា ............ ៧

១.១.២.៣.ឋានៈសិទ្ធិ និងកាតព្វកិច្ចរបស់អាជ្ញាសាលា ............ ៨

១.១.២.៤.សិទ្ធិ និង កាតព្វកិច្ចរបស់អាជ្ញាសាលា ............ ៩

**១.២.ប្រភេទនៃការអនុវត្តដោយបង្ខំ** ............ ១០

**១.២.១.ការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់** ............ ១១

**១.២.២.ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងសងជាប្រាក់** ............ ១៣

**១.២.៣.ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ** ............ ១៤

**១.៣.ការផ្អាក និងការលុបចោលការអនុវត្ត** ............ ១៥

**១.៣.១.បណ្តឹងធ្វើឱ្យមានការជំនុំជម្រះសាជាថ្មី** ............ ១៥

**១.៣.២.បណ្តឹងសាទុក្ខចំពោះសាលក្រម ឬសាលដីកា** ............ ១៧

**១.៣.៣.បណ្តឹងឧទ្ធរណ៍ដែលភ្ជាប់ការផ្អាក និងលុបចោលការអនុវត្ត** ............ ១៧

**១.៣.៤.ការប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ** ............ ២០

**ជំពូកទី២ លក្ខខណ្ឌទូទៅសម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល** ..២១

**២.១.ការដាក់ពាក្យសុំ** ........................................................................................................២១

**២.១.១ លិខិតអនុវត្ត** ........................................................................................................២២

**២.១.២.រូបមន្តអនុវត្ត** ........................................................................................................២៥

២.១.២.១.ពាក្យសុំរូបមន្តអនុវត្ត........................................................................................២៦

២.១.២.២.ការសរសេររូមមន្តអនុវត្ត ....................................................................................២៦

**២.១.៣.ពន្ធ និងសោហ៊ុយសម្រាប់ការអនុវត្ត** ..................................................................២៧

២.១.៣.១.ពន្ធដាក់ពាក្យសុំ ..........................................................................................២៧

២.១.៣.២.សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ ........................................................................២៨

២.១.៣.៣.សោហ៊ុយភាគី ..............................................................................................២៩

**ជំពូកទី៣ ការអនុវត្តដោយបង្ខំសិទ្ធិលើបំណុលមានកម្មវត្ថុជាការសងប្រាក់**.... ៣០

**៣.១.ការដាក់ពាក្យសុំ**........................................................................................................៣១

**៣.២.ការពិនិត្យពាក្យសុំ**..................................................................................................... ៣២

**៣.៣.ការរឹបអូសសិទ្ធិលើបំណុល** ......................................................................................... ៣៤

**៣.៣.១.ពាក្យសុំចេញដីការសម្រេចរឹបអូស**........................................................................៣៦

**៣.៣.២.នីតិវិធីនៃការចេញដីកាសម្រេចរឹបអូស** ................................................................... ៣៧

**៣.៣.៣.អានុភាពនៃដីកាសម្រេចរឹបអូស** .............................................................................៣៩

**៣.៣.៤.ការប្រមូលបំណុល**...............................................................................................៣៩

**៣.៤.ការលក់សិទ្ធិលើបំណុល** .............................................................................................៤០

**៣.៤.១.ស្ថាប័នមានសមត្ថកិច្ចអនុវត្តការលក់**.......................................................................៤១

**៣.៤.២.នីតិវិធីក្នុងការលក់ឡាយឡុង**...................................................................................៤៤

៣.៤.២.១ការលក់ឡាយឡុងដោយផ្ទាល់មាត់ .........................................................................៤៤

៣.៤.២.២.ការលក់ឡាយឡុងដោយស្រោមសំបុត្រ .....................................................................៤៥

៣.៤.២.៣.កំណត់វិធីលក់ ............................................................................................. ៤៦

៣.៤.២.៤.ការជូនដំណឹងពីការលក់ជាសាធារណៈ...................................................................... ៤៦

៣.៤.២.៥.សំណើរទិញ ................................................................................................. ៤៦

៣.៤.២.៦.ការអនុវត្តការលក់ ........................................................................................................ ៤៧
៣.៤.២.៧.លទ្ធកម្មចលនវត្ថុដែលបានលក់............................................................................ ៤៨
៣.៤.២.៨.កំណត់ហេតុនៃការលក់ ......................................................................................... ៤៨
**៣.៥.ការបែកចំណែក**................................................................................................................... ៤៨
**៣.៥.១.ម្ចាស់បំណុលដែលមានសិទ្ធិទទួលបានចំណែក**................................................................. ៤៨
**៣.៥.២.នីតិវិធីបែកចំណែក**.................................................................................................................៤៩
៣.៥.២.១.ការបែកចំណែកដោយការព្រមព្រៀង .......................................................................៤៩
៣.៥.២.២.ការបែកចំណែកដោយតុលាការ ................................................................................ ៥០
**៣.៦.ការអនុវត្តដោយបង្ខំសិទ្ធិលើបំណុលជាការប្រគល់ចលនវត្ថុ** .................. ៥០
**៣.៦.១.ការប្រគល់ចលនវត្ថុ**...............................................................................................................៥០
៣.៦.១.១.ការដាក់ពាក្យសុំ..........................................................................................................៥១
៣.៦.១.២.ការពិនិត្យពាក្យសុំ ........................................................................................................ ៥២
៣.៦.១.៣.ការស្នើសុំកម្លាំង ..........................................................................................................៥៤
៣.៦.១.៤.នីតិវិធីប្រគល់ចលនវត្ថុ.................................................................................................៥៤
៣.៦.១.៥.ការបិទបញ្ចប់ការប្រគល់ .............................................................................................៥៥
**សេចក្តីសន្និដ្ឋាន** .......................................................................................................................... ៥៦
**អនុសាសន៍** ....................................................................................................................................... ៥៧
**ពន្យល់ពាក្យគន្លឹះ**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

វិស័យគតិយុត្តកម្ពុជាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង ដោយសារសង្គ្រាមស៊ីវិល ដែលក្នុងនោះច្បាប់និងលិខិតបទដ្ឋានក្រោមច្បាប់នានា សម្រាប់អនុវត្តទៅលើរឿងក្តី រដ្ឋប្បវេណី ក៏មានភាពខ្វះខាត និងទន់ខ្សោយដែរ។ ភាពមិនច្បាស់លាស់នៃវិធាននានាសម្រាប់យន្តការនៃការដោះស្រាយវិវាទរដ្ឋប្បវេណីជាឧបសគ្គមួយក្នុងចំណោមឧបសគ្គនានា ដែលរារាំងដំណើរអភិវឌ្ឍប្រទេសជាតិ ការកាត់បន្ថយភាពក្រីក្រ និងជាការរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ ដែលក្នុងនោះរួមមានសិទ្ធិផ្នែករដ្ឋប្បវេណីផងដែរ។ហើយនៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារ បុគ្គលឯកជនម្នាក់ៗដែលជាសមាជិកសង្គមនោះ ចូលរួមក្នុងជីវភាពសេដ្ឋកិច្ច តាមរយៈការដោះដូរទំនិញ និង សេវា ដោយប្រើរូបិយវត្ថុជាចម្បង ។ ជាធម្មតា ការដោះដូរទំនិញ និងសេវា ត្រូវបានធ្វើឡើងតាមរយៈកិច្ចសន្យា ឬ ការសន្យារវាងបុគ្គលម្នាក់ និង បុគ្គលម្នាក់ទៀត នៅក្នុងករណីជាច្រើនបុគ្គលនានា ប្រតិបត្តិតាមកិច្ចសន្យា គោរពសិទ្ធិរបស់ភាគីម្ខាងទៀត ហើយអនុវត្តករណីយកិច្ចរបស់ខ្លួន ដោយសេចក្តីសុចរិត ។ វាជាការធម្មតា ដែលប្រជាពលរដ្ឋរស់នៅក្នុងប្រទេសនីតិរដ្ឋ ត្រូវតែគោរពច្បាប់ ។ ក៏ដូចច្នេះដែរ បុគ្គលនានា តាំងចិត្តគោរពការសន្យារបស់ខ្លួន ដោយបុព្វហេតុនទំនុកចិត្តលើសង្គម ឬ ដោយបុព្វហេតុសាសនា។ ក្រមនីតិវិធីរដ្ឋប្បវេណីដែលត្រូវបានចាត់ទុកជាច្បាប់មូលដ្ឋានមួយសម្រាប់ការទ្រទ្រង់នីតិរដ្ឋ និងជាការធានានូវទំនុកចិត្តពីមជ្ឈដ្ឋានជាតិនិងអន្តរជាតិផងនោះត្រូវបានសភាកម្ពុជាអនុម័ត និងត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៧០៦/០២១ចុះថ្ងៃទី០៦ខែកក្កដា ឆ្នាំ២០០៦ហើយដែលត្រូវយកទៅអនុវត្តនៅពេលមួយឆ្នាំក្រោយពីពេលដែលច្បាប់នេះចូលជាធរមាន ។

ក្រមនីតិវិធីរដ្ឋប្បវេណីបានប្រកាសឲ្យប្រើនៅថ្ងៃទី៣០ខែកក្កដា ឆ្នាំ២០០៦ ហើយដែលត្រូវបានដាក់ឲ្យអនុវត្តចាប់ពីខែកក្កដាឆ្នាំ២០០៧ ក្រោមកិច្ចសហការជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជានិងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន។

ក្រមនីតិវិធីថ្មីនេះគឺជាមូលដ្ឋានគ្រឹះនៃអ្នកច្បាប់និងអ្នកវិជ្ជាជីវៈដូចជា ចៅក្រម អាជ្ញាសាលា ក្រឡាបញ្ជីសារការី និងមេធាវីដែលជាស្ថាប័នមានសមត្ថកិច្ចសម្រាប់យកទៅអនុវត្តក្នុងគោលដៅធ្វើឲ្យសង្គមមួយមានយុត្តិធម៌។ដើម្បីការពារដល់សិទ្ធិទាមទារ និង សិទ្ធិ ប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជននោះ៖ ត្រឹមតែការកំណត់ដោយតុលាការ អំពីអត្ថិភាពនៃសិទ្ធិទាំង នោះនៅក្នុងសាលក្រម ឬ សាលដីកា នៅមិនទាន់គ្រប់គ្រាន់ទេ ។ បន្ថែមពីលើនេះ ត្រូវមានការផ្តល់តាវកាលិក ជាអាទិ៍ ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឧទាហរណ៍៖ “ដូចជាការបង់ប្រាក់តាមចំនួនកំណត់ណាមួយ ការប្រគល់ចលនវត្ថុណាមួយជាក់លាក់ជាដើម” ឬ ការផ្តល់តាវកាលិក

ជាប្រាក់ដែលជាគោលបំណងនៃសិទ្ធិទាមទារ ឱ្យសងជាប្រាក់ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ យ៉ាងជាក់ស្តែងផងដែរ។នៅក្នុងរឿងក្តីរដ្ឋប្បវេណីក្នុងការសម្រេចសិទ្ធិទាមទាររបស់ខ្លួន ដែលមានកំណត់នៅក្នុងលិខិតអនុវត្តរបស់ម្ចាស់បំណុលនៃការអនុវត្តដែលត្រូវធ្វើតាមរយៈការអនុវត្តដោយបង្ខំ ដើម្បីអនុវត្តបានម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំអនុវត្តទៅស្ថាប័នអនុវត្ត។

## ២.ចំណោទបញ្ហា

ការសិក្សាអំពីប្រធានបទ "**ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល**" គឺនឹងសិក្សាអំពីនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។ចំណោទបញ្ហាសំខាន់នៅក្នុងប្រធានបទនេះមានដូចជា៖

- តើស្ថាប័នណាមានសមត្ថកិច្ច ធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល?
- តើអាជ្ញាសាលាមានសមត្ថកិច្ចចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលទេ?
- តើការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានប៉ុន្មានប្រភេទ?
- តើនីតិវិធីមួយៗចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានដំណើរការយ៉ាងដូចម្តេច?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវសារណាប្រធានបទ "ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល" មកសិក្សានៅពេលនេះគឺមានគោលបំណង ដើម្បីអភិវឌ្ឍន៍នូវវិស័យច្បាប់សម្រាប់ព្រះរាជាណាចក្រកម្ពុជា និងសិក្សាពីក្របខណ្ឌច្បាប់ដែលកំពុងនៅជាធរមានពាក់ព័ន្ធ នឹងនីតិវិធីក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដើម្បីឆ្លុះបញ្ចាំងឲ្យកាន់តែច្បាស់លាស់។ហើយគោលបំណងនៃការសរសេរនេះគឺដើម្បីស្វែងយល់អំពី៖ ប្រភេទនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល, របៀបសរសេរពាក្យសុំអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល, របៀបនៃការពិនិត្យពាក្យសុំអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល, សិទ្ធិលើបំណុលដែលអាចរឹបអូសបាន និងដែលមិនអាចរឹបអូសបាន, ការកម្រិតពីទំហំនៃការរឹបអូស និងការប្តូរទំហំនៃការរឹបអូសចំពោះសិទ្ធិលើបំណុល, ការតវ៉ាការផ្អាក និងការលុបចោលការរឹបអូសដោយបង្ខំចំពោះសិទ្ធិលើបំណុល។

ម្យ៉ាងទៀតគោលបំណងដែលសំខាន់ចំពោះប្រធានបទខាងលើនេះ គឺដើម្បីសិក្សាស្វែងយល់ពីចំណុចខ្លាំងនិងចំណុចខ្សោយ រួមទាំងបញ្ហាប្រឈមដែលកើតមានឡើងនោះ ហើយនិងប្រៀបធៀបបញ្ញត្តិនៃច្បាប់ដែលបានចែង។

## ៤.ដែនកំណត់ និងទំហំនៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះ គឺធ្វើការសិក្សាតែទៅលើនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលតែប៉ុណ្ណោះ រីឯនីតិវិធីពាក់ព័ន្ធផ្សេងៗទៀតពុំបានលើកយកមកធ្វើការសិក្សាឡើយ។ លើសពីនេះទៅ

ទៀត នីតិវិធីដែលប្រធានបទលើកយកមកនេះ គឺសិក្សាតែនៅក្នុងក្របខណ្ឌដែលបាននឹងកំពុងតែអនុវត្តនៅសាលាដំបូងរាជធានីភ្នំពេញ។ ដូចគ្នាផងដែរការសិក្សានេះគឺសិក្សាតែក្នុងក្របខណ្ឌច្បាប់ធរមានតែប៉ុណ្ណោះ ចំពោះច្បាប់ពីមុនៗដែលនិរាករណ៍ ឬបទប្បញ្ញត្តិច្បាប់បរទេសពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺពុំបានលើកយកមកធ្វើការសិក្សានោះទេ។

## ៥.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- ជំពូកទី១៖ សញ្ញាណនៃការអនុវត្តដោយបង្ខំ
- ជំពូកទី២៖ លក្ខខណ្ឌទូទៅសម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល
- ជំពូកទី៣៖ ការអនុវត្តដោយបង្ខំសិទ្ធិលើបំណុលមានកម្មវត្ថុជាការសងប្រាក់

# ជំពូកទី១ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំគឺជានីតិវិធីតាមផ្លូវតុលាការក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជនដោយប្រើអំណាចរបស់រដ្ឋ។ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីមានគោលបំណងផ្តល់ទៅឱ្យភាគីឯកជន ដែលមានសិទ្ធិដែលបានកំណត់ដោយច្បាប់នូវការការពារសិទ្ធិទាំងនោះ។[1] ដើម្បីការពារដល់សិទ្ធិទាមទារ និងសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជននោះ ត្រឹមតែការកំណត់ដោយតុលាការអំពីអត្ថិភាពនៃសិទ្ធិទាំងនោះនៅក្នុងសាលក្រម ឬសាលដីកានៅមិនទាន់គ្រប់គ្រាន់ទេ ។

បន្ថែមពីលើនេះត្រូវមានការផ្តល់តាវកាលិក ជាអាទិ៍ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬការផ្តល់តាវកាលិកជាប្រាក់ដែលជាគោលបំណងនៃសិទ្ធិទាមទារឱ្យសងជាប្រាក់ ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគយ៉ាងជាក់ស្តែងផងដែរ។ ហេតុនេះហើយដើម្បីការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិនៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីដែលមានគោលបំណងការពារសិទ្ធិរបស់បុគ្គលឯកជន ចាំបាច់ត្រូវមានការរៀបចំនៅនីតិវិធីសម្រាប់អនុវត្តដោយបង្ខំក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចផ្តល់តាវលិក ឬ កូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត ក្នុងគោលដៅសម្រេចឱ្យបាននូវការអនុវត្តកាតព្វកិច្ចដែលជាកម្មនៃសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគតាមរយៈការប្រើប្រាស់អំណាចអាជ្ញាបញ្ញារបស់រដ្ឋ។ អ្វីដែលត្រូវបានរៀបចំឡើងដើម្បីបំពេញភាពចំបាច់នេះ គឺការអនុវត្តដោយបង្ខំ។

ការអនុវត្តដោយបង្ខំជាផ្នែកដ៏សំខាន់នៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីៈការអនុវត្តដោយបង្ខំគឺជាផ្នែកដ៏សំខាន់នៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី។ ក៏ប៉ុន្តែការអនុវត្តដោយបង្ខំគឺជានីតិវិធីឯករាជ្យមួយដែលបានអនុវត្ត ដោយអាជ្ញាធររដ្ឋផ្សេងពីអាជ្ញាធរដែលអនុវត្តនីតិវិធីបណ្តឹងដែលហៅក្នុងន័យចង្អៀត ថានីតិវិធីរដ្ឋប្បវេណីការអនុវត្តដោយបង្ខំមិនមែនជានីតិវិធីបន្ទាប់ ឬបន្តពីនីតិវិធីបណ្តឹងទេតែគឺជានីតិវិធីឯករាជ្យមួយដែលចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុល ដែលត្រូវការឱ្យមានការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគរបស់ខ្លួន។

ស្ថាប័នរដ្ឋដែលមានតួនាទីធ្វើការអនុវត្តដោយបង្ខំវិញ ភាគីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយ បង្ខំហៅថា"ស្ថាប័នអនុវត្ត"។ ចំពោះភាគីទំនាស់នៅក្នុងនៃការអនុវត្តដោយបង្ខំវិញភាគីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំហៅថា"ម្ចាស់បំណុលនៃការអនុវត្ត" ចំណែកភាគីម្ខាងទៀតហៅថាកូនបំណុលនៃការអនុវត្ត ។

ប្រធាននៃនីតិវិធីនៃការអនុវត្តដោយបង្ខំមានស្ថាប័នអនុវត្តម្ចាស់បំណុលនិងកូនបំណុល។ ប៉ុន្តែដោយសារថានីតិវិធីនៃការអនុវត្តដោយបង្ខំគឺ ជានីតិវិធីដែលដាក់បន្ទុកនៃការអនុវត្តទៅលើកូនបំណុលដើម្បីឱ្យសម្រេចនូវ

[1] មាត្រា២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

សិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះឋានៈរបស់ភាគីទាំងពីរនៅក្នុងនីតិវិធីនេះមិនស្មើគ្នាទេ គឺខុសពីឋានៈរបស់ភាគីទាំងសងខាងនៅក្នុងនីតិវិធីបណ្តឹង។

ពិសេសជាងនេះទៅទៀតបទប្បញ្ញត្តិដែល ចែងអំពីនីតិវិធីនៃការអនុវត្តដោយបង្ខំបានកំណត់នូវបែបបទក្នុងកម្រិតអតិបរមា ដែលអាចបានជាផលប្រយោជន៍ដល់ម្ចាស់បំណុលនិងបែបបទក្នុងកម្រិតអប្បបរមាដែលចាំបាច់សម្រាប់ការការពារសិទ្ធិរបស់បំណុល។អាស្រ័យហេតុនេះហើយគួរកត់សំគាល់ថាការធ្វើសកម្មភាពបែបណាមួយ ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់កូនបំណុលហួសអំពីទំហំដែលបានកម្រិតទុកនេះមិនត្រូវបានអនុញ្ញាតឡើយ។ បទប្បញ្ញត្តិមួយចំនួននៃការអនុវត្តដោយបង្ខំគ្រាន់តែជាគោលការណ៍ណែនាំតែប៉ុណ្ណោះ។ឯមួយចំនួនទៀត គ្រាន់តែមានអានុភាពក្នុងទំហំដែលថាសកម្មភាពនៃការអនុវត្តដោយបង្ខំដែលផ្ទុយនឹងបញ្ញត្តិនោះ មិនបាត់បង់សុពលភាពដោយស្វ័យប្រវត្តិឡើយ រហូតទាល់តែមានការលុបចោល ហើយម្យ៉ាងទៀតវិការៈនៃសកម្មភាពទាំងនោះ អាចជួលជុលឡើងវិញបានដោយការបោះបង់ ឬការបាត់បង់សិទ្ធិតវ៉ារបស់ភាគី។[២]

រចនាសម្ព័ន្ធនៃនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានលក្ខណៈស្មុគស្មាញជាពិសេស។ នីតិវិធីនៃការអនុវត្តដោយបង្ខំប្រភេទនេះ មានគោលដៅបង្កើតទំនាក់ទំនងគតិយុត្តជាសារធាតុមួយថ្មី រវាងភាគីទាំងពីរ ឬ ក្នុងករណីខ្លះរវាងភាគីនិងតតិយជន ក្នុងខណៈដែលនីតិវិធីចេះតែដំណើរការទៅមុខហើយចុងក្រោយ នឹងសម្រេចនូវសិទ្ធិទាមទារដោយការរួមបញ្ចូលនូវនីតិវិធីទាំងនោះ។ សកម្មភាពនានានៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំមានន័យត្រឹមជាដំណាក់កាលនៃនីតិវិធីប៉ុណ្ណោះទេ តែវាក៏មានអានុភាពក្នុងការបង្កើតទំនាក់ទំនងគតិយុត្តជាសារធាតុបែបនេះផងដែរ។

## ១.១.ស្ថាប័នអនុវត្តដោយបង្ខំ

### ១.១.១.តុលាការអនុវត្ត

សាលាដំបូងដែលទទួលសំណុំរឿងអនុវត្ត ឬដែលធ្វើការពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំហៅថាតុលាការអនុវត្ត។សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃគន្ថីទី៦ គឺជាតុលាការអនុវត្ត។[៣]

តុលាការអនុវត្តមានសមត្ថកិច្ចដូចជាៈ

-ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ[៤]

---

[២] មាត្រា៩៨ ការបាត់បង់នូវសិទ្ធិប្តឹងតវ៉ាស្តីពីអំពីនីតិវិធីបណ្តឹង

[៣] មាត្រា ៣៣៦ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី

[៤] មាត្រា ៤១៨ ក្រមដដែល

-ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល[៥]

-ការអនុវត្តដោយបង្ខំចំពោះនាវា

-ការអនុវត្តដោយបង្ខំឲ្យប្រគល់។[៦]

សមត្ថកិច្ចរបស់តុលាការអនុវត្ត គឺជាសមត្ថកិច្ចផ្តាច់មុខ។[៧]

## ១.១.២.អាជ្ញាសាលា

### ១.១.២.១.ប្រវត្តិ និងការវិវត្តនៃអាជ្ញាសាលា

អាជ្ញាសាលាត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ១៧៩៩ នៅសហរដ្ឋអាមេរិក។ សម្រាប់កម្ពុជា អាជ្ញាសាលាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣៨ ដែលមានលក្ខន្តិកៈស្តីពីអាជ្ញាសាលាចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៣៨។ បន្ទាប់មក នៅសម័យសាធារណៈរដ្ឋខ្មែរក៏គេនៅតែអនុវត្តលក្ខន្តិកៈឆ្នាំ១៩៣៨ដដែល ដែលបានរក្សានូវស្ថាប័នអាជ្ញាសាលា។ ចូលដល់សម័យកម្ពុជាប្រជាធិបតេយ្យដែលប្រទេសជាតិកំពុងជួបនូវសង្គ្រាមស៊ីវិលនោះអាជ្ញាសាលាត្រូវបញ្ចប់មុខងារ។ ក្រោយមកទៀត នៅសម័យប្រជាមានិតកម្ពុជាគឺគេនៅមិនទាន់ឃើញមានមន្ត្រី ឬស្ថាប័នអាជ្ញាសាលានោះទេ។ ជាមួយគ្នានេះដែរនៅសម័យរដ្ឋកម្ពុជាក៏នៅតែពុំទាន់មានអាជ្ញាសាលាដែរ តែមានច្បាប់ស្តីពីវិធីការអនុវត្តសាលក្រមរដ្ឋប្បវេណី។ ដល់សម័យព្រះរាជាណាចក្រកម្ពុជាគឺស្ថាប័នអាជ្ញាសាលា ចាប់ផ្តើមងើបមុខមាត់ឡើងវិញ ដោយគេបានមើលឃើញថានៅមុនពេលមានក្រមរដ្ឋប្បវេណី២០០៧ គឺពុំមានអាជ្ញាសាលាទេ ប៉ុន្តែ ក្រសួងយុត្តិធម៌ដែលមានឯកឧត្តម **ចែម ស្គួត** ជារដ្ឋមន្ត្រី បានចេញសេចក្តីសម្រេចបង្គាប់លេខ១៧៧ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តសាលក្រមសាលដីកាស្ថាពររដ្ឋប្បវេណី និងសេចក្តីសម្រេចផ្សេងៗដោយប្រគល់ភារកិច្ចទៅអោយព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងតាមតុលាការខេត្ត-ក្រុងនីមួយៗជាអ្នកទទួលបន្ទុកអនុវត្ត។

ក្រោយមកទៀតពេលមានក្រមនីតិវិធីរដ្ឋប្បវេណី២០០៧ ពាក្យអាជ្ញាសាលាត្រូវបានគេប្រើជាថ្មី។ នៅក្នុងក្រមនេះ ក៏ជាការបង្កើតនូវវិជ្ជាជីវៈអាជ្ញាសាលា អោយមាននៅក្នុងសង្គមកម្ពុជាជាលើកទី២បន្ទាប់ពីវិជ្ជាជីវៈអាជ្ញាសាលានេះត្រូវបានបង្កើតឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៣៨ ហើយវិជ្ជាជីវៈនេះ បានបាត់បង់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលការណ៍នេះបានបណ្តាលអោយប្រជាពលរដ្ឋមួយចំនួនធំមិនបានស្គាល់នូវវិជ្ជាជីវៈអាជ្ញាសាលា ។

[៥] មាត្រា ៤០២-៤០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[៦] មាត្រា ៤២៦ ក្រមដដែល

[៧] មាត្រា ៣៤៦ ក្រមដដែល

ដោយសារក្នុងក្រមរដ្ឋប្បវេណីតម្រូវអោយមានមន្ត្រី និងស្ថាប័នអាជ្ញាសាលាក្រសួងយុត្តិធម៌បានចេញប្រកាសលេខ៣០ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ប្រគល់ភារកិច្ចអោយព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង អោយក្លាយជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។ យោងតាមប្រកាសស្តីពីការជ្រើសរើសសិស្សអាជ្ញាសាលាជំនាន់ទី១ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ សិស្សអាជ្ញាសាលាជំនាន់ទី១មានចំនួន ២៧ នាក់ ក្នុងនោះមានសិស្សស្រីចំនួន ២នាក់ ។

### ១.១.២.២.លក្ខខណ្ឌដើម្បីក្លាយជាអាជ្ញាសាលា

អាជ្ញាសាលាជាមន្ត្រីរាជការ ដែលត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ចេញពីក្នុងចំណោមបុគ្គលដែលបានបំពេញគ្រប់លក្ខខណ្ឌមួយចំនួនតាមច្បាប់តម្រូវ។ អាជ្ញាសាលាត្រូវទទួលបានប្រាក់ខែពីរដ្ឋ និងសោហ៊ុយពីការអនុវត្ត ពីសំណាក់ម្ចាស់បំណុលនៃការអនុវត្ត ចំពោះការអនុវត្តមុខងាររបស់ខ្លួន ដែលនេះគឺជាចរិតលក្ខណៈពិសេសមួយរបស់អាជ្ញាសាលា ។

ដើម្បីក្លាយជាអាជ្ញាសាលាបានលុះត្រាឆ្លងកាត់ ការប្រឡងជ្រើសរើសអោយចូលរៀននៅសាលាភូមិន្ទអាជ្ញាសាលា ឬត្រូវបានជ្រើសរើសអោយចូលរៀនវគ្គវិក្រឹត្យការដែលតាមន័យនេះបេក្ខជន ដែលត្រូវបានអនុញ្ញាតអោយចូលប្រឡង និងមន្ត្រីរាជការដែលត្រូវបានអនុញ្ញាតអោយចូលរៀនវគ្គវិក្រឹត្យការ ត្រូវបំពេញនូវលក្ខខណ្ឌដែលច្បាប់តម្រូវជាមុនសិន។

ចំពោះការប្រឡងជ្រើសរើសអោយចូលសិក្សាជាសិស្សអាជ្ញាសាលា លុះត្រាតែបេក្ខជននោះត្រូវបានបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជាត្រូវមានបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ និងត្រូវមានអាយុយ៉ាងច្រើនត្រឹម៣០ឆ្នាំគិតដល់ថ្ងៃប្រឡង ឬបេក្ខជនដែលមានបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ និងត្រូវមានអាយុយ៉ាងច្រើន ៣៥ឆ្នាំ ដល់ថ្ងៃប្រឡងចូល។ ដោយឡែកចំពោះបេក្ខជនដែលជាមន្ត្រីរាជការទាំងឡាយណាដែលមានបរិញ្ញាបត្រ និងមានអាយុយ៉ាងច្រើនបំផុត៤០ឆ្នាំគិតមកដល់ថ្ងៃប្រឡង ព្រមទាំងមិនមានទណ្ឌកម្មវិន័យ ដែលនាំអោយបាត់បង់នីតិសម្បទាវិជ្ជាជីវៈ ។

ផ្ទុយទៅវិញចំពោះចៅក្រមដែលមានបទពិសោធន៍ការងារយ៉ាងតិច៥ឆ្នាំ, ក្រឡាបញ្ជី ដែលមានបទពិសោធការងារយ៉ាងតិច៧ឆ្នាំ ព្រមទាំងមិនមានទណ្ឌកម្មខាងវិន័យដែលនាំអោយបាត់បង់នីតិសម្បទាវិជ្ជាជីវៈគឺអាចត្រូវបានជ្រើសរើសអោយចូលរៀនវគ្គវិក្រឹត្យការបាន។

បន្ទាប់ពីបានប្រឡងជាប់ ឬបន្ទាប់ពីត្រូវបានជ្រើសរើសអោយចូលរៀនវគ្គវិក្រឹត្យការហើយ នោះអ្នកទាំងនោះត្រូវបានកំណត់អោយចូលរួមក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងនោះចំពោះសិស្ស ដែលប្រឡងចូល

គឺត្រូវទទួលការបណ្តុះបណ្តាលសិក្ខាគារិកភាព និងកម្មសិក្សាក្នុងរយៈពេល២៤ខែ នៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងតាមបណ្តាសាលាដំបូងរាជធានីខេត្តនានា។

ដោយឡែក ចំពោះសិស្សដែលជាមន្ត្រីក្រឡាបញ្ជីតុលាការវិញ គឺត្រូវទទួលការបណ្តុះបណ្តាលសិក្ខាគារិកភាព និងកម្មសិក្សារយៈពេល១៨ខែនៅរាជបណ្ឌិតសភាវិជ្ជាជីវតុលាការ និងតាមសាលាដំបូងរាជធានីខេត្តនានា។

### ១.១.២.៣.ឋានៈសិទ្ធិ និងភារកិច្ចរបស់អាជ្ញាសាលា

មន្ត្រីអាជ្ញាសាលាត្រូវធ្វើទំនាក់ទំនងជាមួយនឹងម្ចាស់បំណុល ។ តាមរយៈនេះអាជ្ញាសាលាត្រូវធ្វើសកម្មភាពនៃការអនុវត្តដោយបង្ខំដោយផ្អែកលើពាក្យសុំត្រឹមត្រូវរបស់ម្ចាស់បំណុល និងដោយអនុលោមទៅតាមនីតិវិធីដែលបានកំណត់ដោយច្បាប់។ ទំនាក់ទំនងនេះគឺជាទំនាក់ទំនងរវាងបុគ្គលឯកជន និងអាជ្ញាធររដ្ឋនៅក្រោមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី មិនមែនជាទំនាក់ទំនងនៃអាណត្តិនៅក្រោមច្បាប់ឯកជនទេ ។

អាជ្ញាសាលាត្រូវធ្វើការអនុវត្តដោយបង្ខំនៅក្នុងឆន្ទានុសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន។ ទោះបីជាអាជ្ញាសាលាធ្វើតាមការណែនាំរបស់ម្ចាស់បំណុលក៏ដោយ ប្រសិនបើសកម្មភាពនៃការអនុវត្តដោយបង្ខំនោះខុសច្បាប់ នោះអាជ្ញាសាលាមិនអាចគេចផុតពីការទទួលខុសត្រូវចំពោះសម្មភាពនោះបានទេ។ អាជ្ញាសាលាអាចគោរពតាមឆន្ទៈរបស់ម្ចាស់បំណុលបានហើយចំពោះទំហំ និង កម្រិតនៃការអនុវត្តដោយបង្ខំ ប៉ុន្តែប្រសិនបើការណែនាំ ឬសំណូមពរនោះខុសច្បាប់ អាជ្ញាសាលាមិនត្រូវធ្វើតាមឡើយ ។

ដោយសារថាសកម្មភាពរបស់អាជ្ញាសាលាគឺជាការប្រើអំណាចអនុវត្តរបស់រដ្ឋ នោះមន្ត្រីដែលទទួលបន្ទុកការអនុវត្ត ពុំមែនជានិយោជិតរបស់ម្ចាស់បំណុលឡើយ។ ហេតុនេះហើយប្រសិនបើអាជ្ញាសាលាបង្កឲ្យមានការខូចខាតដល់កូនបំណុល ឬតតិយជនដោយសារការអនុវត្តដោយបង្ខំម្ចាស់បំណុល មិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលក្នុងនាមជានិយោជកឡើយ។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលឲ្យអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំមិនត្រឹមត្រូវដោយចេតនា ឬដោយការធ្វេសប្រហែស ហើយបង្ក អោយមានការខូចខាតដល់អ្នកដទៃនោះម្ចាស់បំណុលអាច នឹងមានការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដោយផ្ទាល់ខ្លួន ។

មួយវិញទៀត អាជ្ញាសាលាក៏ជាអ្នកដែលធ្វើទំនាក់ទំនងជាមួយនឹងកូនបំណុល និងតតិយជនផងដែរ ។ អាជ្ញាសាលាមានសិទ្ធិប្រើប្រាស់អំណាចបង្ខំទៅលើកូនបំណុលនិងតតិយជននៅក្នុងទំហំដែលចាំបាច់ដើម្បី ធ្វើការអនុវត្តដោយបង្ខំហើយត្រូវទទួលខុសត្រូវក្នុងការធ្វើសកម្មភាពនេះដោយស្របច្បាប់ ។

ម្យ៉ាងទៀតដូចបានរៀបរាប់ខាងលើដោយសារថា ទំនាក់ទំនងរវាងម្ចាស់បំណុលនិងអាជ្ញាសាលាពុំមែនជាទំនាក់ទំនងនៃអាណត្តិនៅក្រោមច្បាប់ឯកជនទេនោះ ម្ចាស់បំណុលមិនអាចប្រគល់ទៅអោយអាជ្ញាសាលានូវសិទ្ធិតំណាងតាមច្បាប់ឯកជនដូចជាការទទួលការសង ឬការផ្សះផ្សារបានឡើយ។ ក៏ប៉ុន្តែនៅក្នុងការអនុវត្ត

ដោយបង្ខំចំពោះចលនវត្ថុ និងការអនុវត្តដោយបង្ខំអោយប្រគល់ចលនវត្ថុ អាជ្ញាសាលាមានសិទ្ធិទទួលការអនុវត្តដោយស្ម័គ្រចិត្តទៅតាមច្បាប់បាន។ គោលបំណងនៃបញ្ញត្តិនេះគឺដើម្បីកុំអោយមានការខាតបង់នៅក្នុងការអនុវត្ត ក្នុងករណីដែលកូនបំណុលនៃការអនុវត្តមានឆន្ទៈធ្វើការសងដោយស្ម័គ្រចិត្ត ។

ជាមួយតុលាការអនុវត្ត គឺតុលាការអនុវត្ត និងអាជ្ញាសាលាសុទ្ធតែជាស្ថាប័នឯករាជ្យរបស់រដ្ឋរៀងៗខ្លួន ហើយ អាជ្ញាសាលាពុំមែនជាស្ថាប័នជំនួយបន្ថែមរបស់តុលាការអនុវត្តទេ។ ច្បាប់អនុញ្ញាតឲ្យតុលាការអនុវត្តផ្តល់ការណែនាំប្រគល់សិទ្ធិ និងបង្គាប់អាជ្ញាសាលានៅក្នុងករណីជាក់លាក់មួយចំនួន ប៉ុន្តែបទប្បញ្ញត្តិទាំងនេះត្រូវបានរៀបចំឡើង ដោយយកទំនាក់ទំនងឯករាជ្យរវាងស្ថាប័នទាំងពីរមកជាមូលដ្ឋាន និងដោយគិតពិចារណាទៅលើចរិតលក្ខណៈរបស់ស្ថាប័ននីមួយៗផង។

ដោយឡែកចំពោះរដ្ឋបាលយុត្តាធិការវិញ អាជ្ញាសាលាត្រូវទទួលការត្រួតពិនិត្យពីសាលាដំបូងដែលខ្លួនស្ថិតនៅ ចំពោះមុខងាររបស់ខ្លួន។ ក៏ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលជាអ្នកតែងតាំងមានសិទ្ធិអំណាចដាក់ទណ្ឌកម្មខាងផ្នែកវិន័យ ចំពោះការបំពានលើមុខងាររបស់អាជ្ញាសាលា ។

អាជ្ញាសាលាក៏ត្រូវបានគេស្គាល់យ៉ាងច្បាស់ថា ជាស្ថាប័នមួយដែលអនុវត្តការដកហូត ។ ក្នុងករណីដែលអាជ្ញាសាលាមានទំនាក់ទំនងញាត្តិ ឬមានផលប្រយោជន៍ទាក់ទងជាក់លាក់ផ្សេងៗទៀតជាមួយនឹងភាគីអាជ្ញាសាលានោះត្រូវដកហូតចេញពីការអនុវត្តមុខការរបស់ខ្លួនដើម្បីជៀសវាងភាពមន្ទិលសង្ស័យអំពីភាពត្រឹមត្រូវនៅក្នុង ការបំពេញមុខនាទីនោះ ។

### ១.១.២.៤.សិទ្ធិ និង ភាតព្វកិច្ចរបស់អាជ្ញាសាលា

អាជ្ញាសាលាជាស្ថាប័នមួយដែលមានអំណាចក្នុងការប្រើប្រាស់កម្លាំង ក្នុងការអនុវត្តមុខងារសមត្ថកិច្ចរបស់ខ្លួន។ តាមរយៈនេះ អាជ្ញាសាលាមានសិទ្ធិ៖

-សិទ្ធិក្នុងការប្រើកម្លាំងនគរបាល៖ នៅពេលអនុវត្តមុខងាររបស់ខ្លួនអាជ្ញាសាលាអាចប្រើប្រាស់កម្លាំង ឬ នគរបាល ឬកម្លាំងផ្សេងទៀត ដើម្បីជួយសម្រួលដល់ការអនុវត្តកិច្ចការរបស់ខ្លួន

-សិទ្ធិក្នុងការឆែកឆេរ៖ នៅពេលចុះអនុវត្តការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តអាជ្ញាសាលាអាចចុះឆែកឆេរស្វែងរកនូវចលនវត្ថុរបស់កូនបំណុលដើម្បីរឹបអូលបាន

-សិទ្ធិក្នុងការរកអ្នកវាយតម្លៃ៖ ចំពោះការលក់ចលនវត្ថុ ដែលមានតម្លៃខ្ពស់អាជ្ញាសាលាអាចចាត់តាំងអ្នកវាយតម្លៃអោយធ្វើការវាយតម្លៃលើចលនវត្ថុនោះបាន

-សិទ្ធិរក្សាសណ្តាប់ធ្នាប់នៅក្នុងពេលប្រតិបត្តិការលក់ចលនវត្ថុដែលត្រូវបានរឹបអូសៈ ករណីនេះ អាជ្ញាសាលាអាចហាមបុគ្គលមួយចំនួនមិនអោយចូលកន្លែងលក់ ឬមិនអនុញ្ញាតអោយអ្នកទិញ ដែលមិនបាន បង់ប្រាក់ជាមុនមកធ្វើការដេញថ្លៃលើកទី១ក្នុងការលក់លើកទី២នោះទេ

-សិទ្ធិជ្រើសរើសវត្ថុដែលត្រូវរឹបអូសៈ នៅពេលចុះអនុវត្តរឹបអូសចលនវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្ត តែមិនត្រូវធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ម្ចាស់បំណុលឡើយ

-សិទ្ធិក្នុងការលុបចោលការរឹបអូសៈបើអាជ្ញាសាលាអាចយល់ឃើញថាករណីរឹបអូសចលនវត្ថុមាន ទំហំហួសប្រមាណ ឬករណីប៉ានប្រមាណថាគ្មានចំនួនសេសសល់ ឬចលនវត្ថុដែលត្រូវបានរឹបអូសមិនអាចប្តូរ ជាប្រាក់បាន អាជ្ញាសាលាអាចលុបចោលការរឹបអូសទាំងនោះបាន

-សិទ្ធិក្នុងការអនុញ្ញាតអោយកូនបំណុលនៃការអនុវត្តរក្សាទុកវត្ថុរឹបអូសៈ ផ្អែកតាមរយៈការយល់ ឃើញរបស់អាជ្ញាសាលាបើមានផលលំបាកក្នុងការដឹកជញ្ជូន ឬចំណាយច្រើនក្នុងការរក្សានូវចលនវត្ថុដែលត្រូវ បានរឹបអូស ឬប្រើប្រាស់ចលនវត្ថុនោះដោយតម្រូវអោយបិតស្លាក ឬ ដាក់សញ្ញាលើចលនវត្ថុនោះ

-សិទ្ធិក្នុងការបញ្ជូនរឿងក្តីៈ ក្នុងករណីដែលមានពាក្យស្នើសុំអោយអនុវត្តដោយបង្ខំលើចលនវត្ថុថ្មីមួយ ទៀតចំពោះកូនបំណុលនៃការអនុវត្តនិងកន្លែងដដែលនោះហើយព្រមទាំងគ្មានចលនវត្ថុណាសម្រាប់រឹបអូសជា ថ្មីបានទេ ឬក៏មានពាក្យសុំបញ្ជូនរឿងក្តីនោះ អាជ្ញាសាលាអាចបញ្ជូនរឿងក្តីបាន

-ករណីកិច្ចយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណៈ នៅពេលចុះប្រតិបត្តិការបំពេញមុខងារតួនាទីរបស់ ខ្លួនព្រមទាំងត្រូវសុំការអនុញ្ញាតចុះអនុវត្តពេលថ្ងៃឈប់សម្រាកក្នុងករណីចន្លោះម៉ោង៦ល្ងាច និងម៉ោង៦ព្រឹក។ ហើយស្នើសុំនេះគឺត្រូវធ្វើឡើងនូវសាលាដំបូងដែលខ្លួនតាំងនៅ។ បន្ថែមពីលើនេះ នៅពេលបំពេញមុខនាទី អាជ្ញាសាលាត្រូវបង្ហាញលិខិតដែលបញ្ជាក់ថាខ្លួនបានទទួលអនុញ្ញាតនោះផងដែរ។ ការកំណត់បែបនេះគឺ ដើម្បីជៀសវាងការបៀតបៀនដល់ភាពស្ងប់សុខ នៅក្នុងជីវិភាពរស់នៅប្រចាំថ្ងៃរបស់កូនបំណុលដោយពុំមាន ភាពចាំបាច់ ។

## ១.២.ប្រភេទនៃការអនុវត្តដោយបង្ខំ

ដើម្បីការពារដល់សិទ្ធិទាមទារ និងសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជននោះត្រឹមតែការ កំណត់ដោយតុលាការអំពីអត្ថិភាពនៃសិទ្ធិទាំងនោះនៅក្នុងសាលក្រម ឬសាលដីកានៅមិនទាន់គ្រប់គ្រាន់ទេ។ បន្ថែមពីលើនេះត្រូវមានការផ្តល់តាវកាលិក ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬការផ្តល់តាវកាលិកជាប្រាក់ដែលជា គោលបំណងនៃសិទ្ធិទាមទារឱ្យសងជាប្រាក់ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគយ៉ាងជាក់ស្តែងផងដែរ។ ហេតុដូចនេះហើយដើម្បីការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិនៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ដែលមានគោល

បំណងការពារនូវសិទ្ធិរបស់បុគ្គលឯកជន ចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់អនុវត្តដោយបង្ខំ ក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចផ្តល់តាវកាលិកឬកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្តនោះទេ ដូច្នេះហើយក្នុងគោលដៅសម្រេចឱ្យបាននូវការអនុវត្តកាតព្វកិច្ច ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ តាមរយៈការប្រើប្រាស់អំណាចអាជ្ញាបញ្ជារបស់រដ្ឋ។ អ្វីដែលត្រូវបានរៀបចំឡើងដើម្បីបំពេញភាពចាំបាច់នេះ គឺការអនុវត្តដោយបង្ខំ។

ការអនុវត្តដោយបង្ខំ ចែកចេញជាពីរប្រភេទ គឺការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់ និងការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងសងជាប្រាក់។

តាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ការអនុវត្តដោយបង្ខំត្រូវបានបែងចែកជា៣ប្រភេទធំៗគឺការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់ ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងសងជាប្រាក់ និង ការអនុត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ។

### ១.២.១.ការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់

ការអនុវត្តដើម្បីប្រមូលប្រាក់ដោយបង្ខំពីទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ហៅថាការអនុវត្តចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់។ ទ្រព្យសម្បត្តិដែរអាចក្លាយជាទៅជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំហៅថាទ្រព្យសម្បត្តិទទួលខុសត្រូវ។

ទ្រព្យសម្បត្តិទទួលខុសត្រូវនៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់ជាគោលការណ៍ គឺជាទ្រព្យសម្បត្តិទាំងអស់ដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណង ឱ្យសងជាប្រាក់ជាគោលការណ៍គឺជាទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលនៃការអនុវត្ត ។

ដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ម្ចាស់បំណុលនៃការអនុវត្តអាចធ្វើការអនុវត្តដោយបង្ខំទៅលើទ្រព្យសម្បត្តិរបស់កូនបំណុលដែលអាចជាចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និងនាវាជាដើម ។

-ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ៖ ការអនុវត្តដោយបង្ខំដែលត្រូវបានធ្វើឡើងតាមវិធីដែលអាជ្ញាសាលារឹបអូសយកចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។ ចលនវត្ថុនៅទីនេះរួមមានចលនវត្ថុតាមក្រមរដ្ឋប្បវេណីនិងផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយដែលអាចនឹងទទួលផលយ៉ាង

ច្បាស់នៅក្នុងអំឡុងពេល១ខែ។[៨]ម្យ៉ាងទៀត ចលនវត្ថុនៅទីនេះក៏រួមបញ្ចូលផងដែរនូវរូបិយវត្ថុដូចជាក្រដាសប្រាក់ និងកាក់ប្រាក់ដែលមិនទាមទារឱ្យមាននីតិវិធីនៃការប្តូរជាប្រាក់នោះទេ។

-ការអនុវត្តចំពោះអចលនវត្ថុះជានីតិវិធីដែលម្ចាស់បំណុលនៃការអនុវត្ត ដាក់ពាក្យសុំទៅតុលាការអនុវត្ត ដើម្បីលក់ឡាយឡុងអចលនវត្ថុរបស់កូនបំណុលយកប្រាក់មកសងខ្លួន។ គេអាចនិយាយម្យ៉ាងទៀតថាជាវិធីអនុវត្តដែលតាមរយៈនោះ តុលាការអនុវត្តរឹបអូសទ្រព្យដែលជាកម្មសិទ្ធិរបស់កូនបំណុលរួចលក់អចលនវត្ថុនោះដោយបង្ខំហើយទើបយកប្រាក់ដែលបានមកពីការលក់នោះទៅសម្រេចសិទ្ធិនៃការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុល។ ការលក់ដោយបង្ខំចាប់ផ្តើមដោយដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដែលតុលាការអនុវត្តចេញ តាមពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុរបស់ម្ចាស់បំណុលនៃការអនុវត្ត[៩]។

នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុស្ថាប័នអនុវត្តគឺតុលាការអនុវត្ត។[១០]

អចលនវត្ថុដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុរួមមានដី អាគារដែលត្រូវបានចុះបញ្ជីចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអាគារនោះ។[១១]ការចាត់ទុកថាអាគារគឺជាអចលនវត្ថុឯករាជ្យអំពីដី ឬយ៉ាងណានោះវាអាស្រ័យទៅលើគោលការណ៍អាគារគឺជាសមាសភាគនៃដី ដូច្នេះជាគោលការណ៍ទូទៅអាគារមិនអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ នៅក្នុងលក្ខណៈជាអចលនវត្ថុឯករាជ្យបានទេ។ ក៏ប៉ុន្តែនៅក្នុងពេលបច្ចុប្បន្ននេះ យើងបានដឹងថាមានករណីដែលអាចចុះបញ្ជីអាគារជាកម្មវត្ថុនៃកម្មសិទ្ធិដោយឯករាជ្យបានតាមច្បាប់ក្រមនីតិវិធីរដ្ឋប្បវេណីដោយសារមានកាលៈទេសៈពិសេសដីមិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិតាមច្បាប់រដ្ឋប្បវេណីទេ នៅក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជាជាពិសេសទីក្រុងភ្នំពេញ។

ហេតុនេះហើយនៅក្នុងករណីបែបនេះ អាគារដែលត្រូវបានចុះបញ្ជីក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុបានដែរ។ ចំពោះអាគារដែលមិនបានចុះបញ្ជីវាគឺជាសមាសភាគនៃកម្មសិទ្ធិលើដី ឬសមាសភាគសិទ្ធិប្រត្យក្សប្រើប្រាស់ដីដែលមិនអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដោយឯករាជ្យបានទេ។ នៅក្នុងករណីបែបនេះ ដោយសារថាអានុភាពនៃការអនុវត្តដោយបង្ខំចំពោះកម្មសិទ្ធិលើដីឬចំពោះសិទ្ធិប្រត្យក្សប្រើប្រាស់ដី មានទៅលើអាគារដែលជាសមាសភាគនៃសិទ្ធិនោះដែរ។ អាគារទាំងនោះនឹងត្រូវបានលក់ដោយបង្ខំជាមួយនឹងកម្មសិទ្ធិលើដី ឬសិទ្ធិប្រត្យក្សប្រើប្រាស់ដីនោះ។[១២]

[៨] មាត្រា ៣៨៤ កថាខណ្ឌទី៤ ចលនវត្ថុដែលបានកំណត់
[៩] មាត្រា ៤១៩ កថាខណ្ឌទី១ ដីកាសម្រេចចាប់ផ្តើម
[១០] មាត្រា ៤១៩ កថាខណ្ឌទី១ ដីកាសម្រេចចាប់ផ្តើម
[១១] មាត្រា ៤១៧ កថាខណ្ឌទី១ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ
[១២] មាត្រា៤២១ កថាខណ្ឌទី១ អានុភាពនៃការរឹបអូសអចលនវត្ថុ

តុលាការអនុវត្តដែលមានសមត្ថកិច្ចត្រូវបានកំណត់ដូចតទៅៈ

(១) បើយកដីឬអាគារដែលបានចុះបញ្ជីធ្វើជាកម្មវត្ថុនៃការអនុវត្តគឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនោះ។

(២) បើយកចំណែកនៃកម្មវត្ថុសិទ្ធិអរិភោគលើដី ឬលើអាគារដែលបានចុះបញ្ជី ឬសិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានចុះបញ្ជីផលុបភោគដែលបានចុះបញ្ជី ឬចំណែកនៃកម្មសិទ្ធិទាំងពីរនេះដែលជាកម្មសិទ្ធិរួមធ្វើជាកម្មវត្ថុនៃការអនុវត្តគឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវចុះបញ្ជី។ សមត្ថកិច្ចទាំងនេះគឺជាសមត្ថកិច្ចផ្តាច់មុខ។

ការអនុវត្តចំពោះនាវា៖ ជានីតិវិធីដែលម្ចាស់បំណុលនៃការអនុវត្ត ដាក់ពាក្យសុំទៅតុលាការអនុវត្តដើម្បីលក់ឡាយឡុងនាវារបស់កូនបំណុលយកប្រាក់មកសងខ្លួន។ នាវាសំដៅទៅលើជលយានដែលមានចំណុះសរុបតោនស្មើនឹង និងលើសពី២០តោន និងជលយានដែលមានចំណុះសរុបជាតោនក្រោម២០តោនហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា។[១៣]

ចំពោះជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើស២០តោននោះទោះបីជាមិនត្រូវបានចុះបញ្ជីក៏ដោយ ក៏ចាត់ទុកថាជានាវាក្នុងន័យក្រម នីតិវិធីរដ្ឋប្បវេណីដែរ។ចំណុះសរុបជាតោន គឺជារង្វាស់ទំហំនៃនាវាដែលគេប្រើច្រើនបំផុតនាពេលបច្ចុប្បន្ននេះ។

### ១.២.២.ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងសងជាប្រាក់

ការអនុវត្តដើម្បីអោយកូនបំណុលនៃការអនុវត្តបំពេញតាវការលិក ឬសកម្មភាពណាមួយ ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលគ្មានគោលបំណងអោយសងជាប្រាក់នោះឡើយ។ តាមរយៈការអនុវត្តនេះស្ថាប័នអនុវត្តមិនចាំបាច់ធ្វើការចាត់ចែងប្តូរជាប្រាក់ឡើយ ពោលគឺគ្រាន់តែប្រគល់វត្ថុនោះអោយទៅភាគីម្ចាស់បំណុល ។ ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឲ្យសងជាប្រាក់អាចជាការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុ និងការអនុវត្តដោយបង្ខំឲ្យធ្វើ ឬមិនធ្វើសកម្មភាពណាមួយ។

-ការឱ្យប្រគល់ចលនវត្ថុ ៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមឱ្យប្រគល់ចលនវត្ថុនៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកនូវចំនួនជាកំណត់នៃវត្ថុជំនួស ប្រសិនបើវត្ថុជំនួសដែលជាកម្មវត្ថុ

[១៣] មាត្រា ៤៥៤ កថាខណ្ឌទី១ នាវាដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា

នៃការអនុវត្តផ្តល់តាវកាលិក នោះស្ថិតនៅក្រោមការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវដក យកវត្ថុនោះហើយប្រគល់ទៅឱ្យម្ចាស់បំណុល។

-ការឱ្យប្រគល់អចលនវត្ថុ ៖ សំដៅទៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោល បំណងឱ្យប្រគល់ការគ្រប់គ្រងលើទីកន្លែង ឬទីទំនេរណាមួយទៅឱ្យម្ចាស់បំណុល ឬតតិយជន។ វិធីអនុវត្តនេះ អាចធ្វើទៅបានដោយមិនចាំបាច់គិតអំពីអត្ថិភាព ឬនត្ថិភាពនៃការចុះបញ្ជី ឬសិទ្ធិផ្សេងៗដូចជាកម្មសិទ្ធិជាអាទិ៍នៃ អចលនវត្ថុដែលជាកម្មវត្ថុទេ ហើយថែមទាំងអាចធ្វើទៅបានចំពោះផ្នែកណាមួយនៃអចលនវត្ថុបន្ទប់មួយនៃផ្ទះ។

-ការអនុវត្តឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពណាមួយ ៖ ជាការអនុវត្តដែលតម្រូវអោយ កូនបំណុលត្រូវ បំពេញករណីកិច្ចអ្វីមួយ។ គេអាចបែងចកករណីកិច្ចនោះជាពីប្រភេទគឺ"ករណីកិច្ចផ្តល់ឱ្យ"ដូចជាការបង់ប្រាក់ការ ប្រគល់និង"ករណីយកិច្ចធ្វើ" ដែលមានកម្មវត្ថុជាការធ្វើ ឬមិនធ្វើសកម្មភាពអ្វីមួយ។ "ករណីយកិច្ចផ្តល់ឱ្យ" ដែល ស្មើនឹងសិទ្ធិទាមទារឱ្យបង់ប្រាក់ ឬឱ្យប្រគល់វត្ថុអ្វីមួយបើមើលពីទស្សនទានរបស់ម្ចាស់បំណុលសិទ្ធិត្រូវអនុវត្ត តាមវិធីនៃការអនុវត្តដោយផ្ទាល់ ដែលតាមរយៈនោះខ្លឹមសារនៃករណីយកិច្ចត្រូវបានសម្រេចដោយផ្ទាល់ដោយ ស្ថាប័នអនុវត្តដូចជាបានរៀបរាប់ពីខាងដើម។ ផ្ទុយទៅវិញចំពោះ"ករណីយកិច្ច" ដែលស្មើនឹងសិទ្ធិទាមទារឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពអ្វីមួយ ម្ចាស់សិទ្ធិវិញការសម្រេចនូវខ្លឹមសារនៃករណីយកិច្ចនោះដោយស្ថាប័នអនុវត្តមាន ការលំបាកច្រើន ឬមិនអាចធ្វើទៅកើតតែម្តង។

### ១.២.៣.ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ

ជាការអនុវត្តដោយបង្ខំដែលធ្វើឡើងតាមរយៈបុគ្គលដែលមានសិទ្ធិប្រាតិភោគ ដូចជាហ៊ីប៉ូតែក ឬសិទ្ធិ លើការបញ្ចាំដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីធ្វើការប្តូរជាប្រាក់ដោយបង្ខំនូវទ្រព្យសម្បត្តិ ដែលត្រូវបានធានា តាមរយៈស្ថាប័នអនុវត្ត ហើយទទួលបានការសងពីប្រាក់ដែលបានមកនោះបានមុនម្ចាស់បំណុលដទៃទៀត ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគមានដូចជាការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ការ អនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ឬទ្រព្យសម្បត្តិផ្សេងទៀត និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា។

-ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ៖ ចំពោះសិទ្ធិប្រាតិភោគដែលមានកម្មវត្ថុជាចលនវត្ថុក្រម រដ្ឋប្បវេណីចែងអំពីឯកសិទ្ធិទូទៅឯកសិទ្ធិលើចលនវត្ថុនិងសិទ្ធិលើការបញ្ចាំ។ ជាគោលការណ៍ ការអនុវត្តសិទ្ធិ ទាំងអស់នេះត្រូវធ្វើការតាមរយៈការលក់ចលនវត្ថុទាំងនោះ។[១៤]

[១៤] មាត្រា ៨៣២ និង ៥០៤ នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំ

-ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតការអនុវត្តសិទ្ធិដោយផ្អែកលើឧបាទេសកម្មលើវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគត្រូវអនុលោមទៅតាមនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។[១៥]

សិទ្ធិលើបំណុលនៅក្នុងការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតត្រូវសំដៅដល់"សិទ្ធិលើបំណុលដែលមានគោលបំណងសងឱ្យជាប្រាក់ឬ ឱ្យប្រគល់ចលនវត្ថុ"។[១៦] សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតត្រូវសំដៅដល់សិទ្ធិលើទ្រព្យសម្បត្តិក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និងសិទ្ធិលើបំណុល។[១៧]

-ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវាជាគោលការណ៍ត្រូវធ្វើឡើងតាមនីតិវិធីដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះនាវាដែរ។[១៨] ក៏ប៉ុន្តែតម្លៃរបស់នាវាមានកម្រិតប្រហាក់ប្រហែលទៅនឹងអចលនវត្ថុដែរ ហើយបញ្ញត្តិច្បាប់ចែងថាការធ្វើលទ្ធកម្មការបាត់បង់ការផ្លាស់ប្តូរនូវកម្មសិទ្ធិ លើនាវាត្រូវប្រកាសជាសាធារណៈដោយការចុះបញ្ជី។ នៅក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវាស្ថិតនៅ ពេលចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំមានសមត្ថកិច្ចជាតុលាការអនុវត្ត។[១៩]ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ត្រូវធ្វើឡើងតាមការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរដោយម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគជាទូទៅតុលាការអនុវត្តត្រូវមាននីតិវិធី។

## ១.៣.ការផ្អាក និងការលុបចោលការអនុវត្ត

### ១.៣.១.បណ្តឹងធ្វើឱ្យមានការជំនុំជម្រះសាជាថ្មី

បណ្តឹងធ្វើឱ្យមានការជំនុំជម្រះសាជាថ្មីគឺជាបណ្តឹងចំពោះសាលក្រម ឬសាលដីកាស្ថាពរ ដែលទាមទារឱ្យលុបចោលសាលក្រម ឬសាលដីកាស្ថាពរនោះ និងទាមទារឱ្យវិនិច្ឆ័យសាជាថ្មីនូវរឿងក្តីដែលបានចប់ដោយសាលក្រម ឬសាលដីកាស្ថាពរនោះរួចហើយ ដោយអះអាងនូវមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលច្បាប់បានកំណត់។ ការអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី គឺជាលក្ខខណ្ឌដើម្បីឱ្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះមានភាពត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះ ប្រសិនបើពុំអះអាងអំពីមូលហេតុណាមួយទេ

---

[១៥] មាត្រា ៥០៦ កថាខណ្ឌទី១ ការរឹបអូសសិទ្ធិលើបំណុលដោយផ្អែកលើឧបទេសកម្មលើវត្ថុ

[១៦] មាត្រា ៤០២ ការអនុវត្តចំពោះសិទ្ធិលើបំណុល

[១៧] មាត្រា ៤១៦ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

[១៨] មាត្រា ៤៥៤ កថាខណ្ឌទី១ នាវាដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា

[១៩] មាត្រា ៤៥៦ តុលាការអនុវត្ត

បណ្តឹងទាមទារឱ្យជំនុំជំម្រះសាជាថ្មីនោះនឹងត្រូវលើកចោល ។ ប្រសិនបើតុលាការយល់ឃើញថា មានមូលហេតុនៃការជំនុំជម្រះសាជាថ្មីដូចភាគីអះអាងនោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានមូលហេតុត្រឹមត្រូវ ហើយតុលាការនឹងចាប់ផ្តើមនីតិវិធីវិនិច្ឆ័យសាជាថ្មីអំពីរឿងក្តីដែលត្រូវបានបញ្ចប់។

កម្មវត្ថុនៃការទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរតាមរយៈបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីគឺសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ។ ចំពោះសេចក្តីសម្រេចដែលបានចេញនៅកណ្តាលទីនៃនីតិវិធីបណ្តឹងដូចជាសាលក្រមរបៀបជាដើម[២០] មិនអាចធ្វើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យបានទេ។ ប៉ុន្តែក្នុងករណីដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ចំពោះសេចក្តីសម្រេចដែលបានចេញនៅកណ្តាលទីនៃនីតិវិធីបណ្តឹងនោះភាគីអាចយកអង្គហេតុនោះមកធ្វើការអះអាងជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីបាន ចំពោះសាលក្រម ឬសាលដីកាចុងក្រោយដែលត្រូវបានធ្វើឡើងដោយផ្អែកលើសេចក្តីសម្រេច ដែលបានចេញនៅកណ្តាលទីនៃនីតិវិធីបណ្តឹងនោះ។ ម្យ៉ាងវិញទៀត ក្នុងចំណោមដីកាសម្រេចដែលអាចប្តឹងឧបាស្រ័យដោយបណ្តឹងជំទាស់ចំពោះដីកាសម្រេចដែលមានអានុភាពបញ្ចប់នីតិវិធីដូចជាដីកាសម្រេចលើកពាក្យបណ្តឹងចោល ដីកាសម្រេចដាក់ពិន័យស៊ីវិលចំពោះសាក្សីជាដើម អាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យបានដែលអនុលោមដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដែរ។ ចុងចម្លើយនៃការជំនុំជម្រះសាជាថ្មីគឺជាភាគីដែលឈ្នះបណ្តឹងក្នុងសាលក្រម ឬសាលដីកាស្ថាពរ។ ក្រោយពីពេលដែលភាគីនេះបានទទួលមរណភាពទៅជនដែលមានបំណងដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវយកប្រតិសិទ្ធិសកលជាចុងចម្លើយ។ ក្នុងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសកម្មភាពដែលនាំឱ្យខូចខាតផលប្រយោជន៍ ជនដែលមានបំណងដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវយកដើមចោទ និងចុងចម្លើយនៃសាលក្រម ឬសាលដីកាស្ថាពរមកធ្វើជាសហចុងចម្លើយ។

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខនៃតុលាការដែលបានចេញសាលក្រម ឬសាលដីកាស្ថាពរ ដែលជាកម្មវត្ថុនៃបណ្តឹងឧបាស្រ័យនោះ។ ប៉ុន្តែបណ្តឹងទាមទារឱ្យជំនុំជម្រះសារជាថ្មីចំពោះជាសាលក្រម ឬសាលដីកាស្ថាពរច្រើន ដែលចេញដោយតុលាការច្រើន ដែលមានថ្នាក់ខុសៗគ្នាអំពីរឿងក្តីតែមួយ តុលាការជាន់ខ្ពស់ត្រូវមានសមត្ថកិច្ចរួមបញ្ចូលនូវសាលក្រម និង សាលដីកាទាំងនោះ។

[២០] មាត្រា ១៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ១.៣.២.បណ្តឹងសាទុក្ខចំពោះសាលក្រម ឬសាលដីកា

បណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការកំពូល ចំពោះសាលក្រម ឬសាលដីកាចុងក្រោយ ដែលទាមទារឱ្យវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយ ចំពោះតែការអនុវត្តច្បាប់ប៉ុណ្ណោះ។ ជាគោលការណ៍បណ្តឹងសាទុក្ខ អាចធ្វើបានចំពោះសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ ក៏ប៉ុន្តែក្នុងករណីដែលមានការព្រមព្រៀងស្តីពីការប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូល និងក្នុងករណីដែលសាលាឧទ្ធរណ៍ជាតុលាការនៃការជំនុំជម្រះលើកទី១អាចប្តឹងសាទុក្ខដោយផ្ទាល់បានចំពោះសាលក្រម ឬសាលដីកានៃតុលាការជំនុំជម្រះលើកទី១។

ការជំនុំជម្រះនៃបណ្តឹងសាទុក្ខ គឺជាការជំនុំជម្រះលើអង្គច្បាប់ ដែលតុលាការកំពូលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬ សាលដីកាដើមចុងក្រោយ ក្នុងនាមជាតុលាការនៃបណ្តឹងសាទុក្ខ ហេតុដូច្នេះខុសគ្នាពីការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៅក្នុងការជំនុំជម្រះបណ្តឹងសាទុក្ខ តុលាការធ្វើការពិនិត្យមើលជាថ្មីម្តងទៀតទៅលើសាលក្រម ឬសាលដីកាដើមដោយផ្អែកទៅលើធនធានដែលត្រូវបានប្រើប្រាស់សម្រាប់វិនិច្ឆ័យនៅក្នុងសាលក្រម ឬសាលដីកាដើមនោះ។ តុលាការនៃបណ្តឹងសាទុក្ខមិនធ្វើការទទួលស្គាល់នូវអង្គហេតុឡើងវិញទេ គឺគ្រាន់តែវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុ ដោយផ្អែកលើការទទួលស្គាល់នូវអង្គហេតុដោយតុលាការដើម។ ក្នុងន័យនេះ ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបានចងដោយអង្គហេតុដែលត្រូវបានទទួលស្គាល់ជាស្ថាពរដោយស្របច្បាប់ក្នុងសាលក្រម ឬសាលដីកាដើម ប៉ុន្តែចំពោះចំណុចដែលតុលាការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន មិនមានអានុភាពចងឡើយ។

### ១.៣.៣.បណ្តឹងឧទ្ធរណ៍ដែលភ្ជាប់ការផ្អាក និងលុបចោលការអនុវត្ត

បណ្តឹងឧទ្ធរណ៍គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១របស់សាលាដំបូង។ដូច្នេះបណ្តឹងឧទ្ធរណ៍អាចធ្វើឡើងបានតែ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១របស់សាលាដំបូងតែប៉ុណ្ណោះ។ ចំពោះសាលក្រមរបៀបមិនអាចប្តឹងឧទ្ធរណ៍ដោយឯករាជ្យបានឡើយ។ ក៏ប៉ុន្តែបណ្តឹងឧទ្ធរណ៍មិនត្រូវបានអនុញ្ញាតឱ្យធ្វើ ប្រសិនបើក្រោយពេលចេញសាលក្រមចុងក្រោយនោះ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថាមិនធ្វើការប្តឹងឧទ្ធរណ៍ទេ ប៉ុន្តែរក្សាទុកសិទ្ធិធ្វើបណ្តឹងសាទុក្ខផ្ទាល់ទៅតុលាការកំពូលតែម្តង ឬប្រសិនបើសាលក្រមនោះជាសាលក្រមចុងក្រោយនៃរឿងក្តីរដ្ឋប្បវេណី ឬរឿងក្តីពាណិជ្ជកម្មដែលមានតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើស៥លានរៀលទេនោះ។ម្យ៉ាងទៀតបណ្តឹងឧបាស្រ័យចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ ដែលបានចេញក្នុងនាមជាការសម្រេចសេ

ចក្តីនៃការជំនុំជម្រះលើកទី១អាចប្តឹងបានត្រឹមតែសាទុក្ខប៉ុណ្ណោះ។ ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តីមិនអាចប្តឹងឧទ្ធរណ៍ដោយឯករាជ្យតែឯកឯងបានឡើយ។

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល១ខែ ដោយគិតចាប់ពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃលិខិតសាលក្រមនៃការជំនុំជម្រះលើកទី១ ឬពីថ្ងៃដែលដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខត្រូវជូនដំណឹង។ ចំពោះសាលក្រមកំបាំងមុខ ប្រសិនបើអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ត្រូវគណនាដោយគិតចាប់ពីថ្ងៃដែលទទួលនូវការបញ្ជូននៃលិខិតសាលក្រមកំបាំងមុខ ក្នុងករណីដែលភាគីបានប្តឹងទាស់ ដោយគិតថាអាចប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះតែតុលាការលើកចោល ឬច្រានចោលពាក្យបណ្តឹងទាស់ នោះអាចមានករណីដែលមិនអាចប្តឹងឧទ្ធរណ៍បានដោយសារអំឡុងពេល១ខែបានកន្លងហួស ដោយគិតពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃលិខិតសាលក្រមកំបាំងមុខនោះ។

ហេតុដូច្នេះអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមកំបាំងមុខត្រូវគណនាដោយគិតពីថ្ងៃដែលទទួលការជូនដំណឹងអំពី ដីកាសម្រេចច្រានចោល ឬលើកចោលនូវពាក្យបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះ។

អំឡុងពេល១ខែនេះ មិនអាចពន្យាពេលបានឡើយ។ ក៏ប៉ុន្តែក្នុងករណីដែលភាគី ដែលមានសិទ្ធិប្តឹងឧទ្ធរណ៍មិនអាចប្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលនេះ ដោយមូលហេតុដែលមិនមែនជាកំហុសរបស់ខ្លួនទេ ភាគីនោះអាចបំពេញនូវសកម្មភាពបណ្តឹងពេលក្រោយបានក្នុងអំឡុងពេល១សប្តាហ៍ ក្រោយពីមូលហេតុនោះបានរលត់ហើយ។ ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ក្នុងករណីនេះភាគីគ្រាន់តែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាធម្មតា ក្នុងកំឡុងពេលមួយសប្តាហ៍គិតចាប់ពីថ្ងៃដែលនាំឱ្យខកខាននោះបានរលត់ និងភាគីត្រូវធ្វើការអះអាង និងបញ្ជាក់ដោយភស្តុតាងថាការមិនអាចធ្វើបណ្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលកំណត់នោះបាន មិនមែនដោយសារកំហុសរបស់ខ្លួនទេ ជាការគ្រប់គ្រាន់។

ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ ក្រៅពីឈ្មោះ និងអាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ភាគីត្រូវសរសេរនូវអត្តសញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី១និងសេចក្តីដែលប្តឹងឧបាស្រ័យចំពោះសាលក្រមនោះ។ ម្យ៉ាងវិញទៀតជាការល្អនៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ គួរតែសរសេរអោយបានក្បោះក្បាយអំពីមូលហេតុដែលទាមទារអោយលុបចោល ឬ អោយផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី១។

ប្រសិនបើមិនបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារនេះទេ អ្នកធ្វើបណ្តឹងឧទ្ធរណ៍ត្រូវដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរអំពីមូលហេតុនោះ ក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍នេះ។ ពាក្យបណ្តឹងឧទ្ធរណ៍នេះត្រូវដាក់ទៅតុលាការដើម ដែលបានធ្វើការជំនុំជម្រះ

លើកទី១ ។ ពេលដែលទទួលពាក្យបណ្តឹង ឧទ្ធរណ៍នេះតុលាការនៃការជំនុំជម្រះលើកទី១ ត្រូវផ្ញើរពាក្យបណ្តឹងឧទ្ធរណ៍នេះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងឧទ្ធរណ៍អោយបានឆាប់រហ័ស។

ពេលដែលបានទទួលពាក្យបណ្តឹងឧទ្ធរណ៍ហើយ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍នោះ ហើយប្រសិនបើពិនិត្យឃើញថាមានចំនុចខ្វះខាត តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបង្គាប់អោយភាគីធ្វើការកែតម្រូវនូវចំនុចខ្វះខាតទាំងនោះ។ បើទោះជាមានការបង្គាប់អោយកែតម្រូវក៏ដោយ តែដើមបណ្តឹងឧទ្ធរណ៍មិនព្រមកែតម្រូវទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះដោយដីកាសម្រេច។ ចំណុចនេះត្រូវយកមកអនុវត្តដូចគ្នានេះផងដែរក្នុងករណីដែលដើមបណ្តឹងឧទ្ធរណ៍មិនបានបង់ពន្ធ សម្រាប់ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះ។

ប្រសិនបើពាក្យបណ្តឹងឧទ្ធរណ៍នោះត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រឡាបញ្ជីត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍នោះទៅអោយចុងបណ្តឹងឧទ្ធរណ៍។ ពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើក្នុងអំឡុងពេលដែលកំណត់អោយធ្វើបណ្តឹងឧទ្ធរណ៍ទោះជាអំឡុងពេលដែលកំណត់អោយធ្វើបណ្តឹងឧទ្ធរណ៍នោះបានកន្លងផុតទៅហើយក៏ដោយក៏សាលក្រមដើមមិនចូលជាស្ថាពរដែរ។ នេះគេហៅថា "អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃការប្តឹងឧទ្ធរណ៍" ។ ប្រសិនបើសាលក្រមដើមមិនភ្ជាប់ជាមួយនឹងការប្រកាសអោយអនុវត្តជាបណ្តោះអាសន្ន[២១] អានុភាពអនុវត្តក៏មិនត្រូវកើតឡើងឡើយ[២២]។

ពេលដែលមានបណ្តឹងឧទ្ធរណ៍ ការចាត់ការនៃការទាមទារដែលបានជំនុំជម្រះក្នុងសាលក្រមដើមត្រូវផ្ទេរពីសាលាជំនុំជម្រះលើកទី ១ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍។ នេះគេហៅថា "អានុភាពនៃការផ្ទេរការជម្រះក្តីដោយបណ្តឹងឧទ្ធរណ៍"។ ដោយសារអានុភាពនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យអំពីការទាមទារនោះ។ ថ្វីបើដើមបណ្តឹងឧទ្ធរណ៍ ប្តឹងឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រមដើមក៏ដោយ ក៏"អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃការប្តឹងឧទ្ធរណ៍"និង "អានុភាពនៃការផ្ទេរការជម្រះក្តី" កើតមានឡើងចំពោះការទាមទារទាំងអស់ដែលបានសម្រេចនៅក្នុងសាលក្រមដើមដែរ។ នេះគេហៅថា "ភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍"។

ដូច្នេះនៅពេលមានបណ្តឹងឧទ្ធរណ៍ដោយហេតុថាសាលក្រមដើមត្រូវបានរារាំង នូវអានុភាពចូលជាស្ថាពរ ហើយសូម្បីតែផ្នែកដែលដើមបណ្តឹងឧទ្ធរណ៍បានឈ្នះក្តី ក៏ត្រូវបានបង្អាក់មិនអោយចូលជាស្ថាពរដែរនោះ ដើមបណ្តឹងឧទ្ធរណ៍ មិនអាចនឹងធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រមដើមបានទេ ប្រសិនបើមិនមានការប្រកាសអោយធ្វើការអនុវត្តជាបណ្តោះអាសន្ន ទៅលើផ្នែកដែលខ្លួនឈ្នះនៅក្នុងសាលក្រមទេនោះ។

[២១] មាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[២២] មាត្រា ១៩៥ ក្រមដដែល

ឧទាហរណ៍ថាដើមចោទបានប្តឹងមួយដោយរួមបញ្ចូលនូវការទាមទារអោយសងប្រាក់កំចីចំនួន១០លានរៀល និងការទាមទារអោយបញ្ជាក់អំពីកម្មសិទ្ធិនៃអចលនវត្ថុមួយហើយ ចុងចម្លើយបានដាក់បណ្តឹងតបដែលទាមទារអោយបញ្ជាក់ថា ខ្លួនមានកម្មសិទ្ធិលើអចលនវត្ថុដដែលនោះ ពេលនោះតុលាការសម្រេចទទួលស្គាល់សិទ្ធិលើបំណុល ១០លានរៀលរបស់ដើមចោទ តែច្រានចោលនូវការទាមទារអោយបញ្ជាក់កម្មសិទ្ធិលើអចលនវត្ថុរបស់ដើមចោទនោះ ហើយសម្រេចទទួលស្គាល់នូវការទាមទារនៃបណ្តឹងតបរបស់ចុងចម្លើយ។ ក្នុងករណីបែបនេះ ប្រសិនបើដើមចោទដាក់ពាក្យបណ្តឹងឧទ្ធរណ៍ដោយធ្វើឧបាស្រ័យចំពោះផ្នែក ដែលច្រានចោលនូវការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិរបស់ខ្លួន និងផ្នែកដែលទទួលស្គាល់ការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិរបស់ចុងចម្លើយ នោះសាលក្រមទាំងមូលដែលមានខ្លឹមសារបើចំណុចនោះនឹងត្រូវរារាំងនូវការចូលជាស្ថាពរ ហើយត្រូវផ្ទេរទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ជាលទ្ធផលដើមចោទ មិនអាចធ្វើការអនុវត្តសិទ្ធិទាមទារអោយចុងចម្លើយសងប្រាក់កម្ចី ដោយផ្អែកលើសាលក្រមដើមនោះទេ។

### ១.៣.៤.ការប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ

ភាគីដែលទទួលសាលក្រមកំបាំងមុខ ដោយសារតែការអវត្តមាននៅកាលបរិច្ឆេទ អាចទាមទារឱ្យតុលាការនៃបណ្តឹងថ្នាក់ជម្រះ ដដែល ឱ្យធ្វើការវិនិច្ឆ័យសាជាថ្មី ដោយបណ្តឹងទាស់បាន។ ក៏ប៉ុន្តែ បណ្តឹងទាស់អាចអនុញ្ញាតឱ្យដាក់បានតែក្នុងករណីដែលភាគីអវត្តមានដោយសារមានហេតុដែលមិនអាចព្យាករណ៍បានឬហេតុដែលមិនអាចជៀសវាងបាន។ ម្យ៉ាងទៀត បណ្តឹងទាស់នោះត្រូវដាក់ក្នុងអំឡុងពេល២សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃសាលក្រមកំបាំងមុខ ហើយពាក្យបណ្តឹងទាស់នេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

ក្នុងករណីដែលមានពាក្យបណ្តឹងទាស់ តុលាការត្រូវពិនិត្យនូវចំណុចដែលបានសរសេរក្នុងពាក្យបណ្តឹងទាស់ហើយប្រសិនបើមានចំណុចខ្វះខាត ត្រូវបង្គាប់ឱ្យភាគីដែលដាក់ពាក្យបណ្តឹងទាស់នោះកែតម្រូវហើយប្រសិនបើភាគីមិនបានកែតម្រូវទេ តុលាការត្រូវលើកបណ្តឹងទាស់នោះចោល ដោយដីកាសម្រេច។ ប្រសិនបើពាក្យបណ្តឹងទាស់គ្មានចំណុចខ្វះខាតទេ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងទាស់នោះទៅភាគីម្ខាងទៀត ហើយកំណត់កាលបរិច្ឆេទ ដើម្បីវិនិច្ឆ័យបណ្តឹងទាស់នោះ និងកោះហៅគូភាគី។

## ជំពូកទី២ លក្ខខណ្ឌទូទៅសម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

### ២.១.ការដាក់ពាក្យសុំ

ជាគោលការណ៍ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត ដោយធ្វើតាមពាក្យសុំរបស់ភាគី[២៣] ត្រង់ចំណុចនេះមានន័យថា ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលពុំមែនជានីតិវិធីដែលត្រូវចាប់ផ្ដើមឡើងដោយស្វ័យប្រវត្តិដោយគ្មានពាក្យសុំបានទេ ហើយការចាប់ផ្តើមនីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនេះ គឺបានបញ្ជាក់ថានីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជានីតិវិធីឯករាជ្យពីនីតិវិធីបណ្តឹង។ ពាក្យសុំអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ។

នៅត្រង់ចំណុចនៃការសរសេរពាក្យសុំអនុវត្តដោយបង្ខំត្រូវធ្វើឡើង តាមមាត្រា៣៤៩ កថាខណ្ឌទី២នៃក្រមនីតិវិធីរដ្ឋប្បវេណីនិងមាត្រា៤០៣។ យោងតាមមាត្រា៣៤៩ កថាខណ្ឌទី២ ចំណុចដែលត្រូវសរសេរសុំសំខាន់ៗមានៈ

-ឈ្មោះ ឬ នាមករណ៍និងអាស័យដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ឈ្មោះ នេះសំដៅដល់ឈ្មោះរបស់រូបវន្តបុគ្គល ឬឯនាមករណ៍វិញ សំដៅដល់ឈ្មោះរបស់នីតិបុគ្គល

-សញ្ញាណនៃលិខិតអនុវត្តសំដៅដល់ប្រភេទនៃលិខិតអនុវត្ត វាអាចជាសេចក្តីសម្រេចរបស់តុលាការ និងកំណត់ហេតុផ្សេងៗតាមផ្លូវតុលាការដែលមានអានុភាព ដូចសេចក្តីសម្រេចរបស់តុលាការឬលិខិតយថាភូតដែលធ្វើឡើងដោយសារការី ឬសេចក្តីសម្រេចរបស់មជ្ឈត្តករជាដើម[២៤]

-ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់នូវសញ្ញាណនៃលិខិតអនុវត្ត។ ប្រសិនលិខិតអនុវត្តជាសាលក្រម ឬសាលដីកា ម្ចាស់បំណុលនៃការអនុវត្តគប្បីសរសេរលេខ កាលបរិច្ឆេទ និង តុលាការដែលចេញសាលក្រម ឬសាលដីកានោះ

-សេចក្តីស្នើសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។ តាមការអនុវត្តបង្ខំដោយផ្ទាល់នេះជាប្រភេទនៃការអនុវត្តដោយបង្ខំ ដែលខ្លឹមសារនៃលិខិតអនុវត្តមានគោលបំណងឲ្យកូនបំណុលនៃការអនុវត្តសងជាប្រាក់។

ចំពោះការអនុវត្តជំនួសគឺជាវិធាននៃការអនុវត្តដោយបង្ខំដែលខ្លឹមសារនៃលិខិតអនុវត្ត ដោយបង្ខំឲ្យកូនបំណុលនៃការអនុវត្តធ្វើសកម្មភាពណាមួយ ហើយសម្មភាពនេះអាចឲ្យតតិយជនធ្វើជំនួសកូនបំណុលនៃ

---

[២៣] មាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[២៤] មាត្រា ៣៥០ ក្រមដដែល

ការអនុវត្តបាន។ ការអនុវត្តប្រភេទនេះ ត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចអនុញ្ញាតឲ្យម្ចាស់បំណុលនៃការអនុវត្តឲ្យតតិយជនបំពេញសម្មភាពនោះជំនួស ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត[២៥]

ចំណែកឯវិធានអនុវត្តដោយប្រយោលវិញគឺជាវិធាននៃការអនុវត្តដោយបង្ខំដែលឲ្យកូនបំណុលនៃការអនុវត្តធ្វើឬមិនធ្វើសកម្មភាព អ្វីមួយក៏អាចធ្វើបានតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឲ្យកូនបំណុលនៃការអនុវត្តបង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ចទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ស្របទៅតាមអំឡុងពេលដែលទទួលស្គាល់ថាសមរម្យដើម្បីអនុវត្តកាតព្វកិច្ច[២៦]។

-សញ្ញាណនៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំក្នុងករណីដែលសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ សញ្ញាណនៃទ្រព្យសម្បត្តិនេះម្ចាស់បំណុលនៃការអនុវត្តត្រូវបញ្ជាក់ពីអាស័យដ្ឋានអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តឲ្យបានច្បាស់លាស់

-ខ្លឹមសារនៃសេចក្ដីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឲ្យអនុវត្តដោយបង្ខំតាមការអនុវត្តដោយជំនួស ឬវិធានបង្ខំដោយប្រយោល

-ចំនួននៃសិទ្ធិលើបំណុល និងបញ្ជាក់អំពីកូនបំណុលទី៣។

### ២.១.១ លិខិតអនុវត្ត

លិខិតអនុវត្ត គឺជាឯកសារមួយដែលបានបញ្ជាក់អំពីសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិកណាមួយជាក់លាក់ដែលបានកំណត់នៅក្រោមនីតិឯកជនហើយដោយផ្អែកលើឯកសារនេះ ច្បាប់ផ្ដល់ឱ្យនូវអំណាចបង្ខំឱ្យអនុវត្ត ដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិនោះតាមរយៈការអនុវត្តដោយបង្ខំ។ ខ្លឹមសារនិង វិធីនៃការអនុវត្តដោយបង្ខំត្រូវកំណត់ដោយផ្អែកទៅលើលិខិតអនុវត្ត។ ខ្លឹមសារនិងវិធីនៃការអនុវត្តដោយបង្ខំអាចត្រូវបានកម្រិត ឬបន្ថែមដោយរូបមន្តអនុវត្ត។

លិខិតអនុវត្តរួមមានជាចម្បងដូចជាសេចក្ដីសម្រេចរបស់តុលាការ និងកំណត់ហេតុផ្សេងៗតាមផ្លូវតុលាការដែលមានអានុភាពដូចសេចក្ដីសម្រេចរបស់តុលាការ។ ក្រៅពីនេះមានលិខិតយថាភូតដែលធ្វើឡើងដោយសារការីជាដើម។

[២៥] មាត្រា ៥២៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[២៦] មាត្រា ៥២៨ កថាខណ្ឌទី១ នៃក្រមដដែល

ប្រភេទលិខិតអនុវត្តដែលអាចឲ្យម្ចាស់បំណុអនុវត្តដោយបង្ខំបានគឺមាន៖

១. សាលក្រមឬសាលដីកាង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ៖ សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលចេញដោយតុលាការនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានទទួលស្គាល់ថាជាលិខិតអនុវត្ត។ ក្នុងចំណោមសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ មានតែសាលក្រមឬសាលដីកាដែលបង្គាប់ឲ្យផ្តល់តាវការលិកតែប៉ុណ្ណោះដែលមានអានុភាពអនុវត្ត។ ទោះបីជាក្នុងករណីដែលសាលក្រមឬសាលដីកាដែលពាក់ព័ន្ធគឺជាសាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកក៏ដោយប្រសិនបើការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបានអាស្រ័យដោយចរិតលក្ខណៈនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកនោះសាលក្រម ឬសាលដីកានោះមិនមានអានុភាពអនុវត្តទេ។

២.សាលក្រមឬសាលដីកាចុងក្រោយដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន៖ ស្រដៀងគ្នាទៅនឹងករណីនៃសាលក្រម ឬសាលដីកាដែលបានចូលជាសាពរដែរ ដោយសារថាការអនុវត្តដោយបង្ខំដែលផ្អែកលើសាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវការលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តដោយបង្ខំនឹងធ្វើឲ្យមានការវិត្ត ទៅដល់ការសម្រេចនូវសិទ្ធិទាមទារជាស្ថាពរ ដូច្នេះការសម្រេចសិទ្ធិនេះ មិនមានលក្ខណៈបណ្តោះអាសន្នទេ។

៣.ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក៖ជាគោលកាណ៍ដីកាសម្រេចមានអនុភាពភ្លាមបន្ទាប់ពីបានធ្វើការជូនដំណឹង។ ប្រសិនបើដីកាសម្រេចនោះគឺជាដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក ដីកាសម្រេចនោះត្រូវមានអានុភាពអនុវត្ត។

ឧទាហរណ៍៖ ដូចជាដីកាសម្រេចបង្គាប់ឲ្យបង់ជាមុននូវសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តជំនួស[២៧] ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ដើម្បីធានាការនូវការអនុវត្តកាតព្វកិច្ចនៅក្នុងវិធានដោយប្រយោល[២៨]។

៤.ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន៖ ប្រសិនបើកូនបំណុលមិនដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងពេល២សប្តាហ៍ បន្ទាប់ពីថ្ងៃទទួលការបញ្ជូន ដីកាសម្រេចដាស់តឿនឬប្រសិនបើដីកាសម្រេចដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនបានចូលជាស្ថាពរ នោះការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន នឹងត្រូវបានភ្ជាប់ទៅនឹងដីកាសម្រេចដាស់តឿនហើយដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយ នឹងការប្រកាសឲ្យអនុវត្តដោយបណ្តោះអាសន្ននោះ នឹងក្លាយជាលិខិអនុវត្ត។

[២៧] មាត្រា ៥២៧ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[២៨] មាត្រា ៥២៨ កថាខណ្ឌទី១ ក្រមដដែល

៥.ការចាត់ចែងរបស់ក្រឡាបញ្ជី ដែលកំណត់អំពីចំនួនប្រាក់ប្រដាប់ក្តី៖ បន្ទាប់ពីតុលាការបានវិនិច្ឆ័យអំពីភាគនិងបន្ទុកប្រាក់ប្រដាប់ក្តីហើយ ចំនួនទឹកប្រាក់លម្អិតត្រូវកំណត់ដោយក្រឡាបញ្ជីនៃសាលាដំបូងតាមពាក្យសុំរបស់ភាគី។ ភាគីម្ខាងអាចធ្វើការអនុវត្តដោយឲ្យភាគីម្ខាងទៀតសងប្រាក់ប្រដាប់ក្តី ដោយយកការចាត់ចែងរបស់ក្រឡាបញ្ជីនេះធ្វើជាលិខិតអនុវត្ត។

៦.លិខិតយថាភូតដែលធ្វើឡើងដោយសារការី៖ លិខិតយថាភូតដែលធ្វើឡើងដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់មានកំណត់ ហើយដែលនៅក្នុងលិខិតនោះបានបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។

៧.សាលក្រម ឬសាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ៖ ប្រសិនបើសាលក្រម ឬសាលដីការបស់តុលាការបរទេស បានបំពេញគ្រប់ល័ក្ខខ័ណ្ឌមួយចំនួនសាលក្រមឬសាលដីកាបរទេសនោះ នឹងត្រូវបានអនុវត្តទទួលស្គាល់នូវអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការកម្ពុជាទើបអាចធ្វើការអនុវត្តបាន។

៨.សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ៖នីតិវិធីមជ្ឈត្តកម្មគឺជានីតិវិធីនៃការដោះស្រាយវិវាទជំនួសនីតិវិធីបណ្តឹង ហើយសេចក្តីសម្រេចមជ្ឈត្តករដែលជាលទ្ធផលនៃនីតិវិធីនេះមានអានុភាពចងចំពោះភាគីដូចសាលក្រម ឬសាលដីកាស្ថាពរដែរ។ ប៉ុន្តែដើម្បីធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសេចក្តីសម្រេចមជ្ឈត្តករ ទោះបីជាសេចក្តីសម្រេចមជ្ឈត្តករក្នុងប្រទេសក៏ដោយ ឬបរទេសក៏ដោយ ត្រូវទទួលដីកាសម្រេចអនុវត្តរបស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា ។

ភាគីត្រូវដាក់ឯកសារដូចខាងក្រោមៈ

-ច្បាប់ដើមនៃសេចក្តីសម្រេចមជ្ឈត្តករដែលត្រូវបានបញ្ជាក់ដោយត្រឹមត្រូវឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ។

-ច្បាប់ដើមនៃកិច្ចសន្យាមជ្ឈត្តកម្ម ឬឯកសារចម្លងនៃកិច្ចសន្យានោះដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ។

ពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចបជ្ឈត្តករក្នុងប្រទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើកន្លែងរបស់កូនក្តីនៃការអនុវត្ត[២៩]។ ចំពោះពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបរទេសត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍។

[២៩] មាត្រា ៣៥៣ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

៩.កំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរៈកំណត់ហេតុនៃការទទួលស្គាល់ការទាមទារ និងកំណត់ហេតុនៃការសះជាតាមផ្លូវតុលាការសុទ្ធតែត្រូវបានរាប់ចូលជាកំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរ។

១០.លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគៈ

- សាលក្រម ឬសាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬលិខិតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរនោះ។ នៅក្នុងករណីកិច្ចសន្យាប្រាតិភោគដែលធ្វើឡើងដោយឯកជន និងឯកជន ត្រូវបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគដោយតុលាការ
- លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ បើកិច្ចសន្យាប្រាតិភោគ ដែលធ្វើឡើងដោយសារការីការបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិប្រាតិភោគត្រូវធ្វើឡើងដោយសារការី។

### ២.១.២.រូបមន្តអនុវត្ត

ជាទូទៅស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកទៅលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។ អត្ថិភាពនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត គឺជាល័ក្ខខ័ណ្ឌទាមទារសម្រាប់ការអនុវត្តដោយបង្ខំ។ ម្យ៉ាងវិញទៀត ប្រសិនបើមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្តហើយ នោះស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំដោយមិនចាំបាច់ពិនិត្យពិចារណាលើខ្លឹមសារនៃលិខិតអនុវត្តនោះទេ។

ហេតុនេះហើយ ទោះបីជាឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តខុសគ្នាពីលិខិតអនុវត្តច្បាប់ដើម ឬបើប្រសិនបើរូបមន្តអនុវត្តនោះត្រូវបានផ្តល់ដើម្បីជាផលប្រយោជន៍ ឬ ទៅឲ្យបុគ្គលណាម្នាក់ដែលពុំមានលក្ខណៈជាភាគីនៃការអនុវត្តដោយបង្ខំក៏ដោយ ឬ ទោះបីជាលិខិតអនុវត្តនោះបាត់បង់អានុភាពក៏ដោយ ក៏ការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះ នៅតែជាការអនុវត្តស្របតាមច្បាប់ស្តីពីការអនុវត្តដោយបង្ខំដែរ។

រូបមន្តអនុវត្ត គឺជាលិខិតដែលបញ្ជាក់ជាផ្លូវការនូវអត្ថិភាព និងអត្ថន័យនៃអំណាចបង្ខំឲ្យអនុវត្ត នៃលិខិតអនុវត្ត ដែលធ្វើឡើងដោយក្រឡាបញ្ជី ឬសារការី សំរាប់ភ្ជាប់បន្ថែមជាមួយលិខិតអនុវត្ត។

ជាគោលការណ៍ ទោះបីជាមានលិខិតអនុវត្តប្រភេទណាមួយក៏ដោយ ដើម្បីអាចដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគបានម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលបាននូវការផ្តល់រូបមន្តអនុវត្តសិនជានិច្ច។ ប៉ុន្តែករណីលើកលែង ប្រសិនបើលិខិតអនុវត្តគឺជាសាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច

ដែលចូលជាស្ថាពរ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ឬ ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ននោះពុំចាំបាច់មានរូបមន្តអនុវត្តទេ[៣០]។

### ២.១.២.១.ពាក្យសុំរូបមន្តអនុវត្ត

ការផ្តល់រូបមន្តអនុវត្តត្រូវបានធ្វើឡើងដោយក្រឡាបញ្ជីឬសារការី ទៅតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ក្នុងករណីដែលលិខិតអនុវត្តគឺជាសាលក្រម ឬសាលដីកា ស្ថាប័នដែលមានសិទ្ធិអំណាចក្នុងការផ្តល់រូបមន្តអនុវត្តគឺក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនៃបណ្តឹងដែលនាំទៅដល់ការចេញសាលក្រម ឬសាលដីកានោះ[៣១]។ តែក្នុងករណីដែលលិខិតអនុវត្តគឺជាលិខិតបញ្ជាក់អនុវត្តសារការីដែលរក្សាទុកនូវច្បាប់ដើមនៃលិខិតអនុវត្តនៃលិខិតបញ្ជាក់នោះគឺជាស្ថាប័នផ្តល់រូបមន្តអនុវត្ត[៣២]។

ពាក្យសុំរូបមន្តអនុវត្តត្រូវធ្វើឡើងដោយលិខិតជាលាយល័ក្ខអក្សរ ដែលត្រូវសរសេរចំណុចដូចខាងក្រោមៈ[៣៣]

-ឈ្មោះឬនាមករណ៍និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្តនិងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

-សញ្ញាណនៃលិខិតអនុវត្ត

-ហេតុការណ៍ និងមូលហេតុ បើការទាមទារឲ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងចំពោះបុគ្គលផ្សេង ក្រៅពីភាគីដែលត្រូវសរសេរឡើងនៅលើលិខិតអនុវត្តធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តក្រឡាបញ្ជី ឬសារការីត្រូវធ្វើការស្រាវជ្រាវអំពីអត្ថិភាពនៃល័ក្ខខ័ណ្ឌទាមទារនានាសម្រាប់ការផ្តល់រូបមន្តអនុវត្ត និងការធ្វើការសម្រេចដោយឯករាជ្យ និងដោយឆន្ទានុសិទ្ធិថាតើគួរផ្តល់រូបមន្តអនុវត្តតាមពាក្យសុំឬមិនផ្តល់។ ក៏ប៉ុន្តែដើម្បីផ្តល់រូបមន្តពិសេស ក្រឡាបញ្ជីត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅសិន[៣៤] ។

### ២.១.២.២.ការសរសេររូមមន្តអនុវត្ត

ការផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែមនៅផ្នែកក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដោយក្រឡាបញ្ជី ឬសារការី នូវចំណុចនីមួយៗដូចខាងក្រោម៖

---

[៣០] មាត្រា ៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ ចំណុច ក ដល់ គ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[៣១] មាត្រា ៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[៣២] មាត្រា ៣៥៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមដដែល

[៣៣] មាត្រា ៣៥៥ នៃក្រមដដែល

[៣៤] មាត្រា ៣៥៦ កថាខណ្ឌទី៤ នៃក្រមដដែល

-បុគ្គលដែលអាចទាមទារឲ្យធ្វើការអនុវត្តដោយបង្ខំបានដោយលិខិតអនុវត្តនោះនិងភាគីម្ខាងទៀត។

-ហេតុការណ៍ ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តពិសេស។

-ទំហំដែលអាចអនុវត្តដោយបង្ខំបាន ហើយបានផ្តល់រូបមន្តអនុវត្តតែមួយផ្នែកនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត។ នៅពេលសរសេរបន្ថែមនូវរូបមន្តអនុវត្តនៅក្នុងឯកសារចម្លងយថាភូតនៃលិខិតអនុវត្តក្រឡាបញ្ជី ឬសារការីត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្តដោយសរសេរថ្ងៃខែឆ្នាំនៃការផ្តល់[៣៥]។

ជាគោលការណ៍ការផ្តល់រូបមន្តអនុវត្ត មិនចាំបាច់ជូនដំណឹងទៅកូនបំណុលនៃការអនុវត្តទេ។ ក៏ប៉ុន្តែក្នុងករណីដែលផ្តល់រូបមន្តអនុវត្តនៅក្នុងលិខិតចម្លងយថាភូតច្រើនច្បាប់នៃលិខិតអនុវត្តឬរូបមន្តពិសេសត្រូវជូនដំណឹងអំពីហេតុនោះទៅកូនបំណុលនៃការអនុវត្តឲ្យបានដឹង[៣៦]។

### ២.១.៣.ពន្ធ និងសោហ៊ុយសម្រាប់ការអនុវត្ត

សោហ៊ុយសម្រាប់ការអនុវត្ត គឺជាផ្នែកដ៏សំខាន់ដែលមិនអាចខ្វះបាន នៅពេលចាប់ផ្តើមការអនុវត្តដោយបង្ខំនៅពេលដែលពាក្យសុំឲ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត អ្នកដែលដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលតុលាការអនុវត្តកំណត់ ថាជាសោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ ។

បើអ្នកដាក់ពាក្យសុំមិនបានបង់ជាមុនទេ តុលាការអនុវត្តអាចលើកចោលពាក្យសុំអនុវត្តដោយបង្ខំ ឬអាចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន[៣៧]។ ចំពោះអាជ្ញាសាលាវិញអាចធ្វើការអនុវត្តបានដូចតុលាការអនុវត្តបានផងដែរនូវការលើកចោលពាក្យសុំអនុវត្តដោយបង្ខំ ឬអាចលុបចោលនីតិវិធីនៃការអនុវត្តកាលបើអ្នកដាក់ពាក្យសុំមិនព្រមបង់សោហ៊ុយជាមុន[៣៨]។ ជាគោលការណ៍សោហ៊ុយនៃការអនុវត្តជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត។ សោហ៊ុយនៃការអនុវត្តសំដៅទៅលើពន្ធដាក់ពាក្យសុំ សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ និង សោហ៊ុយភាគី។

#### ២.១.៣.១.ពន្ធដាក់ពាក្យសុំ

ពន្ធដាក់ពាក្យសុំគឺ ជាព័ន្ធដែលម្ចាស់បំណុលនៃការអនុវត្តត្រូវបង់នៅពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅស្ថាប័នអនុវត្ត។ពន្ធដាក់ពាក្យសុំប្រែប្រួលអាស្រ័យទៅតាមស្ថាប័នអនុវត្តដែលទទួលពាក្យសុំនោះ។

---

[៣៥] មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[៣៦] មាត្រា ៣៥៨ កថាខណ្ឌទី២ និង៣៦០ វាក្យខណ្ឌទី២ ក្រមដដែល

[៣៧] មាត្រា ៣៧៥ នៃក្រមដដែល

[៣៨] ប្រការ ១៥ ស្តីពី ប្រកាសមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាឆ្នាំ២០០៧

ក្នុងករណីដែលពាក្យសុំត្រូវទទួលដោយតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ១០០០០រៀលទៅតុលាការ[៣៩]។ ចំណែកឯពន្ធដាក់ពាក្យសុំទៅអាជ្ញាសាលាវិញត្រូវបង់ចំនួន៥០០០រៀល[៤០]។

នៅក្នុងការចុះអនុវត្តជាក់ស្តែង ការយកពន្ធលើពាក្យសុំលើការអនុវត្តដោយបង្ខំធ្វើឡើងនៅក្នុងរដ្ឋបាលតុលាកា។ ពោលគឺនៅពេលដែលមានពាក្យសុំអនុវត្តដោយបង្ខំម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់មកខាងរដ្ឋបាលតុលាការ នៅពេលណាដែលរដ្ឋបាលតុលាការពិនិត្យឃើញថាសុំណុំរឿងអនុវត្តនោះជាសមត្ថកិច្ចរបស់តុលាការអនុវត្តត្រូវបញ្ជូនទៅតុលាការអនុវត្ត បើសុំណុំរឿងណាដែលជាសមត្ថកិច្ចរបស់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវបញ្ជូនទៅខាងសាលាដំបូងរាជធានីភ្នំពេញ។ ហើយចំពោះការបង់ពន្ធលើពាក្យសុំអនុវត្តនៅតុលាការរាជធានីភ្នំពេញវិញជាទូទៅយក១០០០០រៀល។

បើយើងពិនិត្យទៅលើស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណី ការបង់ពន្ធដាក់ពាក្យសុំអនុវត្តត្រូវបង់ដាច់ដោយឡែកពីគ្នារវាងតុលាការអនុវត្ត និងអាជ្ញាសាលាពាលគឺស្ថាប័នទាំងពីរនេះមានរដ្ឋបាលដាច់ដោយឡែកពីគ្នា។ ទាំងនេះជាបញ្ហាដែលអាចឲ្យសាធារណៈជនទូទៅមានការយល់ច្រលំថាស្ថាប័នអាជ្ញាសាលា និងស្ថាប័នតុលាការគឺជាស្ថាប័នតែមួយពីព្រោះកាលគាត់មកដាក់ពាក្យបណ្តឹងអង្គសេចក្តីបង់ពន្ធដាក់ពាក្យសុំក៏ដាក់នៅនឹងរដ្ឋបាលតុលាការ ហើយនៅពេលដែលដាក់ពាក្យសុំអនុវត្ត និងបង់ពន្ធដាក់ពាក្យសុំ ក៏ដាក់នៅនឹងរដ្ឋបាលតុលាការដដែល។ ទាំងនេះហើយដែលខុសពីគោលការណ៍នៃស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលថាអាជ្ញាសាលាជាស្ថាប័នមួយឯករាជ្យដាច់ពីតុលាការ។

#### **២.១.៣.២.សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ**

សំដៅលើចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំបាច់សម្រាប់ក្នុងការបញ្ជូនឯកសារ ឬ ធ្វើសកម្មភាពផ្សេងទៀត ដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ[៤១] ។ តែបើយើងពិនិត្យមើលតាមសេចក្តីប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាវិញ ដូចជាបានរៀបរាប់ពីប្រភេទសោហ៊ុយនេះលម្អិតពាក់ព័ន្ធនឹងសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ។ នៅក្នុងសេចក្តីប្រកាសនេះបានចែងថាអ្នកដាក់ពាក្យសុំទទួលបន្ទុកក្នុងការបង់ឬសងនូវសោយហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាត្រូវធ្វើតាមពាក្យសុំនេះ។

[៣៩] មាត្រា ៣៧២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[៤០] ប្រការ ១៣ ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឆ្នាំ២០០៧

[៤១] មាត្រា ៣៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

សោហ៊ុយទាំងនោះមានដូចជាៈ

-សោហ៊ុយសំរាប់ធ្វើដំណើរនិងស្នាក់នៅសម្រាប់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា

-សោហ៊ុយសម្រាប់ផ្ញើឯកសារ ទូរស័ព្ទ និងទូរសារ ជាអាទិ៍

-សោហ៊ុយសម្រាប់ជូនដំណឹងជាសាធារណៈ

-សោហ៊ុយធ្វើដំណើរប្រាក់ឧបត្ថម្ភប្រចាំថ្ងៃនិងសោហ៊ុយសម្រាប់ស្នាក់នៅសម្រាប់អ្នកអង្កេតការណ៍ដែលបានកំណត់នៅក្នុងមាត្រា ៣៣៩ នៃក្រមនីតិវិធីរដ្ឋវេណី

-កម្រៃសម្រាប់អ្នកបច្ចេទេស ឬកម្មករ

-សោហ៊ុយសម្រាប់ការដឹកជញ្ជូន ថែរក្សា និងគ្រប់គ្រងវត្ថុ

-សោហ៊ុយសម្រាប់ការប្រមូលផល

-សោហ៊ុយសម្រាប់ការទទួលលិខិតបញ្ជាក់ពីស្ថាប័នសាធារណៈ

-សោហ៊ុយសម្រាប់ថត និងផ្ដិតរូបថត ដើម្បីថតស្ថានភាពបច្ចុប្បន្ននៃវត្ថុ

-សោហ៊ុយសម្រាប់ធ្វើលិខិតបញ្ជាក់ដែលកំណត់នៅក្នុងកថាខណ្ឌទី៩នៃមាត្រ៤១៣

-សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃសោហ៊ុយសម្រាប់ស្នាក់នៅកម្រៃសម្រាប់អ្នកវាយតម្លៃ

-សោហ៊ុយធ្វើលិខិតរាយការណ៍ដែលត្រូវដាក់ជូនទៅតុលាការអនុវត្ត

-សោហ៊ុយចាំបាច់សម្រាប់ការលក់តាមនីតិវិធីផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់[៤២]។

**២.១.៣.៣.សោហ៊ុយភាគី**

សំដៅលើសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ និងសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំដែលតុលាការទទួលស្គាល់ចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំត្រូវចាត់ទុកថាជាសោហ៊ុយភាគី[៤៣]។ ការកំណត់សោហ៊ុយដោយតុលាការនេះគឺជាការកំណត់ទូទៅតែម្តង។

ម្ចាស់បំណុលនៃការអនុវត្តឬ កូនបំណុលនៃការអនុវត្តត្រូវចេញឲ្យអ្នកផ្សេងក្រៅពីតុលាការអនុវត្ត និងអាជ្ញាសាលាដើម្បីធ្វើការអនុវត្តដោយបង្ខំ។តាមអនុវត្តជាក់ស្តែងប្រភេទសោហ៊ុយប្រភេទនេះម្ចាស់បំណុលនៃការអនុវត្តធ្វើការរ៉ាប់រងទទួលខុសត្រូវដោយខ្លួនឯង ឬក៏បង់សរុបទៅខាងស្ថាប័នអនុវត្តតែម្តង រួចខាងស្ថាប័នអនុវត្តជាអ្នកចេញរ៉ាប់រងលើថ្លៃដំណើរការនីតិវិធីទាំងអស់។

[៤២] ប្រការ ១៤ នៃសេចក្តីប្រកាសស្តីពី មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាឆ្នាំ ២០០៧

[៤៣] មាត្រា ៣៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ជំពូកទី៣ ការអនុវត្តដោយបង្ខំសិទ្ធិលើបំណុលមានកម្មវត្ថុជាការសងប្រាក់

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជាការអនុវត្តដោយបង្ខំដែលធ្វើឡើងតាមវិធីដែលតុលាការអនុវត្តរឹបអូសយកសិទ្ធិលើបំណុលរបស់កូនបំណុលនៃការអនុវត្ត ចំពោះកូនបំណុលទី៣ ដើម្បីជួយសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់របស់ម្ចាស់បំណុលនៃការអនុវត្តដែលសិទ្ធិទាមទារនេះមានកំណត់នៅក្នុងលិខិតអនុវត្ត។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានពីរប្រភេទគឺ សិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងប្រាក់ និងសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការប្រគល់ចលនវត្ថុ។

ជាទូទៅម្ចាស់បំណុលតែងតែចង់អោយកូនបំណុលរបស់ខ្លួន ធ្វើការអនុវត្តដោយស្ម័គ្រចិត្តជាជាងធ្វើការអនុវត្តដោយបង្ខំ។ តែទោះបីជាយ៉ាងណាក៏ដោយការចងបានរបស់ម្ចាស់បំណុលអាចជោគជ័យ ឬជួនកាលត្រូវបានបរាជ័យដោយសារតែកូនបំណុលមិនព្រមអនុវត្តដោយស្ម័គ្រចិត្ត។

ការចរចារនេះមិនមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទេ តែការអនុវត្តជាក់ស្តែងម្ចាស់បំណុល និងចៅក្រមតែងតែធ្វើការចរចារជាមុនជាមួយកូនបំណុល អោយកូនបំណុលធ្វើការអនុវត្តដោយស្ម័គ្រចិត្តតាមរយៈការចេញដីកាបង្គាប់អោយអនុវត្តដោយស្ម័គ្រចិត្តរបស់ចៅក្រម។ ករណីនេះយើងឃើញថាទទួលបានជោគជ័យផងដែរ ។ ទោះបីជាការចរចារនេះមិនមានចែងនៅក្នុងច្បាប់ណាមួយក៏ដោយតែការចរចារនេះវាជាគោលការណ៍គ្រឹះមួយនៅក្នុងនីតិរដ្ឋប្បវេណី ហើយគោលការណ៍នេះត្រូវបានគេហៅថា គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន[៩៤]។

បើគ្មានការអនុវត្តដោយស្ម័គ្រចិត្តទេ ទើបឈានដល់ការអនុវត្តដោយបង្ខំ ។ ករណីដែលកូនបំណុលមិនព្រមធ្វើការអនុវត្តដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលនៃការអនុវត្តមានកាតព្វកិច្ចស្រាវជ្រាវរកចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត គឺមិនមែនជាកាតព្វកិច្ចរបស់អាជ្ញាសាលាទេ[៩៥]។ ការជូនដំណឹងអនុវត្តដោយស្ម័គ្រចិត្តសំដៅលើការជូនដំណឹងអោយកូនបំណុលធ្វើការអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត តាមរយៈសេចក្តីសម្រេចអោយអនុវត្តដោយស្ម័គ្រចិត្តដែលធ្វើឡើយដោយអាជ្ញាសាលាដែលទទួលបន្ទុកសំណុំរឿងនោះ។

ការជូនដំណឹនេះមិនមានចែងនៅក្នុងក្រមនីតិវីធីរដ្ឋប្បវេណីឡើយ តែការអនុវត្តជាក់ស្តែងនៅសាលាដំបូងរាជធានីភ្នំពេញ គឺមានការជូនដំណឹងនេះ ហើយជួនកាលកូនបំណុលស្ម័គ្រចិត្តអនុវត្តដោយស្ម័គ្រចិត្តផងដែរ ។

[៩៤] មាត្រា ៣ ក្រមរដ្ឋប្បវេណី។

[៩៥] មាត្រា ៣៨៤ កថាខណ្ឌទី១ និង ទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ការជូនដំណឹងនេះត្រូវធ្វើឡើយជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន ដោយកំណត់អំឡុងពេលមួយជាក់លាក់សម្រាប់អោយកូនបំណុលធ្វើការអនុវត្តដោយស្ម័គ្រចិត្ត។

### ៣.១.ការដាក់ពាក្យសុំ

ម្ចាស់បំណុលនៃការអនុវត្តមានកាតព្វកិច្ចស្រាវជ្រាវរកសិទ្ធិលើបំណុលរបស់កូនបំណុលនៃការអនុវត្តដែលមានគឺមិនមែនជាកាតព្វកិច្ចរបស់តុលាការអនុវត្តនោះទេ ។

ដើម្បីអាចដាក់ពាក្យសុំ ម្ចាស់បំណុលនៃការអនុវត្តត្រូវរៀប ចំឯកសារដូចខាងក្រោម ៖

- លិខិតចម្លងយថាភូតនៃលិខិតអនុវត្ត។
- ឯកសារបញ្ជាក់ពីការចូលជាស្ថាពរនៃលិខិតអនុវត្ត
- រូបមន្តអនុវត្ត។
- ត្រូវសរសេរពាក្យសុំតាមមាត្រា មាត្រា ៤០៣ និងមត្រា ៣៤៩។

ពាក្យសុំអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ត្រូវដាក់ទៅតុលាការអនុវត្តដែលមានសមត្ថកិច្ចគឺសាលាដំបូង ដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលនៃការអនុវត្ត ។ បើគ្មានគឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលទី៣។ នៅក្នុងពាក្យសុំអនុវត្តចំពោះសិទ្ធិលើបំណុលក្រៅពីមាត្រា ៣៤៩គឺត្រូវសរសេរអំពីកូនបំណុលទី៣ ព្រមទាំងបញ្ជាក់អំពីសិទ្ធិលើបំណុលដែលត្រូវរឹបអូស[៤៦]។ ក្នុងករណីដែលសុំឲ្យអនុវត្តចំពោះផ្នែកណាមួយនៃសិទ្ធិលើបំណុល ត្រូវសរសេបញ្ជាក់ឲ្យបានច្បាស់លាស់នូវទំហំនៃការអនុវត្តនោះ។ ម្ចាស់បំណុលត្រូវបង់ពន្ធ ១០០០០ រៀល។

ចំណុចនៃការសរសេរពាក្យសុំអនុវត្តដោយបង្ខំត្រូវធ្វើឡើងតាមមាត្រា៣៤៩កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ យោងតាមមាត្រា៣៤៩កថាខណ្ឌទី២ចំណុចដែលត្រូវសរសេរសុំសំខាន់ៗមាន៖

- ឈ្មោះ ឬនាមករណ៍និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ឈ្មោះនេះសំដៅដល់ឈ្មោះរបស់រូបវន្តបុគ្គល ឬឯនាមករណ៍វិញ សំដៅដល់ឈ្មោះរបស់នីតិបុគ្គល។

- សញ្ញាណនៃលិខិតអនុវត្តសំដៅដល់ប្រភេទនៃលិខិតអនុវត្តវាអាចជាសេចក្ដីសម្រេចរបស់តុលាការនិងកំណត់ហេតុផ្សេងៗតាមផ្លូវតុលាការដែលមានអានុភាព ដូចសេចក្ដីសម្រេចរបស់តុលាការ ឬលិខិតយថាភូតដែលធ្វើឡើងដោយសារការី ឬសេចក្ដីសម្រេចរបស់ មជ្ឈត្តករជាដើម[៤៧] ។

[៤៦] មាត្រា ៤០៣ កថាខណ្ឌ២នៃក្រមនីតិវិធីរដ្ឋប្បវេណី

[៤៧] មាត្រា ៣៥០ ក្រមដដែល

ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់នូវសញ្ញាណនៃលិខិតអនុវត្ត។ ប្រសិនលិខិតអនុវត្តជាសាលក្រម ឬសាលដីកា ម្ចាស់បំណុលនៃការអនុវត្តគប្បីសរសេរលេខ កាលបរិច្ឆេទ និង តុលាការដែលចេញសាលក្រម ឬសាលដីកានោះ ។

- សេចក្តីស្នើសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួសឬវិធានបង្ខំដោយប្រយោលតាមការអនុវត្តបង្ខំដោយផ្ទាល់នេះជាប្រភេទនៃការអនុវត្តដោយបង្ខំ ដែលខ្លឹមសារនៃលិខិតអនុវត្តមានគោលបំណងឲ្យកូនបំណុលនៃការអនុវត្តសងជាប្រាក់។

ចំពោះការអនុវត្តជំនួស គឺជាវិធាននៃការអនុវត្តដោយបង្ខំដែលខ្លឹមសារនៃលិខិតអនុវត្ត ដោយបង្ខំឲ្យកូនបំណុលនៃការអនុវត្តធ្វើសកម្មភាពណាមួយ ហើយហើយសម្មភាពនេះអាចឲ្យតតិយជនធ្វើជំនួសកូនបំណុលនៃការអនុវត្តបាន។ ការអនុវត្តប្រភេទនេះត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចអនុញ្ញាតឲ្យម្ចាស់បំណុលនៃការអនុវត្តឲ្យតតិយជនបំពេញសម្មភាពនោះជំនួស ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត[៤៨]។

ចំណែកឯវិធានអនុវត្តដោយប្រយោលវិញគឺជា វិធាននៃការអនុវត្តដោយបង្ខំដែលឲ្យកូនបំណុលនៃការអនុវត្តធ្វើឬមិនធ្វើសកម្មភាពអ្វីមួយ ក៏អាចធ្វើបានតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឲ្យកូនបំណុលនៃការអនុវត្តបង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យ ដើម្បីធានាការអនុវត្តកាតព្វកិច្ចទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ស្របទៅតាមអំឡុងពេលដែលទទួលស្គាល់ថាសមរម្យដើម្បីអនុវត្តកាតព្វកិច្ច[៤៩]។

- សញ្ញាណនៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំក្នុងករណីដែលសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់សញ្ញាណនៃទ្រព្យសម្បត្តិនេះម្ចាស់បំណុលនៃការអនុវត្តត្រូវបញ្ជាក់ពីអាស័យដ្ឋាន អចលនវត្ថុរបស់កូនបំណុល នៃការអនុវត្តឲ្យបានច្បាស់លាស់។

- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឲ្យអនុវត្តដោយបង្ខំតាមការអនុវត្តដោយជំនួស ឬវិធានបង្ខំដោយប្រយោល។

### ៣.២.ការពិនិត្យពាក្យសុំ

ចៅក្រមម្នាក់ៗត្រូវទទួលបន្ទុកជាស្វ័យប្រវត្តិ។

---

[៤៨] មាត្រា ៥២៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[៤៩] មាត្រា៥២៨ កថាខណ្ឌទី១ នៃក្រមដដែល

នៅពេលទទួលបានពាក្យសុំ ចៅក្រមត្រូវពិនិត្យ ៖

- តើត្រូវសមត្ថកិច្ចឬទេ ?
- តើពាក្យសុំត្រឹមត្រូវតាមមាត្រា៣៤៩ និងមាត្រា ៤០៣ ឬទេ ?
- តើភាគីត្រឹមត្រូវដូចក្នុងលិខិតអនុវត្តឬទេ ?
- តើមានឯកសារភ្ជាប់គ្រប់គ្រាន់ដែរ ឬទេ?
- មានលិខិតអនុវត្ត មានលិខិតបញ្ជាក់ពីការចូលជាស្ថាពរ និងមានរូបមន្តអនុវត្ត មានលិខិតបញ្ជាក់សិទ្ធិតំណាងដែរឬទេ?
- តើបានបង់ពន្ធដាក់ពាក្យសុំឬទេ?
- តើបានបញ្ជូនលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្តជាមុនតាមមាត្រា៣៦០ ឬទេ?
- ការបង់សោហ៊ុយជាមុន?

តុលាការអនុវត្តដែលទទួលបន្ទុកសំណុំរឿងអនុវត្តដោយបង្ខំ បើពិនិត្យឃើញពាក្យសុំមិនត្រឹមត្រូវ តុលាការអនុវត្តត្រូវចេញដីកាសម្រេចបង្គាប់ឲ្យម្ចាស់បំណុលកែតម្រូវនូវចំណុចខ្វះក្នុងអំឡុងពេលសមរម្យ[៥០]។ ជាការអនុវត្តជាក់ស្តែងទុកពេលចំនួន០១ខែដល់ម្ចាស់បំណុលដើម្បីកែតម្រូវពាក្យសុំឲ្យបានត្រឹមត្រូវឡើងវិញ។ ការធ្វើសេចក្តីសម្រេចបង្គាប់ឲ្យម្ចាស់បំណុលកែតម្រូវពាក្យសុំរបស់តុលាការអនុវត្តធ្វើឡើងដោយដីកាសម្រេច។

ប៉ុន្តែ ក្នុងករណីពាក្យសុំដែលពុំបានបញ្ជាក់ច្បាស់លាស់ពីកម្មវត្ថុ ដែលនឹងត្រូវអនុវត្តដែលប្រធានសាលាដំបូងចាត់បញ្ជូនឲ្យតុលាការអនុវត្តជាអ្នកចាត់ការ នៅពេលម្ចាស់បំណុលកែតម្រូវហើយ តុលាការពិនិត្យឃើញថា ជាសមត្ថកិច្ចរបស់អាជ្ញាសាលា ករណីនេះជាក់ស្តែង តុលាការអនុវត្តធ្វើដីកាសម្រេចផ្ទេរសមត្ថកិច្ចទៅស្ថាប័នទទួលបន្ទុកកិច្ចការអាជ្ញាសាលា[៥១]។ បើផុតអំឡុងពេលដែលបានកំណត់ ក្នុងសេចក្តីសម្រេចបង្គាប់ឲ្យកែតម្រូវសម្រេចនោះ អ្នកដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំនៅតែមិនព្រមកែតម្រូវ ឬមានការយឺតយ៉ាវក្នុងការកែតម្រូវ ស្ថាប័នអនុវត្តអាចចេញសេចក្តីសម្រេចលើកចោលពាក្យសុំឲ្យអនុវត្តដោយបង្ខំបាន។ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំអំពីសេចក្តីសម្រេចដែលបានធ្វើឡើងនេះ។ តុលាការអនុវត្តចេញដីកាសម្រេចលើកចោលពាក្យសុំឲ្យអនុវត្តដោយបង្ខំប្រសិនបើអ្នកដាក់ពាក្យសុំពុំព្រមកែតម្រូវ ឬមានការយឺតយ៉ាវក្នុងការកែតម្រូវពាក្យសុំ។

[៥០] មាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[៥១] មាត្រា ១៨ នៃក្រមដដែល

## ៣.៣.ការរឹបអូសសិទ្ធិលើបំណុល

ក្រោយការពិនិត្យពាក្យសុំ ឃើញថាមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវហើយនោះ តុលាការអនុវត្ត បន្តនីតិវិធី។ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំគឺជាដីកាសម្រេចដំបូងដែល"ចាប់ផ្តើមលក់ដោយបង្ខំ" តុលាការអនុវត្តចេញក្នុងការចាប់ ផ្តើមនីតិវិធីលក់ដោយបង្ខំ។

នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលត្រូវចាប់ផ្តើម ដោយដីកាសម្រេចរឹបអូសរបស់ តុលាការអនុវត្ត ។ ជាគោលការណ៍ការ រឹបអូសអាចធ្វើបានចំពោះ រូបទ្រព្យ ឬ អរូបទ្រព្យទាំងអស់ដែលធ្លាក់ទៅ លើកូនបំណុលនៃការអនុវត្ត លើកលែងតែមានការកំណត់ពិសេសក្នុងច្បាប់ ។

សិទ្ធិលើបំណុលដែលមិនអាចរឹបអូសនោះមានប្រាក់បៀវត្សប្រាក់ឈ្នួល និងសិទ្ធិលើបំណុលដែល មានលក្ខណៈដូចជា ប្រាក់បៀវត្សផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត បន្ទាប់ពីកាត់ចេញនូវពន្ធអាករនិង ប្រាក់ធានារ៉ាប់រងសង្គមកិច្ច ដែលមានចំនួនដូចក្នុងចំណុច ក ដល់ ច ។ ទោះបីជាមានមាត្រា៣៨២ ក៏ដោយ តុលាការអនុវត្ត អាចលុបចោលដីកាសម្រេចទាំងអស់ឬ មួយផ្នែក ឬអាចចេញដីកាសម្រេចរឹបអូសសិទ្ធិលើ បំណុលទាំងអស់ឬមួយផ្នែកដែលហាមឃាត់នោះ ដោយពិចារណាលើជីវភាពនិងស្ថានភាពផ្សេងទៀតរបស់កូន បំណុល ឬម្ចាស់បំណុលតាមពាក្យសុំ។

បើមានស្ថានភាពផ្លាស់ប្តូរ តុលាការអាចផ្លាស់ប្តូរសេចក្តីសម្រេចរបស់ខ្លួនបានតាមពាក្យសុំ។ បើមាន ពាក្យសុំដូចខាងលើ តុលាការអនុវត្តអាចបង្គាប់ហាមឃាត់កូនបំណុលទី៣មិនឲ្យបង់ឬផ្តល់តាវកាលិកផ្សេង ទៀតដោយឲ្យដាក់ប្រាតិភោគ ឬមិនឲ្យដាក់ប្រាតិភោគបានរហូតដល់ដីកាសម្រេចនោះមានអានុភាព។ ដីកា សម្រេចលើកចោលពាក្យសុំឲ្យលុបចោលដីកាសម្រេចរឹបអូស ខាងលើអាចប្តឹងជំទាស់បាន។ ដីកាសម្រេចលុប ចោលដីកាសម្រេចរឹបអូស អាចប្តឹងជំទាស់បាន។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលត្រូវចាប់ផ្តើម ដោយដីកាសម្រេចរឹបអូសរបស់តុលាការ អនុវត្ត។នៅក្នុងដីកាសម្រេចតុលាការអនុវត្តត្រូវហាមឃាត់មិនឲ្យកូនបំណុលធ្វើការប្រមូលបំណុលឬចាត់ចែង ផ្សេងទៀតនិងហាមមិនឲ្យកូនបំណុលទី៣ សងបំណុលឲ្យកូនបំណុលនៃការអនុវត្ត។

ដីកាសម្រេចរឹបអូសត្រូវធ្វើឡើង ដោយមិនត្រូវសួរកូនបំណុលនៃការអនុវត្ត និង កូនបំណុលទី៣ទេ។ ដីកាសម្រេចរឹបអូសត្រូវបញ្ជូនទៅឲ្យកូនបំណុលនៃការអនុវត្ត និងកូនបំណុលទី៣។ ក្រឡាបញ្ជីត្រូវជូនដំណឹង អំពីការណ៍នោះ និងថ្ងៃខែ ឆ្នាំ នៃការបញ្ជូននោះទៅម្ចាស់បំណុលនៃការអនុវត្ត។

បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេង ទៀតដែលបានចុះបញ្ជី បានបង្កើតអានុភាពតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់

ឲ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី បញ្ជាក់ថាសិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ។ សេចក្តីសម្រេចអំពីពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសអាចប្តឹងជំទាស់បាន។

ទោះបីសិទ្ធិលើបំណុលមានតម្លៃលើសពីចំនួនទឹកប្រាក់នៃ សិទ្ធិទាមទារឲ្យសងជាប្រាក់ ដែលបានកំណត់នៅក្នុងលិខិតអនុវត្ត និងសោហ៊ុយសម្រាប់អនុវត្តក៏ដោយតុលាការអនុវត្តអាចរឹបអូសសិទ្ធិលើបំណុលនោះទាំងអស់បាន។ ប៉ុន្តែ បើតម្លៃនៃសិទ្ធិលើបំណុលដែលបានរឹបអូសមានលើសពីចំនួនសិទ្ធិលើបំណុលដែលមានក្នុងលិខិតអនុវត្ត និងសោហ៊ុយសម្រាប់អនុវត្តនោះតុលាការអនុវត្តមិនត្រូវរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតឡើយ។ អានុភាពនៃការរឹបអូសត្រូវកើតឡើងនៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅដល់កូនបំណុលទី៣។

ដីកាសម្រេចរឹបអូសមានអានុភាពទៅលើសិទ្ធិលើបំណុល ទាំងមូលដែលត្រូវបានរឹបអូសដោយមិនគិតសិទ្ធិទាមទារដែលមានក្នុងលិខិតអនុវត្តនោះទេ។ ការរឹបអូសជាន់គ្នាចំពោះសិទ្ធិលើបំណុលតែមួយ គឺមានអានុភាពទៅលើសិទ្ធិលើបំណុលទាំងអស់នោះតែម្តង។ ដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលដែលពុំមានអត្ថិភាពនៅតែមានអានុភាពជាដីកាសម្រេចរឹបអូស។

កូនបំណុលនៃការអនុវត្តលែងមានសិទ្ធិទារបំណុលពីកូនបំណុលទី៣។ កូនបំណុលទី៣លែងមានករណីកិច្ចសងបំណុលទៅកូនបំណុលនៃការអនុវត្ត។ បើរឹបអូសសិទ្ធិលើបំណុលដែលទាក់ទងនឹងប្រាក់បៀវត្សឬតាវកាលិកផ្សេងទៀតដែលទទួលបន្តបន្ទាប់ ការរឹបអូសនោះត្រូវមានអានុភាពលើតាវកាលិកដែលនឹងទទួលក្រោយពីការរឹបអូសនោះត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្ត។

ការដាស់តឿនឲ្យកូនបំណុលទី៣ ធ្វើសេចក្តីថ្លែងការណ៍បើមានពាក្យសុំពីម្ចាស់បំណុលនៃការអនុវត្តនៅពេលបញ្ជូនដីកាសម្រេចរឹបអូស តុលាការអនុវត្តត្រូវដាស់តឿនឲ្យកូនបំណុលទី៣ធ្វើសេចក្តីថ្លែងការណ៍ក្នុងអំឡុងពេល ២សប្តាហ៍នូវចំណុចខាងក្រោម៖

- អត្ថិភាពឬនត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវរឹបអូសនោះព្រមទាំងប្រភេទចំនួនទឹកប្រាក់ និងខ្លឹមសារនៃសិទ្ធិលើបំណុល
- អត្ថិភាព ឬនត្ថិភាពនៃឆន្ទៈសង និងទំហំនៃការសង ឬមូលហេតុដែលមិនសង
- សញ្ញាណនៃជនដែលមានសិទ្ធិអាទិភាពជាងម្ចាស់បំណុល នៃការអនុវត្ត
- អត្ថិភាពឬនត្ថិភាពនៃការរឹបអូស ឬការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលត្រូវរឹបអូស ដោយម្ចាស់បំណុលផ្សេង។

បើកូនបំណុលទី៣ មិនបានធ្វើសេចក្តីថ្លែងការណ៍តាមការដាស់តឿនដោយចេតនា ឬដោយកំហុសរបស់ខ្លួន ឬបានធ្វើសេចក្តីថ្លែងការណ៍ខុសពីការពិត កូនបំណុលទី៣ ត្រូវសងសំណងការខូចខាតដោយសារអំពើនោះ។ នៅពេលសិទ្ធិលើបំណុលត្រូវបានរឹបអូសកូនបំណុលទី៣ អាចរួចផុតពីបំណុលរបស់ខ្លួនដោយផ្ញើទុកប្រាក់ស្មើនឹងចំនួនប្រាក់ដែលត្រូវបានរឹបអូសក្នុងចំណោមសិទ្ធិលើបំណុល ឬប្រាក់ស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ នៅតុលាការអនុវត្ត។

កូនបំណុលទី៣ត្រូវផ្ញើប្រាក់ស្មើនឹងចំនួនប្រាក់នៃចំនួនប្រាក់ ទាំងអស់នៃសិទ្ធិលើបំណុល បើបានចេញដីកាសម្រេចរឹបអូស ឬដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយលើសភាគសំណល់ពីការរឹបអូសសិទ្ធិលើបំណុល ហើយបានទទួលដីកាសម្រេចនោះ មុនពេលដែលកូនបំណុលទី៣ បានទទួលពាក្យបណ្តឹងប្រមូលបំណុល។ កូនបំណុលទី៣ ត្រូវជូនដំណឹងអំពីស្ថានភាពនោះ ទៅតុលាការអនុវត្ត។

### ៣.៣.១.ពាក្យសុំចេញដីការសម្រេចរឹបអូស

បើគ្មានការអនុវត្តដោយស្ម័គ្រចិត្តទេ ទើបឈានដល់ការអនុវត្តដោយបង្ខំ ។ ម្ចាស់បំណុលនៃការអនុវត្តមានកាតព្វកិច្ចស្រាវជ្រាវរកសិទ្ធិលើបំណុលរបស់កូនបំណុលនៃការអនុវត្តដែលមាន គឺមិនមែនជាកាតព្វកិច្ចរបស់តុលាការអនុវត្តនោះទេ។

ដើម្បីអាចដាក់ពាក្យសុំ ម្ចាស់បំណុលនៃការអនុវត្តត្រូវរៀប ចំឯកសារដូចខាងក្រោម ៖

- លិខិតចម្លងយថាភូតនៃលិខិតអនុវត្ត
- ឯកសារបញ្ជាក់ពីការចូលជាស្ថាពរនៃលិខិតអនុវត្តដែលបញ្ជាក់ដោយក្រឡាបញ្ជី
- រូបមន្តអនុវត្តដែលរូបមន្តអនុវត្តផ្តល់ដោយក្រឡាបញ្ជី
- ត្រូវសរសេរពាក្យសុំតាមមាត្រា៤០៣ និងមាត្រា៣៤៩

ពាក្យសុំអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ត្រូវដាក់ទៅតុលាការអនុវត្តដែលមានសមត្ថកិច្ចគឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលនៃការអនុវត្ត ។ បើគ្មានគឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលទី៣។ នៅក្នុងពាក្យសុំអនុវត្តចំពោះសិទ្ធិលើបំណុលក្រៅពីមាត្រា ៣៤៩ គឺត្រូវសរសេរអំពីកូនបំណុលទី៣ព្រមទាំងបញ្ជាក់អំពីសិទ្ធិលើបំណុលដែលត្រូវរឹបអូស ក្នុងករណីដែលសុំឲ្យអនុវត្តចំពោះផ្នែកណាមួយនៃសិទ្ធិលើបំណុលត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវទំហំនៃការអនុវត្តនោះ។ ការដាក់ពាក្យសុំត្រូវបង់ពន្ធ ១០០០០ រៀល។

ក្រោយពេលបានទទួលពាក្យសុំរួចមក ចៅក្រមម្នាក់ៗត្រូវទទួលបន្ទុកជាស្វ័យប្រវត្តិតាមការកំណត់ទុកជាមុនដោយដីកាសម្រេចរបស់ប្រធានសាលាដំបូង។ នៅពេលទទួលបានពាក្យសុំចៅក្រមត្រូវពិនិត្យ ៖

- តើត្រូវសមត្ថកិច្ចឬទេ ?
- តើពាក្យសុំត្រឹមត្រូវតាមមាត្រា៣៤៩ និងមាត្រា៤០៣ឬទេ?
- តើភាគីត្រឹមត្រូវដូចក្នុងលិខិតអនុវត្តឬទេ ?
- តើមានឯកសារភ្ជាប់គ្រប់គ្រាន់ដែរ ឬទេ? (មានលិខិតអនុវត្ត មានលិខិតបញ្ជាក់ពីការចូលជាស្ថាពរ និងមានរូបមន្តអនុវត្ត មានលិខិតបញ្ជាក់សិទ្ធិតំណាងដែរឬទេ?
- តើបានបង់ពន្ធដាក់ពាក្យសុំឬទេ?
- តើបានបញ្ជូនលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្តជាមុនតាមមាត្រា៣៦ឬទេ?
- ការបង់សោហ៊ុយជាមុន?

### ៣.៣.២.នីតិវិធីនៃការចេញដីកាសម្រេចរឹបអូស

ក្រោយការពិនិត្យពាក្យសុំឃើញថាមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវហើយនោះតុលាការអនុវត្តបន្តនីតិវិធី។ ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំគឺជាដីកាសម្រេច"ចាប់ផ្តើមលក់ដោយបង្ខំ"ដំបូងដែលតុលាការអនុវត្តចេញ ក្នុងការចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ។ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលត្រូវចាប់ផ្តើម ដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត។ ជាគោលការណ៍ការរឹបអូសសិទ្ធិលើបំណុលអាចធ្វើបានចំពោះរូបទ្រព្យ ឬអរូបទ្រព្យទាំងអស់ដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត លើកលែងតែមានការកំណត់ពិសេសក្នុងច្បាប់។

សិទ្ធិលើបំណុលដែលមិនអាចរឹបអូសបានៈបៀវត្ស ប្រាក់ឈ្នួល និងសិទ្ធិលើបំណុលដែលមានលក្ខណៈដូចជាប្រាក់បៀវត្សផ្សេងទៀត អាចរឹបអូសបានចំពោះប្រាក់សល់ពីការកាត់ពន្ធអាករ និងប្រាក់ធានារ៉ាប់រងសង្គមកិច្ចពីចំនួនទឹកប្រាក់ដែលកូនបំណុលនៃការអនុវត្តត្រូវទទួលសំណងនៅពេលកំណត់ត្រូវសងនោះលុះត្រាតែស្របតាមចំណុចនីមួយៗដែលកំណត់ដូចខាងក្រោម៖

- ផ្នែកតិចជាងឬស្មើនឹង ២០០.០០០រៀល ក្នុងមួយខែនោះពុំអាចរឹបអូសបានទេ
- ផ្នែកក្នុងខ្ទង់លើសពី ២០០.០០០រៀល ទៅ ៦០០.០០០រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើស ចំនួនទឹកប្រាក់ ១ភាគ៤នៃផ្នែកនេះទេ
- ផ្នែកក្នុងខ្ទង់លើសពី ៦០០.០០០រៀល ទៅ ២០០០.០០០រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើស ចំនួនទឹកប្រាក់ ១ភាគ៣នៃផ្នែកនេះទេ
- ផ្នែកក្នុងខ្ទង់លើសពី ២០០០.០០០រៀល ទៅ ៤០០០.០០០រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើស ចំនួនទឹកប្រាក់ ១ភាគ២នៃផ្នែកនេះទេ

- ផ្នែកក្នុងខ្ទង់លើសពី ៤០០០.០០០រៀល ទៅ ៦០០០.០០០រៀល ក្នុងមួយខែនោះ ពុំអាចរឹបអូសលើស ចំនួនទឹកប្រាក់ ២ភាគ៣នៃផ្នែកនេះទេ
- ផ្នែកក្នុងខ្ទង់លើសពី៦០០០.០០០រៀលក្នុងមួយខែនោះអាចរឹបអូសបានទាំងអស់។

ទោះបីជាមានមាត្រា៣៨២ សិទ្ធិលើបំណុលដែលហាមឃាត់មិនឲ្យរឹបអូសក៏ដោយ តុលាការអនុវត្តអាចលុបចោលដីកាសម្រេចទាំងអស់ ឬមួយផ្នែក ឬអាចចេញដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលទាំងអស់ ឬមួយផ្នែកដែលហាមឃាត់នោះដោយពិចារណាលើជីវភាពនិងស្ថានភាពផ្សេងទៀតរបស់កូនបំណុល ឬម្ចាស់បំណុលតាមពាក្យសុំ។ បើមានស្ថានភាពផ្លាស់ប្តូរ តុលាការអាចផ្លាស់ប្តូរសេចក្តីសម្រេចរបស់ខ្លួនបានតាមពាក្យសុំ។

បើមានពាក្យសុំដូចខាងលើតុលាការអនុវត្តអាចបង្គាប់ហាមឃាត់កូនបំណុលទី៣មិនឲ្យបង់ ឬផ្តល់តាវកាលិកផ្សេងទៀតដោយឲ្យដាក់ប្រាតិភោគឬមិនឲ្យដាក់ប្រាតិភោគបានរហូតដល់ដីកាសម្រេចនោះមានអានុភាព។ ដីកាសម្រេចលើកចោលពាក្យសុំឲ្យលុបចោលដីកាសម្រេចរឹបអូសខាងលើអាចប្តឹងជំទាស់បាន ដីកាសម្រេចលុបចោលដីកាសម្រេចរឹបអូសអាចប្តឹងជំទាស់បាន។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលត្រូវចាប់ផ្តើម ដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត។ នៅក្នុងដីកាសម្រេចតុលាការអនុវត្តត្រូវហាមឃាត់មិនឲ្យកូនបំណុលធ្វើការប្រមូលបំណុល ឬចាត់ចែងផ្សេងទៀត និងហាមមិនឲ្យកូនបំណុលទី៣ សងបំណុលឲ្យកូនបំណុលនៃការអនុវត្ត។ ហើយដីកាសម្រេចរឹបអូសត្រូវធ្វើឡើងដោយមិនត្រូវសួរកូនបំណុលនៃការអនុវត្ត និងកូនបំណុលទី៣ទេ។ ដីកាសម្រេចរឹបអូសត្រូវបញ្ជូនទៅឲ្យកូនបំណុលនៃការអនុវត្ត និងកូនបំណុលទី៣។ ក្រឡាបញ្ជីត្រូវជូនដំណឹងអំពីការណ៍នោះ និងថ្ងៃខែឆ្នាំនៃការបញ្ជូននោះទៅម្ចាស់បំណុលនៃការអនុវត្ត។

បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជី បានបង្កើតអានុភាពតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីបញ្ជាក់ថាសិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ។ សេចក្តីសម្រេចអំពីពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសអាចប្តឹងជំទាស់បាន ។

ទោះបីសិទ្ធិលើបំណុលមានតម្លៃលើសពីចំនួនទឹកប្រាក់នៃសិទ្ធិទាមទារឲ្យសងជាប្រាក់ ដែលបានកំណត់នៅក្នុងលិខិតអនុវត្ត និងសោហ៊ុយសម្រាប់អនុវត្តក៏ដោយតុលាការអនុវត្តអាចរឹបអូសសិទ្ធិលើបំណុលនោះទាំងអស់បាន។ ប៉ុន្តែបើតម្លៃនៃសិទ្ធិលើបំណុលដែលបានរឹបអូស មានលើសពីចំនួនសិទ្ធិលើបំណុលដែល

មានក្នុងលិខិតអនុវត្ត និងសោហ៊ុយសម្រាប់អនុវត្តនោះតុលាការអនុវត្តមិនត្រូវរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតឡើយ។

### ៣.៣.៣.អានុភាពនៃដីកាសម្រេចរឹបអូស

អានុភាពនៃការរឹបអូសត្រូវកើតឡើង នៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅដល់កូនបំណុលទី៣។ ដីកាសម្រេចរឹបអូសមានអានុភាពទៅលើសិទ្ធិលើបំណុលទាំងមូលដែលត្រូវបានរឹបអូសដោយមិនគិតសិទ្ធិទាមទារដែលមានក្នុងលិខិតអនុវត្តនោះទេ។ការរឹបអូសជាន់គ្នាចំពោះសិទ្ធិលើបំណុលតែមួយគឺមានអានុភាពទៅលើសិទ្ធិលើបំណុលទាំងអស់នោះតែម្តង។

ដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលដែលពុំមានអត្ថិភាពនៅតែមានអានុភាពជាដីកាសម្រេចរឹបអូស។ កូនបំណុលនៃការអនុវត្តលែងមានសិទ្ធិទារបំណុលពីកូនបំណុលទី៣។ កូនបំណុលទី៣លែងមានករណីកិច្ចសងបំណុលទៅកូនបំណុលនៃការអនុវត្ត។

បើរឹបអូសសិទ្ធិលើបំណុលដែលទាក់ទងនឹងប្រាក់បៀវត្ស ឬតាវកាលិកផ្សេងទៀតដែលទទួលបន្តបន្ទាប់ ការរឹបអូសនោះត្រូវមានអានុភាពលើតាវកាលិក ដែលនឹងទទួលក្រោយពីការរឹបអូសនោះត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តនិងសោហ៊ុយសម្រាប់ការអនុវត្ត។

### ៣.៣.៤.ការប្រមូលបំណុល

បើ១សប្តាហ៍កន្លងហួស ក្រោយពីថ្ងៃដែលដីកាសម្រេចរឹបអូសបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត ម្ចាស់បំណុល ដែលបានរឹបអូសសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ អាចប្រមូលបំណុលនោះបានដោយមិនឲ្យលើសតម្លៃនៃសិទ្ធិលើបំណុលរបស់ខ្លួន និងសោហ៊ុយសម្រាប់ការអនុវត្តបានឡើយ។

ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស មានលក្ខខណ្ឌឬមានកំណត់ពេល ឬមានការលំបាកក្នុងការប្រមូលដោយសារភ្ជាប់នឹងតាវការលិកតប ឬមានហេតុផ្សេងទៀត តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឲ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុលនោះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ មុននឹងចេញដីកាសម្រេចបង្គាប់ឲ្យលក់នេះតុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្តសិន។ ហាមឃាត់ការលក់ដែលពុំមានប្រាក់នៅសល់។ មុនហាមឃាត់ការស្នើទិញដោយកូនបំណុលនៃការអនុវត្ត។

អាជ្ញាសាលាត្រូវបំពេញលក្ខខណ្ឌតតាំងសម្រាប់អនុប្បទាននៃសិទ្ធិលើបំណុល និងផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីសិទ្ធិប្រាតិភោគដែលបានធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសជាបន្តបន្ទាប់។ កូនបំណុលទី៣មិនព្រមសងដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យបណ្តឹងទាមទារប្រមូលបំណុលបាន។ ករណីមានបណ្តឹងទាមទារប្រមូលបំណុល បើមានពាក្យសុំរបស់កូនបំណុលទី៣តុលាការដែលទទួលពាក្យបណ្តឹង

អាចបង្គាប់ម្ចាស់បំណុលផ្សេងទៀត ដែលបានរឹបអូសសិទ្ធិលើបំណុលនោះមុនពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូន ឲ្យចូលរួមក្នុងនាមជាសហដើមចោទបាន ដោយដីកាសម្រេច។

### ៣.៤.ការលក់សិទ្ធិលើបំណុល

បើ១សប្តាហ៍កន្លងហួសក្រោយពីថ្ងៃដែលដីកាសម្រេចរឹបអូស បានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលបានរឹបអូសសិទ្ធិលើបំណុល ដែលមានគោលបំណងឲ្យសងជាប្រាក់ អាចប្រមូលបំណុលនោះបានដោយមិនឲ្យលើសតម្លៃនៃសិទ្ធិលើបំណុលរបស់ខ្លួន និងសោហ៊ុយសម្រាប់ការអនុវត្តបានឡើយ។ ម្ចាស់បំណុលក៏អាចអនុវត្តសិទ្ធិលើប្រាតិភោគបានដែរ។

ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសមានលក្ខខណ្ឌឬមានកំណត់ពេល ឬមានការលំបាកក្នុងការប្រមូលដោយសារភ្ជាប់នឹងតាវការលិកតប ឬមានហេតុផ្សេងទៀត តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឲ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុលនោះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ មុននឹងចេញដីកាសម្រេចបង្គាប់ឲ្យលក់នេះតុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្តសិន។ អាជ្ញាសាលាត្រូវបំពេញលក្ខខណ្ឌតតាំងសម្រាប់អនុប្បទាននៃសិទ្ធិលើបំណុល និងផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីសិទ្ធិប្រាតិភោគដែលបានធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស។

ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំទៅអាជ្ញាសាលាទាមទារឲ្យកូនបំណុលទី៣ប្រគល់ចលនវត្ថុ បើអំឡុងពេល១សប្តាហ៍បានកន្លងហួសគិតចាប់ពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត។ បន្ទាប់ពីទទួលការប្រគល់អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមវិធីលក់ចលនវត្ថុ ហើយត្រូវប្រគល់ប្រាក់ដែលបានពីការលក់នោះទៅតុលាការអនុវត្ត។

ម្ចាស់បំណុលនៃការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍ដែលបានទទួលសំណង ទៅតុលាការអនុវត្ត។ ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលខុសត្រូវចំពោះកូនបំណុលនៃការអនុវត្តក្នុងការសងការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តសិទ្ធិលើបំណុលដែលខ្លួនបានរឹបអូស។

បើកូនបំណុលទី៣មិនព្រមសងដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យបណ្តឹងទាមទារប្រមូលបំណុលបាន។ ករណីមានបណ្តឹងទាមទារប្រមូលបំណុលបើមានពាក្យសុំរបស់កូនបំណុលទី៣ តុលាការដែលទទួលពាក្យបណ្តឹងអាចបង្គាប់ម្ចាស់បំណុលផ្សេងទៀតដែលបានរឹបអូសសិទ្ធិលើបំណុលនោះមុនពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនឲ្យចូលរួមក្នុងនាមជាសហដើមចោទបាន ដោយដីកាសម្រេច។

### ៣.៤.១.ស្ថាប័នមានសមត្ថកិច្ចអនុវត្តការលក់

ការអនុវត្តការលក់ត្រូវបានអនុវត្តដោយអាជ្ញាសាលា។នៅកាលបរិច្ឆេទនៃការលក់អាជ្ញាសាលាត្រូវចែកទម្រង់ពាក្យសុំផ្តល់សំណើទិញទៅឲ្យអ្នកមានបំណងធ្វើសំណើទិញ។ អ្នកមានបំណងធ្វើសំណើទិញទាំងអស់ត្រូវសរសេរបំពេញទម្រង់ក្នុងពាក្យសុំនោះ ។

ចំណុចសំខាន់ៗ ដែលត្រូវបំពេញក្នុងទម្រង់ ពាក្យសុំផ្តល់សំណើទិញ ៖

- អត្តសញ្ញាណរបស់អ្នកផ្តល់សំណើរសុំទិញ អ្នកតំណាងដោយអាណត្តិ
- តម្លៃដែលស្នើសុំទិញ
- វិធីផ្តល់ប្រាក់ធានាលើសំណើទិញ។

អាជ្ញាសាលាត្រូវប្រកាសអត្តសញ្ញាណរបស់អ្នកទិញដែលដេញថ្លៃបាន និងថ្លៃលក់ឡាយឡុងនោះ ។ អាជ្ញាសាលាប្រកាសបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុង ។

បើមានអ្នកដេញថ្លៃច្រើននាក់ បានស្នើសុំទិញ ក្នុងតម្លៃអតិបរមាស្មើគ្នា ៖

- អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាស្មើគ្នាត្រូវដេញថ្លៃម្តងទៀតដោយ មិនអាចដេញថ្លៃក្នុងតម្លៃតិចជាងតម្លៃដែលខ្លួនបានដេញមុនឡើយ
- អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាស្មើគ្នាមិនព្រមដេញថ្លៃម្តងទៀត គឺត្រូវកំណត់ដោយការចាប់ឆ្នោត។

បន្ទាប់ពីបានអនុវត្តការលក់ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្តីពីការអនុវត្តការលក់ដាក់ទៅតុលាការអនុវត្តភ្លាម។

កំណត់ហេតុត្រូវសរសេរនូវចំណុច ៖

- សញ្ញាណនៃអចលនវត្ថុ
- កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ
- សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និងអ្នកដំណាង
- តម្លៃទិញរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។
- ហេតុការណ៍និងស្ថានភាពបើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា។
- ស្ថានភាពរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់។

ប្រសិនបើជនណាមានបំណងរំខានដល់កន្លែងលក់ និងរំខានដល់សកម្មភាព មិនឱ្យអនុវត្តការលក់នេះ ឬមានបំណងមិនត្រឹមត្រូវ អាជ្ញាសាលាមានសិទ្ធិមិនឱ្យជននោះចូលកន្លែងលក់ ឬមិនអាចស្នើសុំទិញបាន ឬ

អាចដេញជននោះចេញពីកន្លែងបាន គឺដើម្បីរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់ឱ្យមានរបៀបរៀបរយ។ ចំណែកឯប្រាក់ដែលបានមកពីការលក់នោះ អាជ្ញាសាលាត្រូវផ្ញើទៅសាលាដំបូងដែលខ្លួនស្ថិតនៅនិងធ្វើកំណត់ហេតុជូនតុលាការ[៥២]។

អាជ្ញាសាលាមានសិទ្ធិអំណាច និងទទួលខុសត្រូវនៅក្នុងការរៀបចំនិងរក្សាសណ្តាប់ធ្នាប់នៃការលក់ឡាយឡុងដោយផ្ទាល់មាត់ និងដោយដាក់ស្រោមសំបុត្រ។ និយាយម្យ៉ាងទៀតចំពោះជនណាដែលធ្វើសកម្មភាពរំខានកុំឱ្យមានការអនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវ ដូចជាបានធ្វើឱ្យរំខានដល់ជនដទៃទៀតក្នុងការធ្វើសំណើរទិញ ឬបានឃុបឃិតដើម្បីបញ្ចុះថ្លៃលក់ដោយមិនត្រឹមត្រូវ ឬចំពោះជនដែលបានប្រើឱ្យធ្វើសកម្មភាពនោះ អាជ្ញាសាលាអាចកម្រិតមិនឱ្យជននោះចូលកន្លែងលក់ ឬអាចដេញជននោះចេញពីកន្លែងលក់ ឬអាចមិនឱ្យស្នើសុំទិញបាន។

ក្នុងពេលប្រតិបត្តិការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ អាជ្ញាសាលាមានភារកិច្ចត្រូវរក្សាសណ្តាប់ធ្នាប់នៅក្នុងពេលលក់ដោយបង្ខំនោះដែល ករណីនេះអាជ្ញាសាលាអាចហាមបុគ្គលមួយចំនួនមិនចូលកន្លែងលក់ ឬមិនអនុញ្ញាតឱ្យអ្នកទិញដែលមិនបានបង់ប្រាក់ថ្លៃទិញលើកទី១ ក្នុងការលក់លើកទី២។ ក្នុងករណីដែលការលក់មិនអាចធ្វើទៅបានបើទោះបីជាបានអនុវត្តការលក់តាមវិធីសមរម្យក៏ដោយ ហើយប៉ាន់ប្រមាណឃើញថាមិនអាចលក់បាននាពេលអនាគត អាជ្ញាសាលាអាចលុបចោលការរឹបអូសចលនវត្ថុដែលត្រូវបានរឹបអូសហើយនោះបាន។

នៅកាលបរិច្ឆេទនៃការលក់ អាជ្ញាសាលាដែលទទួលបន្ទុកត្រូវតែចែកទម្រង់ពាក្យលក់ឡាយឡុងដោយស្រោមសំបុត្រ ស្រោមសំបុត្រដើម្បីបិទទម្រង់ពាក្យលក់ និងស្រោមសំបុត្រដែលដើម្បីបិទចំនួនប្រាក់ធានាលើសំណើទិញ។ អ្នកដែលមានបំណងធ្វើសំណើទិញត្រូវបំពេញក្នុងទម្រង់ពាក្យលក់ឡាយឡុងដោយស្រោមសំបុត្របិទទុកក្នុងស្រោមសំបុត្រ ហើយប្រគល់ទម្រង់ពាក្យលក់ឡាយឡុងជាមួយនឹងចំនួនទឹកប្រាក់ធានាលើសំណើទិញជូនទៅអាជ្ញាសាលា។

ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អ្នកដែលមានបំណងធ្វើសំណើសុំទិញត្រូវប្រគល់ទម្រង់ពាក្យលក់ឡាយឡុងនោះទៅអាជ្ញាសាលាដោយផ្ទាល់ដៃ ឬដាក់ទម្រង់នោះ នៅក្នុងប្រអប់នៅពេលដែលអាជ្ញាសាលាមានវត្តមាន។

តាមការអនុវត្តជាក់ស្តែង លោកសាស្ត្រាចារ្យគ្រូដឹកនាំកម្មសិក្សាបានប្រាប់ខ្ញុំបាទពេលកំពុងធ្វើកម្មសិក្សា ថាពុំមានទម្រង់ច្បាស់លាស់នោះទេ លោកប្រគល់ឲ្យអ្នកស្នើសុំទិញអលចនវត្ថុនូវក្រដាស រ៉ាមសមួយ

[៥២] មាត្រា៤៣៦ កឋាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

សន្លឹកទៅឲ្យអ្នកដេញថ្លៃ ហើយឲ្យអ្នកដេញថ្លៃសរសេរពីតម្លៃដែលខ្លួនយល់ព្រមដេញថ្លៃដោយដាក់ក្រដាសនោះទៅក្នុងសំបុត្របិទជិត រួចប្រគល់ជូនមន្ត្រីទទួលបន្ទុក កិច្ចការអាជ្ញាសាលា ក្រោយមកទើបលោកនាយកបើកសំបុត្រ ហើយប្រកាសកំណត់អ្នក ស្នើសុំទិញក្នុងតម្លៃអតិបរិមា។

នីតិវិធីនៃកាលក់ដោយបង្ខំ មានដំណើរតាមលំដាប់ តាមពាក្យសុំរបស់ម្ចាស់បំណុលតុលាការអនុវត្តដាក់កម្រិតទៅលើសិទ្ធិចាត់ចែងរបស់កូនបំណុល ចំពោះអចលនវត្ថុដែមជាកម្មវត្ថុ ដោយធ្វើការរឹបអូសអចលនវត្ថុនោះ ហើយលក់អចលនវត្ថុនោះ រួចទើបធ្វើការចែកចំណែកនៅប្រាក់ដែលបានមកពីការលក់នោះ ។លំហូរនៃនីតិវិធីដែលមានការរឹបអូស ការលក់និងការចែកចំណែក គឺដូចគ្នាទៅនឹងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ ខុសតែត្រង់ថាសកម្មភាពនៃការអនុវត្តទាំងអស់នេះ ត្រូវធ្វើឡើងតាមលំដាប់លំដោយ តុលាការអនុវត្ត ។ មានន័យថាជាដំបូងតុលាការអនុវត្តរឹបអូសអចលនវត្ថុដោយចេញដីការសម្រេចចាប់ផ្តើការលក់ដោយបង្ខំ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។ បន្ទាប់មក តុលាការអនុវត្ត កំណត់វិធីលក់ កំណត់កាលបរិច្ឆេទនិងទីកន្លែងលក់ ហើយឲ្យអាជ្ញាសាលាអនុវត្តការលក់នោះ និងកំណត់អ្នកស្នើសុំទិញក្នុងតំលៃអតិបរមា ។

ក្រៅពីនេះតុលាការអនុវត្តស្តាប់ការថ្លែងយោបល់របស់បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍នៅក្នុងការបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតអោយលក់ រួចហើយប្រកាសអំពីការអនុញ្ញា ឬ មិនអនុញ្ញាតឲ្យលក់ ។ ជាចុងក្រោយនៅពេលដែលដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរហើយ តុលាការអនុវត្តនឹងកំណត់ពេលដែលអ្នកទិញត្រូវបង់ប្រាក់ថ្លៃទិញ។ បន្ទាប់ពីបានទទួលការបង់ប្រាក់ថ្លៃទិញហើយ តុលាការអនុវត្តនឹងកំណត់កាលបរិច្ឆេទនៃការចែកចំណែក និង ធ្វើការចែកចំណែកនៅកាលបរិច្ឆេទនោះ ។ តុលាការអនុវត្តត្រូវឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីកាទាញហេតុផលដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនីមួយៗនៃតុលាការអនុវត្ត ។

ការលក់អាចប្រព្រឹត្តិទៅបានតាមរូបភាពច្រើនប្រភេទ ដូចជាការលក់ឡាយឡុង ការលក់ដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ។ ការលក់អចលនវត្ថុ ត្រូវធ្វើឡើងដោយអាជ្ញាសាលា តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រឬដោយផ្ទាល់មាត់ ។ មានតែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រមសំបុត្រ ឬ ដោយផ្ទាល់មាត់ ដែលតុលាការអនុវត្តកំណត់វិធីលក់ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

### ៣.៤.២.នីតិវិធីក្នុងការលក់ឡាយឡុង

ក្រោយពីអាជ្ញាសាលាបានកំណត់តម្លៃអប្បបរមារួច អាជ្ញាសាលាត្រូវកំណត់អំពីវិធីលក់ កាលបរិច្ឆេទ ពេលវេលានិងទីកន្លែងលក់ជាមុនសិន។ បន្ទាប់មកអាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុ ដែលនឹងត្រូវដាក់លក់ និងវិធីលក់ចលនវត្ថុដោយបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ[៥៣]។

#### ៣.៤.២.១ការលក់ឡាយឡុងដោយផ្ទាល់មាត់

ការលក់ឡាយឡុងដោយផ្ទាល់មាត់៖ ធ្វើឡើងដោយការស្នើចំនួនទឹកប្រាក់ថ្លៃទិញ ហើយអាជ្ញាសាលា នឹងប្រកាសអំពីការអនុញ្ញាតឲ្យទិញ ចំពោះអ្នកស្នើដែលហ៊ានឲ្យថ្លៃខ្ពស់ជាងគេ គឺជាអ្នកដែលដេញថ្លៃបាន។ ក្នុង ចំណោមវិធីលក់ចលនវត្ថុ ការលក់ឡាយឡុងដោយផ្ទាល់មាត់គឺជាវិធីមួយដែលសមរម្យងាយស្រួលក្នុងការ អនុវត្ត។

ការលក់ឡាយឡុងដោយផ្ទាល់មាត់៖ ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺជាវិធីលក់ដែលតាមរយៈ នោះអ្នកស្នើសុំទិញ ធ្វើសំណើទិញដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃការលក់ ហើយពួកគេដេញថ្លៃឡើង រហូត ដល់ពេលគេអាចកំណត់អ្នកដែលហ៊ានអោយថ្លៃខ្ពស់ជាងគេបាន ។

ចរិតលក្ខណៈនៃការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺថាអ្នកស្នើសុំទិញដឹងអំពីចំនួនទឹកប្រាក់ ដែលដៃគូរប្រកួតប្រជែងរបស់ខ្លួនដាក់ស្នើហើយដេញថ្លៃឡើងអោយខ្ពស់ជាងថ្លៃដែលគេបានស្នើនោះ វិធីនេះបង្ក ភាពងាយស្រួលដល់ការស្នើសុំទិញ ហើយការប្រកួតប្រជែងត្រូវបានធ្វើឡើងដោយចំពោះ គុណសម្បត្តិនៃវិធីនេះ គឺគេអាចលក់វត្ថុបានថ្លៃ ។

ដោយឡែក គុណវិបត្តិនៃវិធីនេះគឺវាទាមទារនូវភាពបិនប្រសព្វបច្ចេកទេសនិងបទពិសោធន៍។មាន ន័យថាវិធីនេះ ល្អសម្រាប់តែអ្នកជំនួញដែលមានបទពិសោធន៍ប៉ុណ្ណោះ ហើយគេពិបាកទាក់ទាញឲ្យមានការ ចូលរួមយ៉ាងទូលំទូលាយពីសំណាក់សាធារណៈជនទូទៅណាស់ ។

ការលក់តាមវិធីផ្សេងក្រៅពីវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយស្រោមសំបុត្រះប្រសិនបើ អាជ្ញាសាលាយល់ថាសមរម្យដោយគិតពិចារណាអំពីប្រភេទនិងចំនួននៃចលនវត្ថុអាទិ៍អាជ្ញាសាលា អាចអនុវត្ត ការលក់ចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្តោះអាសន្នផ្សេងពីវិធីទាំងពីនេះ ឬឲ្យបុគ្គលផ្សេងពីអាជ្ញាសាលាអនុវត្ត ការលក់ចលនវត្ថុដែលត្រូវបានរឹបអូសដោយទទួលការអនុញ្ញាត ពីសាលាដំបូងដែលខ្លួនស្ថិតនៅ។

[៥៣] មាត្រា ៣៩៥ កថាខណ្ឌទី ៣, ក្រមនីតិវិធីរដ្ឋប្បវេណី

វិធីផ្សេងនោះមានដូចជា៖ការលក់ចលនវត្ថុនៅក្នុងពិធីតាំងពិពណ៌ ឬការយកចលនវត្ថុដែលត្រូវបានរឹបអូសទៅលក់នៅកន្លែងដែលងាយលក់ ឬអនុញ្ញាតឲ្យបុគ្គលដែលមានបទពិសោធន៍ក្នុងការលក់ចលនវត្ថុដែលមានប្រភេទដូចគ្នានឹងចលនវត្ថុដែលត្រូវបានរឹបអូសជាអ្នកលក់ជំនួសអាជ្ញាសាលា។

### ៣.៤.២.២.ការលក់ឡាយឡុងដោយស្រោមសំបុត្រ

ការលក់ឡាយឡុងដោយស្រោមសំបុត្រ ៖ ធ្វើឡើងតាមវិធីដែលអ្នកស្នើសុំទិញដាក់ពាក្យសុំទិញជាលាយលក្ខណ៍អក្សរ ហើយអាជ្ញាសាលានឹងបើកស្រោមសំបុត្រភ្លាមបន្ទាប់ពីដេញថ្លៃ រួចប្រកាសឈ្មោះនិងថ្លៃដេញរបស់បុគ្គលដែលហ៊ានថ្លៃជាងគេព្រមទាំងការអនុញ្ញាតឲ្យបុគ្គលនោះទិញ។ វិធីលក់ឡាយឡុងដោយស្រោមសំបុត្រនេះ គេច្រើនយកមកអនុវត្តនៅក្នុងការលក់ចលនវត្ថុដែលមានតម្លៃខ្ពស់ ហើយដែលអាចកំណត់តម្លៃអប្បបរមា តាមការវាយតម្លៃរបស់អ្នកវាយតម្លៃ។

វិធីលក់ឡាយឡុងដោយស្រោមសំបុត្រ គឺជាវិធីលក់ដែលតាមរយៈ អ្នកសស្នើសុំទិញមកជួបជុំគ្នានៅថ្ងៃលក់ឡាយឡុង ហើយធ្វើសំណើទិញដោយដាក់ឯកសារដេញថ្លៃដែលមានបញ្ជាក់ពីថ្លៃទិញនៅក្នុងនោះ។ បន្ទាប់មក គេនឹងបើកឯកសារដេញថ្លៃទាំងនោះ ហើយប្រកាសអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានៅលើឆាក។ វិធីលក់នេះនឹងមិនធ្វើឲ្យបុគ្គលដែលចង់ទិញដឹងអំពីកម្មវត្ថុ និង ថ្លៃដែលបុគ្គលផ្សេងទៀតហ៊ានឲ្យទេ ព្រោះថាអ្នកស្នើសុំទិញម្នាក់ៗដាក់សំណើសុំទិញដែលគេហ៊ានឲ្យនៅក្នុងឯកសារបិទជិត ។

ហេតុនេះនាំឲ្យគេអាចទប់ស្កាត់ការប្រើល្បិចកល និង ការឃុបឃិតដើម្បីបញ្ចុះថ្លៃលក់បាន។ម៉្យាងទៀត ការប្រើវិធីនេះឲ្យគេមិនសូវមានក្ដីបារម្ភថាអ្នកស្នើសុំទិញអាចទទួលរងការគាបសង្កត់ដោយសារបរិយាកាសនៅកន្លែងលក់ ឬដោយសារអ្នកប្រកួតប្រជែងដែលមិនស្មោះត្រង់។ហេតុនេះហើយបានជាគេកំណត់យកវិធីនេះជាវិធីទូទៅសម្រាប់ការលក់អចលនវត្ថុ ។

នៅកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រនោះ ពេលដែលការដេញថ្លៃបានបញ្ចប់ ហើយអាជ្ញាសាលាត្រូវបើកស្រោមសំបុត្រនៅចំពោះមុខអ្នកស្នើសុំទិញទាំងអស់ ដែលមានវត្តមានហើយកំណត់អ្នកស្នើសុំទិញដោយអតិបរមា រួចហើយប្រកាសនូវនាម ឬនាមករណ៍របស់អ្នកនោះ និងថ្លៃលក់ឡាយឡុងនោះ។ ប្រសិនបើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា មានច្រើននាក់ អាជ្ញាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយឲ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្ដងទៀត។ ក្នុងករណីដែលអ្នកដេញថ្លៃទាំងនោះមិនព្រមដេញថ្លៃម្ដងទៀត ឬករណីដែលនៅតែមានអ្នកហ៊ានឲ្យថ្លៃស្មើគ្នាទៀត នោះត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយការចាប់ឆ្នោត ។

### ៣.៤.២.៣.កំណត់វិធីលក់

ដើម្បីលក់ចលនវត្ថុដែលបានរឹបអូស អាជ្ញាសាលាត្រូវលក់តាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយដាក់ស្រោមសំបុត្រ។ ប៉ុន្តែប្រសិនបើយល់ឃើញថាសមរម្យ និងដោយគិតពិចារណាអំពីប្រភេទ និងចំនួនរបស់ចលនវត្ថុ ជាអាទិ៍ អាជ្ញាសាលាអាចអនុវត្តការលក់ចលនវត្ថុតាមវិធីផ្សេងបាន ឬអាចឲ្យបុគ្គលផ្សេងពីអាជ្ញាសាលា អនុវត្តការលក់ចលនវត្ថុដែលបានរឹបអូសនោះបាន ដោយទទួលការអនុញ្ញាតពីសាលាដំបូង[៥៤]។

ការលក់ឡាយឡុងដោយផ្ទាល់មាត់ ធ្វើឡើងដោយការស្នើសុំចំនួនទឹកប្រាក់ដែលជាថ្លៃទិញ ហើយអាជ្ញាសាលានឹងប្រកាសអំពីការអនុញ្ញាតឲ្យទិញចំពោះអ្នកស្នើដោយហ៊ានឲ្យថ្លៃខ្ពស់ជាងគេ។

រីឯការលក់ដោយស្រោមសំបុត្រធ្វើឡើងតាមវិធីដែលអ្នកស្នើសុំទិញ ដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរហើយអាជ្ញាសាលា នឹងបើកស្រោមសំបុត្រភ្លាមបន្ទាប់ពីបិទការដេញថ្លៃរួចប្រកាសឈ្មោះ និងថ្លៃដេញរបស់បុគ្គលដែលហ៊ានឲ្យថ្លៃខ្ពស់ជាងគេ ព្រមទាំងការអនុញ្ញាតឲ្យបុគ្គលនោះទិញ បន្ទាប់មកអ្នកស្នើទិញក្នុងតម្លៃអតិបរមាត្រូវបង់ថ្លៃទិញភ្លាមៗ[៥៥]។

### ៣.៤.២.៤.ការជូនដំណឹងពីការលក់ជាសាធារណៈ

អាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុដែលត្រូវដាក់លក់ និងវិធីលក់ចលនវត្ថុនោះដោយបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ។ មុនចាប់ផ្តើមការលក់ ចលនវត្ថុដែលបានរឹបអូស អាជ្ញាសាលាត្រូវធ្វើការជូនដំណឹងពីការលក់នេះជាសាធារណៈដោយត្រូវផ្សាយពីការកំណត់ថ្ងៃលក់ ទីកន្លែង និងតម្លៃនៃចលនវត្ថុ។

### ៣.៤.២.៥.សំណើរទិញ

ការអាចទិញចលនវត្ថុបាន អ្នកដែលមានបំណងចង់ទិញចលនវត្ថុនៃការលក់ឡាយឡុងនោះ ត្រូវធ្វើសំណើទិញជាលាយល័ក្ខណ៍អក្សរមកអាជ្ញាសាលាដែលកាន់សំណុំរឿងនោះ ក្នុងករណីដែលអាជ្ញាសាលាជ្រើសរើសយកវិធីលក់ដោយស្រោមសំបុត្រ។ ទោះយ៉ាងនេះក្តីក្រមនីតិវិធីរដ្ឋប្បវេណី មិនមានបញ្ញត្តិថាអ្នកមានបំណងចង់ទិញត្រូវធ្វើសំណើទិញជាលាយល័ក្ខណ៍អក្សរមកអាជ្ញាសាលា ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានយក គោលការណ៍នៃការលក់អចលនវត្ថុមកអនុវត្តចំពោះចលនវត្ថុដែរ។

---

[៥៤] មាត្រា ៣៩៥ កថាខណ្ឌទី ១ និងទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី

[៥៥] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២, ២០០៩, ទំព័រ ៨៩។

អាជ្ញាសាលាបានកំណត់អ្នកមិនអាចធ្វើសំណើទិញបានដែលរួមមានកូនបំណុលនៃការអនុវត្ត អ្នកទិញដែលមិនបានបង់ថ្លៃទិញចលនវត្ថុក្នុងពេលលក់លើកមុន បុគ្គលដែលអាជ្ញាសាលាមិនអនុញ្ញាតឲ្យធ្វើសំណើទិញ និងបុគ្គលដែលមិនអាចក្លាយជាអ្នកទិញបានតាមក្រមរដ្ឋប្បវេណីមាត្រា៥២៥ និងមាត្រ៥២៦ ព្រមទាំងបុគ្គលដែលមិនមានសមត្ថភាពក្នុងការធ្វើសកម្មភាពដូចជាអនីតិជន ជននៅក្រោមហិតូបត្ថមនិងជននៅក្រោមអាណាព្យាបាលទូទៅ ដែលអសមត្ថភាពក្នុងការបង្ហាញឆន្ទៈ។

### ៣.៤.២.៦.ការអនុវត្តការលក់

ការអនុវត្តការលក់ត្រូវធ្វើនៅកាលបរិច្ឆេទនៃការលក់ តាមការប្រកាសផ្សាយបន្ទាប់ពីបានផ្សាយជាសាធារណៈអំពីតម្លៃអប្បបរមា វិធីនៃការដេញថ្លៃ ទីកន្លែងនិងពេលវេលានៃការដេញថ្លៃជាក់លាក់រួច។ នៅកាលបរិច្ឆេទនៃការផ្សាយជាដំបូងអាជ្ញាសាលាត្រូវប្រកាសលក់ចលនវត្ថុនោះ ដោយបញ្ជាក់អំពីតម្លៃអប្បបរមាហើយចាប់ផ្តើមឲ្យអ្នកទិញដាក់សំណើទិញតាមវិធីដែលបានជូនដំណឹង។ នៅពេលបញ្ចប់ការដាក់សំណើទិញអាជ្ញាសាលាត្រូវប្រកាសឈ្មោះអ្នកទិញនិងតម្លៃដែលខ្ពស់ជាងគេ។

បន្ទាប់មកអាជ្ញាសាលាត្រូវប្រកាសអនុញ្ញាតឲ្យទិញ ករណីនេះអ្នកទិញត្រូវបង់ថ្លៃភ្លាមទើបទទួលបាននូវលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះបាន។ ក្នុងករណីដែលអ្នកទិញមិនបានបង់ថ្លៃទិញទេអាជ្ញាសាលាត្រូវដាក់លក់ឡាយឡុងម្តងទៀតតាមវិធីដូចខាងដើម នៅពេលនោះអ្នកទិញក្នុងតម្លៃអតិបរមាមុនមិនអាចដាក់សំណើទិញម្តងទៀតបានទេ[៥៦]។

អាជ្ញាសាលាមានសិទ្ធិអំណាច និងទទួលខុសត្រូវនៅក្នុងការរៀបចំនិងរក្សាសណ្តាប់ធ្នាប់នៃការលក់ឡាយឡុងដោយផ្ទាល់មាត់និងដោយស្រោមសំបុត្រ។ ចំពោះជនណាដែលធ្វើសកម្មភាពរំខានមិនឲ្យមានការអនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវ ឬធ្វើឲ្យរំខានដល់ជនដទៃទៀតក្នុងការធ្វើសំណើរទិញ ឬបានឃុបឃិតដើម្បីបញ្ចុះថ្លៃលក់ដោយមិនត្រឹមត្រូវនោះអាជ្ញាសាលាអាចធ្វើការហាមឃាត់មិនឲ្យជននោះចូលកន្លែងលក់ ឬអាចដេញជននោះចេញពីកន្លែងលក់ ឬអាចមិនឲ្យស្នើសុំទិញបាន។

ក្នុងករណីដែលការលក់មិនអាចធ្វើទៅបាន បើទោះបីជាបានអនុវត្តការលក់តាមវិធីសមរម្យក៏ដោយ ហើយបើប៉ាន់ប្រមាណឃើញថា មិនអាចលក់បាននាពេលអនាគត អាជ្ញាសាលាអាចលុបចោល ការរឹបអូសចលនវត្ថុដែលត្រូវបានរឹបអូសហើយនោះបាន។

[៥៦] មាត្រា ៣៩៥ កថាខណ្ឌទី ៦ ក្រមនីតិវិធីរដ្ឋប្បវេណី

**៣.៤.២.៧.លទ្ធកម្មចលនវត្ថុដែលបានលក់**

ជាទូទៅលទ្ធកម្មចលនវត្ថុដែលលក់ឡាយឡុង មានបន្ទាប់ពីអាជ្ញាសាលាបានប្រកាសអនុញ្ញាតឲ្យទិញហើយអ្នកទិញបានបង់ថ្លៃភ្លាមៗទើបទទួលបាននូវលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ[៥៧]។ ប៉ុន្តែការធ្វើលទ្ធកម្មចំពោះចលនវត្ថុដែលបានចុះបញ្ជីដូចជាទោចក្រយានយន្ត និងរថយន្ត គឺធ្វើលទ្ធកម្មនៅពេលដែលអាជ្ញាសាលាផ្ទុកផ្តាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិបញ្ហាដែលជាការព្រួយបារម្ភ គឺករណីផ្ទេរកម្មសិទ្ធិរថយន្តដែលគ្មានស្លាកលេខរថយន្ត ដែលឈ្មោះក្នុងគល់បញ្ជីមិនមែនជាឈ្មោះម្ចាស់ដែលកំពុងកាន់កាប់ដែលជាករណីលក់តគ្នាដោយ ពុំមានការផ្ទេរឈ្មោះ និងរថយន្តឯកជនតែពាក់ស្លាកលេខរដ្ឋ ឬ ខម ឬ . នគរបាល។

ថ្វីត្បិតតែនេះជាបញ្ហារបស់ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី ប៉ុន្តែប្រសិនជាជួបបញ្ហានេះ ថាតើអាជ្ញាសាលា ត្រូវធ្វើលិខិតផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីផ្ទេរយ៉ាងណា ដើម្បីឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្នដែលយើងពុំមានច្បាប់ចែងច្បាស់លាស់។

**៣.៤.២.៨.កំណត់ហេតុនៃការលក់**

អាជ្ញាសាលាត្រូវបញ្ចប់ការលក់ដោយកំណត់ហេតុនៃការលក់។ ទម្រង់នៃកំណត់ហេតុនេះក៏មានទម្រង់ និងសញ្ញាណដូចនឹងកំណត់ហេតុនៃការរឹបអូសអញ្ចឹងដែរ គឺអាជ្ញាសាលាត្រូវសរសេរឈ្មោះ និងចុះហត្ថលេខាព្រមទាំងមានសញ្ញាណរឿងក្តី ពេលវេលានិងទីកន្លែងបំពេញមុខនាទីខ្លឹមសារនៃកិច្ចការដែលបានចាត់ចែង និងកាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ។

ចំពោះខ្លឹមសារនៃកំណត់ហេតុ អាជ្ញាសាលាត្រូវកត់ត្រាឈ្មោះអ្នកដេញបាន ឬអ្នកតំណាងក្នុងតម្លៃអតិបរមា ការបង់ប្រាក់ ការធ្វើលទ្ធកម្ម ព្រមទាំងហេតុការណ៍ផ្សេងៗទៀតប្រសិនជាមាន។

## ៣.៥.ការចែកចំណែក

### ៣.៥.១.ម្ចាស់បំណុលដែលមានសិទ្ធិទទួលបានចំណែក

វិសាលភាពនៃម្ចាស់បំណុលដែលចូលរួមចែកចំណែករួមមានៈ

- ម្ចាស់បំណុលដែលបានអនុវត្តការរឹបអូស
- មុនម្ចាស់បំណុលដែលបានអនុវត្តការរឹបអូសជាបណ្តោះអាសន្ន
- ម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែកមុនពេល។

---

[៥៧] មាត្រា ៣៩៥ កថាខណ្ឌទី ៥, ក្រមដដែល

តុលាការដែលត្រូវអនុវត្តការចែកចំណែក សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ចំពោះការអនុវត្ត ដោយបង្ខំចំពោះចលនវត្ថុឬតុលាការអនុវត្តចំពោះករណីផ្សេង។ តុលាការដែលត្រូវចែកចំណែក ត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក និងផ្តល់ដំណឹងអំពីពេលវេលានិងទីកន្លែងចែកចំណែក ទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និងកូនបំណុលនៃការអនុវត្ត។

ពេលដែលកាលបរិច្ឆេទត្រូវបានកំណត់ហើយ ក្រឡាបញ្ជីត្រូវដាស់តឿនម្ចាស់បំណុលម្នាក់ៗឲ្យផ្តល់លិខិតគណនាអំពីប្រាក់ដើមនៃសិទ្ធិលើបំណុលការប្រាក់រហូតដល់កាលបរិច្ឆេទនៃការចែកចំណែកនិងសោហ៊ុយសម្រាប់ការអនុវត្តទៅតុលាការដែលត្រូវចែកចំណែកក្នុងអំឡុងពេល១សប្តាហ៍។

បើម្ចាស់បំណុលមានច្រើននាក់ហើយទឹកប្រាក់ដែលត្រូវចែកនោះមិនគ្រប់គ្រាន់ សម្រាប់សងសិទ្ធិលើបំណុល និងសោហ៊ុយសម្រាប់អនុវត្តទេ តុលាការដែលត្រូវចែកចំណែកត្រូវរៀបចំសេចក្តីព្រាងនៃតារាងចែកចំណែក។ ពេលម្ចាស់បំណុលណាម្នាក់ ឬកូនបំណុលនៃការអនុវត្ត ដែលមិនពេញចិត្តចំពោះសេចក្តីព្រាងនៃតារាងនោះ អាចថ្លែងតវ៉ា នៅកាលបរិច្ឆេទនោះ។

បើម្ចាស់បំណុលមានច្រើននាក់ហើយទឹកប្រាក់ដែលត្រូវចែក នោះមិនគ្រប់គ្រាន់សម្រាប់សងសិទ្ធិលើបំណុលនិងសោហ៊ុយសម្រាប់អនុវត្តទេ តុលាការដែលត្រូវចែកចំណែកត្រូវរៀបចំសេចក្តីព្រាងនៃតារាងចែកចំណែក។

### ៣.៥.២.នីតិវិធីចែកចំណែក

#### ៣.៥.២.១.ការចែកចំណែកដោយការព្រមព្រៀង

ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានពីការលក់ ឬប្រាក់ដែលត្រូវបានរឹបអូសអាចសងចំពោះសិទ្ធិលើម្ចាស់បំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បានតុលាការអនុវត្តត្រូវចែកចំណែកចំពោះម្ចាស់បំណុលហើយត្រូវប្រគល់ប្រាក់នៅសេសសល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ ព្រោះថាប្រសិនបើម្ចាស់បំណុលមានតែម្នាក់ ឬបើទោះជាម្ចាស់បំណុលមានច្រើននាក់ក៏ដោយ បើទឹកប្រាក់ដែលបានមកពីការលក់អាចសងបំណុលគ្រប់នោះ នេះជាការគ្រប់គ្រាន់ហើយ ដែលត្រូវសងបំណុលទៅម្ចាស់បំណុលនីមួយៗ និងប្រគល់ប្រាក់ដែលនៅសេសសល់ទៅឱ្យកូនបំណុលវិញ។

ករណីផ្សេងទៀតប្រសិនបើម្ចាស់បំណុលទាំងអស់បានព្រមព្រៀងគ្នា លើការចែកចំណែកនូវប្រាក់ដែលបានមកពីការលក់នោះ តុលាការអនុវត្តត្រូវធ្វើការបែងចែកទៅតាមការព្រមព្រៀងនោះ។ ទោះបីជាម្ចាស់បំណុលមានច្រើន ហើយទឹកប្រាក់ដែលបានមកពីការលក់ មិនអាចសងបំណុលគ្រប់ក៏ដោយប្រសិនបើម្ចាស់

បំណុលទាំងអស់បានព្រមព្រៀងគ្នាលើការចែកចំណែកហើយនោះពុំមានភាពចាំបាច់អ្វីដែលត្រូវធ្វើការសម្រេចជាពិសេសទៀតនោះទេ ហេតុដូច្នេះបញ្ញត្តិនេះតម្រូវឱ្យតុលាការអនុវត្តធ្វើការចែកចំណែកទៅតាមនោះ។

### ៣.៥.២.២.ការចែកចំណែកដោយតុលាការ

ប្រសិនបើម្ចាស់បំណុល មិនអាចព្រមព្រៀងគ្នាលើការចែកចំណែកនូវប្រាក់ ដែលបានមកពីការលក់ទេនោះតុលាការអនុវត្តត្រូវធ្វើការបែងចែកចំណែកនោះ។ សាលាដំបូងត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការចែកចំណែករួចធ្វើការចែកចំណែក។ ដីកាសម្រេចអំពីការកំណត់កាលបរិច្ឆេទនៃការបែងចែកចំណែកត្រូវចេញឲ្យបានឆាប់រហ័សបន្ទាប់ពីអ្នកទិញបានបង់ថ្លៃលក់។

ច្បាប់មិនបានកំណត់ថាតើចៅក្រមត្រូវកំណត់រយៈពេលប៉ុន្មានថ្ងៃ គិតចាប់ពីថ្ងៃចេញដីកាដើម្បីធ្វើការបែងចែកចំណែកនោះទេ ។ មានការផ្តល់យោបល់ថាកាលបរិច្ឆេទសម្រាប់ការបែងចែកចំណែកគួរស្ថិតក្នុងអំឡុងពេល១ខែ គិតចាប់ពីថ្ងៃចេញដីកា។

## ៣.៦.ការអនុវត្តដោយបង្ខំសិទ្ធិលើបំណុលជាការប្រគល់ចលនវត្ថុ

### ៣.៦.១.ការប្រគល់ចលនវត្ថុ

ដើម្បីចាត់ទុកថាជាកម្មវត្ថុដែលត្រូវប្រគល់នោះ ចាំបាច់ត្រូវតែជាចលនវត្ថុជាក់លាក់ ប៉ុន្តែមិនសំខាន់ថាតើនោះជាចលនវត្ថុមួយទាំងមូលឬ ជាផ្នែកណាមួយនៃចលនវត្ថុដែលរួមគ្នានៅឡើយទេ ។ ឧទាហរណ៍ការប្រគល់ទំនិញនៅក្នុងហាងណាមួយ ។ ដោយសារនេះ មិនមែនជាការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ ដូច្នេះទោះបីជាចលនវត្ថុ ដែលជាកម្មវត្ថុនោះគ្មានតម្លៃឬមានតម្លៃប៉ុន្មានក៏ដោយ ហើយទោះបីជាចលនវត្ថុនោះជាទ្រព្យសម្បត្តិដែលហាមឃាត់មិនឲ្យរឹបអូសក៏ដោយ ក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុជាក់លាក់ដែរ ។

ហើយករណីកិច្ចប្រគល់សំដៅលើកាប្រគល់ទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ក៏ដូចជាការប្រគល់ទៅឲ្យ តតិយជន ឬការបង្ហាញដើម្បីធ្វើការត្រួតពិនិត្យ។ ទោះបីកូនបំណុលនៃការអនុវត្តមានករណីកិច្ចបន្ទាប់បន្សំផ្សេងទៀត ដូចជាករណីកិច្ចវេចខ្ចប់និងផ្ញើរក៏ដោយ ក៏គេអាចធ្វើការអនុវត្តដោយបង្ខំនៅកន្លែងវត្ថុនោះស្ថិតនៅបានដែរ ។

មានសំណួរមួយចោទឡើងថា តើគេអាចធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឲ្យប្រគល់កូនក្មេងតាមវិធីអនុវត្តអនុវត្តដោយផ្ទាល់នេះ ដោយបកស្រាយថាសិទ្ធិទាមទារឲ្យប្រគល់កូននោះ គឺជាសិទ្ធិទាមទារដែលមានគោលបំណងឲ្យប្រគល់វត្ថុជាក់លាក់បានដែលឬទេ។ មិនចាំបាច់និយាយអ្វីច្រើនទេ កូនក្មេងមិនមែនជា

ចលនវត្ថុទេ។បើសង្កត់ធ្ងន់ទៅលើចំណុចនេះគេអាចនិយាយបានថាវិធីអនុវត្តនៅក្នុងករណីនៃការទាមទារឲ្យប្រគល់កូនក្មេង។

ឧទាហរណ៍ ករណីម្ដាយដែលត្រូវបានជ្រើសតាំងជាបុគ្គល ដែលមានអំណាចមេបានៅក្រោយពេលលែងលះធ្វើការទាមទារឲ្យប្រគល់កូន ដែលកំពុងរស់នៅជាមួយនិងឪពុក អាចធ្វើបានតែតាមរយៈវិធានបង្ខំដោយប្រយោលប៉ុណ្ណោះ។ មានមតិដោយឡែក មួយទៀតត្រូវបានត្រូវបានលើកឡើងថាដោយធ្វើការបែងចែកករណីនៅតាមកត្តាថាតើកូននោះមានសមត្ថភាពបង្ហាញឆន្ទៈដែរទេ។

មានន័យថាការទាមទារឲ្យប្រគល់កូនក្មេងដែលពុំមានសមត្ថភាពបង្ហាញឆន្ទៈអាចធ្វើតាមវិធីនៃការអនុវត្តដោយផ្ទាល់ ចំណែកឯការទាមទារវិញឲ្យប្រគល់កូនក្មេងដែលមានសមត្ថភាពបង្ហាញឆន្ទៈ អាចធ្វើបានតាមវិធានបង្ខំដោយប្រយោល ។

### ៣.៦.១.១.ការដាក់ពាក្យសុំ

ការចរចារ ជាវិធីមួយដែលម្ចាស់បំណុល តែងតែចង់អោយកូនបំណុលអនុវត្ត ដោយស្ម័គ្រចិត្ត ជាជាងការអនុវត្តដោយបង្ខំ បើទោះបីជាការចរចារនោះទទួលបានជោគជ័យ ឬជួនកាលត្រូវទទួលរងការបរាជ័យ ដោយហេតុថាកូនបំណុលនៃការអនុវត្តមិនព្រមអនុវត្តដោយស្ម័គ្រចិត្ត តាមការចង់បានរបស់ម្ចាស់បំណុល។ នីតិវិធីចរចារនេះមិនមានបញ្ញាត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទេ តែការអនុវត្តជាក់ស្ដែងម្ចាស់បំណុលនៃការអនុវត្តតែងតែធ្វើការចរចារជាមុនជាមួយកូនបំណុល ព្រោះនេះជាគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ហើយបើគ្មានការអនុវត្តដោយស្ម័គ្រចិត្តទេ ទើបឈានដល់ការអនុវត្តដោយបង្ខំ ។

កិច្ចនេះម្ចាស់បំណុលនៃការអនុវត្តមានកាតព្វកិច្ចស្រាវជ្រាវរកចលនវត្ថុរបស់កូនបំណុលដោយខ្លួនឯង គឺវាមិនមែនជាកាតព្វកិច្ចរបស់អាជ្ញាសាលាទេ។

ពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។ ក្នុងនោះគេបានកំណត់អោយអ្នកដាក់ពាក្យសុំត្រូវសរសេរនូវពាក្យសុំដែលក្នុងនោះត្រូវមានឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគីហើយព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ផងដែរ។ ជាមួយគ្នានេះដែរអ្នកដាក់ពាក្យសុំត្រូវសរសេរចំណុចនេះអោយបានច្បាស់លាស់ និងត្រូវអះអាងនូវភស្តុតាងតាមអង្គហេតុនីមួយៗ ដែលត្រូវបានបញ្ជាក់។

ជាងនេះទៅទៀតអ្នកដាក់ពាក្យសុំត្រូវបញ្ជាក់អំពីខ្លឹមសារនៃ ដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំខ្លួនឯងទាមទារដែលជាគោលការណ៍ កម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នត្រូវកំណត់ឲ្យបានជាក់លាក់ថាតើសុំអោយអនុវត្តទៅលើអ្វីអោយប្រាកដ។ ប៉ុន្តែប្រសិនបើកម្មវត្ថុនោះ គឺជាចលនវត្ថុគឺមិនចាំបាច់កំណត់

ដាក់លាក់អំពីចលនវត្ថុនីមួយៗនោះទេ ព្រោះថាចលនវត្ថុអាចផ្លាស់ទីបានគ្រប់ពេល ដូច្នេះដើម្បីកុំអោយកូនបំណុលដឹងខ្លួនមុនថាម្ចាស់បំណុលរឹបអូសអ្វីខ្លះគួរគម្បីកុំសរសេរបញ្ជាក់អត្តសញ្ញាណចលនវត្ថុនោះអី តែគេត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុនោះអោយបានច្បាស់លាស់ប្រាកដប្រជាហើយពាក្យសុំត្រូវសរសេរបញ្ជាក់នូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារភ្ជាប់ជាមួយផងដែរដែលត្រូវរៀបរាប់អំពីមូលហេតុ និងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ។

អ្នកដាក់ពាក្យសុំ ក៏ត្រូវបរៀបរាប់អំពីភាពចាំបាច់នៃការរក្សាការពារ ដែលខ្លួនទាមទារផងដែរ ព្រោះថាអ្នកដាក់ពាក្យសុំពិតជាមានផលវិបាក ឬ បាត់បង់ផងប្រយោជន៍ណាមួយមិនខានប្រសិនបើ ស្ថាប័នអនុវត្តមិនព្រមចេញដីការក្សាការពារ ហើយចំណុចនេះ ក៏ត្រូវសរសេរឡើងអោយមានលក្ខណៈច្បាស់លាស់ផងដែរ។ ចំពោះគោលបំណងនៃការកំណត់បែបនេះមានន័យថាដើម្បីធានានូវភាពច្បាស់លាស់ និងសុក្រឹត្យភាពនៃការអនុវត្តការរក្សាការពារ។ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តព្រមទាំងភាពចាំបាច់នៃការរក្សាការពារគឺតម្រូវអោយអ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង។ ចំពោះការដាក់ពាក្យសុំនេះគឺត្រូវប្រាកដថាអ្នកដាក់ពាក្យបានបង់ពន្ធនៃការដាក់ពាក្យសុំ ដែលត្រូវបានកំណត់ចំនួន ៥ ០០០ រៀល ។

### ៣.៦.១.២.ការពិនិត្យពាក្យសុំ

ជាគោលការណ៍ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយលិខិតអនុវត្ត ដែលជាលក្ខខណ្ឌគតិយុត្តិតម្រូវ។ បានសេចក្តីថាស្ថាប័នអនុវត្តពុំអាចចាប់ផ្តើមការអនុវត្តដោយពុំមានលិខិតអនុវត្តដែលភ្ជាប់ជាមួយនូវពាក្យសុំអោយអនុវត្តដោយបង្ខំ លើកលែងតែការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុដែលអាជ្ញាសាលាអាចធ្វើការចាប់ផ្តើមអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុបានដោយពុំចាំបាច់មានលិខិតអនុវត្តឡើយពោលគឺគ្រាន់តែម្ចាស់បំណុលនៃការអនុវត្ត ប្រគល់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគមកអោយអាជ្ញាសាលា ឬដាក់លិខិតបញ្ជាក់ថាអ្នកកាន់កាប់ចលនវត្ថុនោះយល់ព្រមប្រគល់អោយ អាជ្ញាសាលាជាការស្រេចតែម្តង។

រីឯការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវធ្វើឡើងដោយលិខិតអនុវត្ត។ លិខិតអនុវត្តទាំងនោះមានដូចជា សាលក្រមឬសាលដីកាបង្គាប់អោយផ្តល់នូវតាវកាលិកដែលបានចូលស្ថាព សាលក្រម ឬសាលដីកាបង្គាប់អោយផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសអោយអនុវត្តជាបណ្តោះអាសន្ន ដីកាសម្រេចបង្គាប់អោយផ្តល់តាវការលិក ប៉ុន្តែចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើដីកាសម្រេចនោះមិនទាន់ចូលស្ថាពវិញមានកម្រិតតែដីកាសម្រេចនោះបានចូលស្ថាពរ។

ដីកាសម្រេចដាសតឿនដែលភ្ជាប់ជាមួយ នឹងការប្រកាសអោយអនុវត្តបណ្តោះអាសន្នហើយជាការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានធ្វើនិងលិខិតយថាភូតដែលធ្វើឡើងដោយសារការី ចំពោះការទាមទារដែល

មានគោលបំណងអោយសងជាប្រាក់មានកំណត់។ ប៉ុន្តែមានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុលនឹងទទួលអនុវត្តដោយបង្ខំភ្លាមៗ ។

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។ ហើយរូបមន្តអនុវត្តជាប្រយោគដែលក្រឡាបញ្ជី ឬសារការីសរសេរភ្ជាប់បន្ថែមនៅ ផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត និងបញ្ជាក់ជាផ្លូវការនូវនត្ថិភាពឬអត្ថិភាពនៃអំណាចបង្ខំអោយអនុវត្តនៃលិខិតអនុវត្តនោះ។

ហេតុផលនៃការការតម្រូវអោយភ្ជាប់បន្ថែមនូវរូបមន្តអនុវត្តទៅនឹងលិខិតអនុវត្ត ដោយសារតែស្ថាប័នអនុវត្ត មិនមែនជាតុលាការនៃបណ្តឹងទេ ហេតុដូច្នេះ ហើយវាមិនមែនជាការសមស្របនោះទេ បើអោយស្ថាប័នអនុវត្តធ្វើការវិនិច្ឆ័យទៅលើអានុភាពនៃលិខិអនុវត្តនៅពេលដែលមានពាក្យសុំអនុវត្តដោយបង្ខំម្តងៗដែលកិច្ចនេះនឹងនាំអោយមានការយឺតយ៉ាវនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ។

នៅក្នុងករណីនៃការអនុវត្តដោយបង្ខំត្រូវធ្វើ ឡើងចំពោះបុគ្គលផ្សេងពីអ្នកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថាជាម្ចាស់បំណុល ឬកូនបំណុលនៃការអនុវត្ត នោះជាការចាំបាច់ត្រូវធ្វើការស្រាវជ្រាវថាតើបុគ្គលនោះជាបុគ្គលដែលត្រូវទទួលឥទ្ធិពល នៃអានុភាពនៃលិខិតអនុវត្តដែរឬទេ តើបុគ្គលនោះមានលក្ខណៈធ្វើជាភាគីនៃការអនុវត្តដោយបង្ខំឬទេ។

ប្រសិនបើបុគ្គលនោះជាបុគ្គលដែលត្រូវទទួលអានុភាពអនុវត្តនៃលិខិតអនុវត្ត នោះត្រូវសរសេរបន្ថែមនៅក្នុងលិខិតអនុវត្ត ដោយ រៀបរាប់ចំណុចនោះក្រោមទម្រង់ជារូបមន្តអនុវត្ត ។

ចំពោះការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតដែលមិនចាំបាច់តម្រូវអោយមានការភ្ជាប់ជាមួយនូវរូបមន្តអនុវត្តដែលមានជាអាទិ៍ សាលក្រមនៃបណ្តឹងរឿងក្តីដែលមានចំនួនប្រាក់តិចដែលចូលស្ថាពរ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនប្រាក់តិចភ្ជាប់ជាមួយនឹងការប្រកាសអោយអនុវត្តជាបណ្តោះអាសន្ន ដីកាសម្រេចដាស់តឿនដែល ភ្ជាប់ជាមួយនូវការប្រកាសអោយអនុវត្តបណ្តោះអាសន្ន ។

ហើយបើសិនបើមានហេតុការណ៍នៃការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តពិសេស ក្នុងនោះរួមមានសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្ត មានភ្ជាប់ជាមួយនូវលក្ខខណ្ឌបង្អង់ សិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្តមានភ្ជាប់ជាមួយនូវពេលកំណត់មិនពិតប្រាកដ និងការយកបុគ្គលផ្សេងក្រៅពីភាគីបានកំណត់ក្នុងលិខិតអនុវត្តធ្វើជាម្ចាស់បំណុលឬកូនបំណុលនៃការអនុវត្ត ជាដើម ។

ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់សោហ៊ុយនៃការអនុវត្តដូចជាពន្ធដាក់ពាក្យសុំដែលស្មើនឹង ចំនួន៥០០០រៀល និងសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ ព្រមទាំងសោហ៊ុយភាគី ដែលត្រូវបង់ជាមុន ។ ការ អនុវត្តបង្ខំដោយផ្អែកលើលិខិតអនុវត្តរបស់ខ្លួនបានឡើយ បើអំឡុងពេល៥ឆ្នាំបានកន្លងផុតទៅបន្ទាប់ពីលិខិត អនុវត្តបានចូលស្ថាពរ។

**៣.៦.១.៣.ការស្នើសុំកម្លាំង**

ការអនុវត្តដោយប្រគល់មានការលំបាកជាងការអនុវត្តផ្សេងៗទៀត ដោយសារការអនុវត្តនេះ តម្រូវអោយ អាជ្ញាសាលាត្រូវទៅធ្វើការរំលាយការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត ហើយធ្វើអោយម្ចាស់បំណុលបាន ទទួលការកាន់កាប់វិញ។ ដើម្បីសម្រេចគោលបំណងនេះ អាជ្ញាសាលាដាច់ខាត់ត្រូវការជាចាំបាច់នូវកំលាំងមាន សមត្ថកិច្ចដើម្បីចូលរួមធ្វើការអនុវត្តនេះ។ទោះបីជាក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានចែងផ្តល់ សិទ្ធិអំណាចអោយអាជ្ញាសាលាក្នុងការប្រើប្រាស់កម្លាំងប៉ូលីសក៏ដោយតែការអនុវត្តជាក់ស្តែង ដើម្បីអោយមាន ការចូលរួមអនុវត្តពីអាជ្ញាធរក៏ដូចជាកងកម្លាំងមានសមត្ថិកច្ចនោះ អាជ្ញាសាលាត្រូវដាក់លិខិតស្នើសុំកំលាំង ជា មុនទៅអាជ្ញាធរនៃទីកន្លែងដែលត្រូវចុះអនុវត្តនោះចំនួន១៥ថ្ងៃមុន បើមិនដូច្នោះទេខាងអាជ្ញាធរមិនមានចូលរួម សហការជាមួយអាជ្ញាសាលាឡើយ។ ហើយបែបបទនៃលិខិតស្នើសុំកំលាំងនេះគឺមានលក្ខណៈខុសគ្នាទៅតាម សាលាដំបូងរាជធានីខេត្តនីមួយៗ និង តាមខេត្តនីមួយៗផងដែរ។

**៣.៦.១.៤.នីតិវិធីប្រគល់ចលនវត្ថុ**

ជានីតិវិធីមួយថ្មីចំពោះស្ថាប័នអនុវត្ត ឬ អ្នកអនុវត្តមុនក្រមនីតិវធីរដ្ឋប្បវេណី២០០៧ គេអនុវត្តតាម អនុលោមការអនុវត្តតាមសាលក្រមព្រហ្មទណ្ឌលុះដល់បច្ចុប្បន្ននេះនីតិវិធីនៃការអនុវត្ត ដោយបង្ខំត្រូវបានបញ្ញត្តិ នៅគន្ថីទី៦នៃក្រមនីតិវិធីរដ្ឋប្បវេណី។ វត្ថុកាន់កាប់ដោយកូនបំណុលក្នុងករណីដែលកូនបំណុលនៃការអនុវត្តជា អ្នកកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុ អាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុនោះ ស្ថិតនៅត្រូវដកយកវត្ថុនោះពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់វត្ថុនោះទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ប្រសិនបើកូនបំណុលនៃការអនុវត្តមិនពេញចិត្តចំពោះការ កំណត់សញ្ញាណនៃវត្ថុ កូនបំណុលនោះ អាចធ្វើការតវ៉ាចំពោះការអនុវត្តបាន ។

វត្ថុកាន់កាប់ដោយតតិយជននៅក្នុងដែលតតិយជនជាអ្នកកាន់កាប់ចលនវត្ថុ ដែលជាកម្មវត្ថុវិញដូច ក្នុងករណីនៃការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលដីកាសម្រេចរបស់

តុលាការអនុវត្ត ដែលបង្គាប់ឲ្យរឹបអូសសិទ្ធិទាមទារឲ្យប្រគល់ដែលកូនបំណុលមានចំពោះតតិយជន ហើយទាមទារឲ្យតតិយជននោះប្រគល់វត្ថុដែលជាកម្មវត្ថុមកឲ្យខ្លួនដោយដោយផ្អែកលើដីកាសម្រេចរឹបអូស[៥៩]។

**៣.៦.១.៥.ការបិទបញ្ចប់ការប្រគល់**

ការបិទបញ្ចប់ការប្រគល់ចលនវត្ថុ ត្រូវបានបញ្ចប់ដោយការធ្វើកំណត់ហេតុប្រគល់របស់អាជ្ញាសាលា ហើយប្រគល់ចលនវត្ថុនោះអោយទៅម្ចាស់បំណុលនៃការអនុវត្ត។

នេះជាគំរូនៃកំណត់ដែលបានអនុវត្តជាក់ស្តែងនៅសាលាដំបូងរាជធានីភ្នំពេញ។

[៥៩] មាត្រា ៤០៣ ក្រមនីតិវិធីនៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា

# សេចក្តីសន្និដ្ឋាន

ប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្នមានការរីកចំរើន និងបាននឹងកំពុងធ្វើការកែទម្រង់ដោយស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសបាននឹងកំពុងយកចិត្តទុកដាក់បំផុតចំពោះការជម្រះក្តី ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះពិតប្រាកដ ។ តាមរយៈនេះគេបានកត់សម្គាល់ឃើញមានស្ថាប័នមួយដែលមានលក្ខណៈឯករាជ្យ និងជាស្ថាប័នអនុវត្តសាលក្រម និងសាលដីការបស់តុលាការ ព្រមទាំងអនុវត្តនូវកិច្ចការនានាក្នុងការជួយសម្រួលដល់ស្ថាប័នតុលាការ ហើយស្ថាប័ននឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួលដល់ការអនុវត្តសាលក្រម ឬសាលដីកា។

បើទោះបីជាតុលាការអនុវត្តមានរូបរាង និងរចនាសម្ព័ន្ធមួយច្បាស់លាស់ក៏ដោយ តែការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺនៅតែត្រូវបានអនុវត្តទៅដោយរលូនដដែល ដែលកិច្ចការនេះត្រូវបានប្រគល់ទៅអោយចៅក្រមអនុវត្តនៃសាលាដំបូងរាជធានីខេត្តជាអ្នកអនុវត្ត។ លើសពីនេះទៅទៀតបើតាមក្រមនីតិវិធីរដ្ឋប្បវេណីថ្មីនេះ បានកំណត់នៅនីតិវិធីមួយជាលាក់សម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។ ដូច្នេះតាមរយៈការសិក្សាស្រាវជ្រាវ បានអោយយើងឃើញថាការអនុវត្តតួនាទីរបស់ចៅក្រម គឺមិនទាន់មានលក្ខណៈច្បាស់លាស់ និងមិនទាន់ត្រឹមត្រូវទាំងស្រុងដូចមានចែងក្នុងច្បាប់នៅឡើយ ។ ពិតណាស់ថាមានការបណ្តុះបណ្តាលចៅក្រមជាបន្តបន្ទាប់ពីមួយជំនាន់ទៅមួយជំនាន់ក្តី តែទោះបីជាយ៉ាងនេះក៏ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនៅតែមើលទៅហាក់បីដូចជាមានភាពផ្ទុយគ្នាពីអ្វីដែលក្រមនីតិវិធីរដ្ឋប្បវេណីថ្មីបានកំណត់។

# អនុសាសន៍

ការអនុវត្តន៍ដោយបង្ខំសិទ្ធិលើបំណុលគឺ ជានីតិវិធីមួយដែលពោពេលទៅដោយភាពចម្រូងចម្រាស និងពេលខ្លះអាចមានការប្រឆាំងតបមកតុលាការអនុវត្តក៏មានដែរ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការអនុវត្ត ដោយបង្ខំចំពោះសិទ្ធិលើបំណុលនោះគឺត្រូវបានធ្វើឡើងដោយស្របច្បាប់ផងដែរ។ ស្របច្បាប់នៅត្រង់ថាការអនុវត្ត គឺត្រូវបានធ្វើតាមការសម្រេចសេចក្តីរបស់ស្ថាប័នតុលាការ និងតាមការស្នើសុំពីម្ចាស់បំណុលនៃការអនុវត្ត ។

ដោយឡែកប្រជាពលរដ្ឋខ្មែរមួយចំនួនធំនៅមិនស្គាល់ច្បាស់ពីការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុល និងស្ថាប័នអនុវត្តដោយបង្ខំនៅឡើយទេ ហេតុនេះហើយបានជារាល់ពេលអនុវត្តដោយបង្ខំម្តងៗកូនបំណុលនៃការអនុវត្ត និងប្រជាពលរដ្ឋបែរជាចោទប្រកាន់ថានេះគឺជាសម្មភាពដែលចេញពីគោលបំណងនៃអាជ្ញាធរសាធារណៈទៅវិញ ។ ពិតណាស់ថាកងម្លាំង និងអាជ្ញាធរសាធារណៈគឺជាអ្នកអនុវត្តដោយបង្ខំ តែមិនមែនមានន័យថា នេះគឺជាឆន្ទៈរបស់អាជ្ញាធរសាធារណៈទេ ។ ផ្ទុយទៅវិញវាគឺជាគោលបំណង និងសិទ្ធិរបស់ម្ចាស់បំណុល ដែលមានសាលក្រម ឬសាលដីការបស់តុលាការអនុវត្តហើយបានដាក់ពាក្យសុំអោយតុលាការអនុវត្ត អោយអនុវត្តនូវសិទ្ធិទាមទារលើទ្រព្យសម្បត្តិនោះមកប្តូរជាប្រាក់។ ដូច្នេះប្រជាពលរដ្ឋខ្មែរ មិនគួរមើលរំលងស្ថាប័នមួយនេះឡើយ ព្រោះវាស្ថាប័នមួយដែលជួយដល់ការអនុវត្តសាលក្រម ឬ សាលដីការបស់តុលការ ។

លើសពីនេះទៅទៀតក្រោយបានសិក្សាលំអិតទៅលើប្រធានបទ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលយ៉ាងស៊ីជម្រៅរួចមក ក្រុមយើងខ្ញុំបានកត់សម្គាល់ឃើញនីតិវិធីនេះមានភាពស្មុគស្មាញហើយពិបាកយល់ទៀតផង។ ភាពមិនច្បាស់លាស់គឺកើតមានឡើងនៅពេលដែលម្ចាស់បំណុលដាក់ពាក្យព្រោះថានៅក្នុងការអនុវត្ត អ្នកដាក់ពាក្យសុំភាគច្រើនសរសេរពាក្យសុំខុស។

ជារួមមកវិញការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ជានីតិវិធីមួយថ្មីសម្រាប់ព្រះរាជាណាចក្រកម្ពុជា ហើយមកដល់ពេលនេះយើងមិនសូវមានសំណុំរឿងនេះច្រើនទេ នៅតាមសាលាដំបូងរាជធានីខេត្ត។

ជាដំណោះស្រាយក្នុងស្ថានភាពជាក់ស្តែង ស្ថាប័នពាក់ព័ន្ធគួរធ្វើការផ្សព្វផ្សាយ និង បណ្តុះបណ្តាលអោយបានកាន់តែទូលំទូលាយអំពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលទាំងមន្ត្រីអនុវត្តច្បាប់ក៏ដូចជាសាធារណជនទូទៅ។

# ពន្យល់ពាក្យគន្លឹះ

- **សិទ្ធិលើបំណុលៈ** ជាសិទ្ធមួយដែលបុគ្គលម្នាក់មានសិទ្ធិទាមទារពីបុគ្គលម្នាក់ទៀតអោយអនុវត្តកាតព្វកិច្ចអ្វីមួយចំពោះខ្លួនឬសិទ្ធិដែលម្ចាស់បំណុលមានលើកូនបំណុល។
- **អាជ្ញាសាលា** ៖ ដោយយោងតាមវចនានុក្រម សម្ដេចជួនណាត ពាក្យអាជ្ញាសាលា គឺសំដៅដល់អ្នកដែលរាជការតាំងអោយមានមុខងារជាអ្នកជំនួយដល់ស្ថាប័នតុលាការ។ តាមន័យច្បាប់ អាជ្ញាសាលាមានន័យពីរយ៉ាង គឺអាជ្ញាសាលាជាស្ថាប័ន និង អាជ្ញាសាលាជាមន្ត្រីអនុវត្ត ។
- **ការអនុវត្តដោយបង្ខំៈ** ការអនុវត្តដោយបង្ខំ គឺជាយន្តការមួយដែលត្រូវបានប្រើប្រាស់កំលាំងដោយបង្ខំពីសំណាក់រដ្ឋដើម្បីសម្រេចសិទ្ធិទាមទារ ឬសិទ្ធិលើបំណុល ដោយផ្អែកលើលិខិតអនុវត្ត តាមរយៈស្ថាប័នអនុវត្ត ។
- **ចៅក្រមអនុវត្តៈ** សំដៅដល់ចៅក្រមដែលទទួលបន្ទុកសំណុំរឿងអនុវត្ត។
- **សិទ្ធិប្រត្យក្សៈ** សំដៅទៅលើសិទ្ធិគ្រប់គ្រង ទៅលើវត្ថុដោយចំពោះដែលអាចអះអាងចំពោះបុគ្គលដ៏ទៃទៀតបាន។
- **សិទ្ធិប្រាតិភោគប្រត្យក្ស** គឺជាសិទ្ធិក្ដាប់ទុកនូវតម្លៃនៃវត្ថុ ដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬតតិយជនដើម្បីធានាសិទ្ធិលើបំណុល។

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣។
- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការរៀបចំអង្គការតុលាការ ។
- ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌។
- ព្រះរាជក្រមលេខ នស/រកម/០៣០៨/០១១ ស្តីពីច្បាប់ស្តីពីនីតិវិធីពិន័យស៊ីវិល។
- ព្រះរាជក្រឹត្យលេខ ០៦ស្តីពីការប្រកាសអោយប្រើច្បាប់ស្តីពីការ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ក្រ ចុះថ្ងៃទី ០៦. ។ ចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចកម្ពុជា ឆ្នាំ ២០០៦។
- សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ស្តីពី ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពាររៀបរៀងដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេក្តីព្រាងក្រមរដ្ឋប្បវេណីកម្ពុជា។
- សេចក្តីព្រាងច្បាប់លើកទី១ ស្តីពីលក្ខន្តិកៈអាជ្ញាសាលា។
- សេចក្តីព្រាងច្បាប់លើកទី២ ស្តីពីលក្ខន្តិកៈអាជ្ញាសាលា។
- សេចក្តីព្រាងច្បាប់លើកទី៣ ស្តីពីលក្ខន្តិកៈអាជ្ញាសាលា។
- សេចក្តីបង្គាប់លេខ ១១៧ សររបស់ក្រសួងយុត្តិធម៌ ស្តីពីការ ខែ មករា ឆ្នាំ ១៩៩៧ ចុះថ្ងៃ ៣១ វ.៩៣. អនុវត្តសាលាក្រម សាលដីកាស្ថាពរ និងសេចក្តីសំរេចផ្សេងៗរបស់តុលាការ។
- ប្រកាសលេខ ៣០ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។
- លិខិតលេខ ១៦៨ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ស្តីពីបែបបទនៃការអនុវត្តដោយបង្ខំ និងការចាត់ចែងលើមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ : ពាក្យសុំអនុវត្តដោយបណ្ដោះអាសន្ន
- ឧបសម្ព័ន្ធទី២ : ពាក្យសុំអនុវត្តសាលក្រម
- ឧបសម្ព័ន្ធទី៣ : ពាក្យសុំឲ្យផ្ដល់រូបមន្តអនុវត្ត
- ឧបសម្ព័ន្ធទី៤ : ពាក្យសុំអនុវត្តរឹបអូសជាបណ្ដោះអាសន្ន

ឧបសម្ព័ន្ធទី១

**ឧបសម្ព័ន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុវត្តដោយបណ្ដោះអាសន្ន

**ម្ចាស់បំណុលអនុវត្តៈ** ឈ្មោះ.................................តំណាងស្របច្បាប់ដោយលោកតួនាទី .................................។.........................................................................................អាសយដ្ឋាននៅភូមិ .....................

**កូនបំណុលអនុវត្តៈ** ឈ្មោះកាន់អត្តសញ្ញាណប័ណ្ណ ...............ភេទ ........................................................................................សញ្ជាតិខ្មែរលេខ.អាសយដ្ឋាននៅភូមិ....................................................................................។

**សូមគោរពចូលមក**

**លោកប្រធានសាលាដំបូងខេត្ត.........................ក្រុង/**

**កម្មវត្ថុ៖** នៃសាលក្រមរដ្ឋប្បវេណី លេខ .....................សុំអនុវត្តបណ្ដោះអាសន្ន ត្រង់សេចក្ដីសម្រេចបញ្ចប់ចំណុចទី លើអចលនវត្ថុដែលជា .................ក្រុង/របស់សាលាដំបូងខេត្ត ........ឆ្នាំ..........ខែ..........ចុះថ្ងៃទី ............. ម៉ែត្រការ៉េ ជាដីលំនៅដ្ឋាន មានទីតាំងស្ថិតនៅភូមិ ....................មានផ្ទៃក្រឡា ....................... ..........................................................................................ដើម្បីឡាយឡុងសងបំណុលមកឲ្យ។......................

**យោង៖** -សាលក្រមរដ្ឋប្បវេណីលេខ............ក្រុង/របស់សាលាដំបូងខេត្ត .......ឆ្នាំ......ខែ......ចុះថ្ងៃទី ........

-រូបមន្តអនុវត្តសាលក្រមលេខ........ចុះថ្ងៃទី ............ខែ...........ឆ្នាំ............

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ............ឆ្នាំ........ខែ........ចុះថ្ងៃទី .................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន លោកប្រធាន មេត្តាជ្រាបថា៖ កាលពីថ្ងៃទី........ខែ........ .........ឆ្នាំ២០ សាលាដំបូងខេត្តបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ លើសំណុំរឿងរដ្ឋប្បវេណី .............ក្រុង/ ......ឆ្នាំ២០.........ខែ........ចុះថ្ងៃទី ...........លេខដោយបានសម្រេចសេចក្ដី តាមសាលក្រមលេខឆ្នាំ........ខែ..........ចុះថ្ងៃទី ............ ........២០របស់សាលាដំបូងខេត្តនៃវិនិច្ឆ័យសេចក្ដីសម្រេចបញ្ចប់ ដែលមានខ្លឹមសារថាៈ .........ត្រង់ចំណុចទី .........ក្រុង/ មានខ្លឹមសាថាៈ បង្គាប់ឲ្យចុងចម្លើយឈ្មោះ........សាលក្រមនេះមានអានុភាពអនុវត្តបណ្ដោះអាសន្នបានត្រង់វិនិច្ឆ័យទី .........................សងប្រាក់ដើមចំនួន .................ឲ្យដើមចោទ។............................

ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលអនុវត្ត ស្របតាមខ្លឹមសារ នៃសាលក្រមរដ្ឋប្បវេណីលេខចុះ .......... ..........ឆ្នាំ២០...........ខែ..........ថ្ងៃទីរបស់សាលាដំបូងខេត្តខ្ញុំបាទស្នើសុំអនុវត្តជាបណ្ដោះអាសន្ន ............ក្រុង/នន្ទូវចំណុចខាងលើដោយអនុវត្តដោយបង្ខំលើអចលនវត្ថុ ដូចបានបញ្ជាក់ក្នុងកម្មវត្ថុខាងលើ ដើម្បីលក់ឡាយឡុងសងបំណុលមកម្ចាស់បំណុលអនុវត្ត។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមលោកប្រធាន មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ ដូចបានបញ្ជាក់ក្នុងកម្មវត្ថុខាងលើដោយក្ដីអនុគ្រោះ។

សូម លោកប្រធាន ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ធ្វើនៅ.......ឆ្នាំ២០.........ខែ.........ថ្ងៃទី .............

**ស្នាមមេដៃស្ដាំ**

ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>ពាក្យសុំអនុវត្តសាលក្រម</u>

នាងខ្ញុំឈ្មោះ ..............................ភេទស្រី អាយុ ............ភូមិ .........ផ្លូវលេខ.........មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ឆ្នាំ......... ................សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ក្នុងករណីប្ដឹងសុំលែងលះមានសំណុំរឿងរដ្ឋប្បវេណី លេខ របស់សាលាដំបូងរាជធានីភ្នំពេញ។............ឆ្នាំ...........ខែ..........ចុះថ្ងៃទី

**<u>សូមគោរពចូលមក</u>**

**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*<u>សូមទានជ្រាប។</u>*

**<u>កម្មវត្ថុ</u>**៖ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ ...............ចុះថ្ងៃទី ..................សុំអនុវត្តសាលក្រមរដ្ឋប្បវេណីលេខៈ ............................ចំណុចទីដល់ចំណុចទីនៃសេចក្ដីសម្រេច។............................

**<u>យោង</u>**៖ -សាលក្រមរដ្ឋប្បវេណីលេខរបស់សាលាដំបូងរាជធានីភ្នំពេញ។...................ចុះថ្ងៃទី ......................

-លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមលេខៈរបស់សាលាដំបូង រាជធានី...............ចុះថ្ងៃទី .................. ភ្នំពេញ។

-រូបមន្តអនុវត្តសាលក្រមលេខរបស់សាលាដំបូងរាជធានីភ្នំពេញ។..............ចុះថ្ងៃទី.........................

តបតាមកម្មវត្ថុ និងយោងខាលើ នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន លោកប្រធាន ជ្រាប់ថាៈ សាលក្រម រដ្ឋប្បវេណីលេខៈរួច..................របស់សាលាដំបូរាជធានីភ្នំពេញបានចូលជាស្ថាពរចាប់តាំងពីថ្ងៃទី ....................ចុះថ្ងៃទី ................. ដែលជាអ្នកមានអំណាច មេបាលើកូនរបស់នាងខ្ញុំទាំងពីរគឺ .........................................ហើយ ប៉ុន្តែត្រូវបានចុងចម្លើយឈ្មោះ ថ្ងៃខែឆ្នាំ ...........ភេទ ...................................និងឈ្មោះ ........................ថ្ងៃខែឆ្នាំកំណើត ...........ភេទ ...................................ឈ្មោះ ពុំបានអនុវត្តអោយនាងខ្ញុំ ដែលជាម្ដាយបានជួប ប្រាស្រ័យទា ........................កំណើតក់ទងកូនទាំងពីររបស់នាងខ្ញុំឡើយ ហើយក៏ពុំដែលបានទទួលដំណឹងអំពីសុខទុក្ខរបស់កូនទាំងពីរដែរ ដោយភាគីចុងចម្លើយមិនបានអនុញ្ញាតតាមសាលក្រម រដ្ឋប្បវេណីលេខ.........................ចុះថ្ងៃទីរបស់សាលាដំបូងរាជធានីភ្នំពេញ.......ត្រង់សេចក្ដីសម្រេចទី...............................កថាខណ្ឌទី....................................................................ដែលបានកំណត់ថា។..................................................................

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូម **លោកប្រធាន** ទទួលនូវការស្នើសុំរបស់នាងខ្ញុំដោយក្ដីអនុគ្រោះ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ធ្វើនៅថ្ងៃទី............ឆ្នាំ...........ខែ..............

**ស្នាមមេដៃស្ដាំ**

ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំឲ្យផ្ដល់រូបមន្តអនុវត្ត**
**សូមគោរពជូន**
**លោក**..................**ចៅក្រមសាលាដំបូង**.................

ម្ចាស់បំណុលនៃការអនុវត្ត:ឈ្មោះតួនាទីជា........តំណាងស្របច្បាប់ដោយលោក.....................
.................

មានអាសយដ្ឋានភូមិ។...................................................................

កូនបំណុលនៃការអនុវត្ត:ឈ្មោះឆ្នាំ សញ្ជាតិខ្មែរ មាន.............អាយុ........ភេទ...........
អាសយដ្ឋាននៅ ភូមិ
..........................................................................................................................................
។.......

សញ្ញាណនៃលិខិតអនុវត្ត: សាលក្រមរដ្ឋប្បវេណីលេខ:.........ឆ្នាំ២០ ......ខែ.....ចុះថ្ងៃទី ........
របស់សាលាដំបូងខេត្ត/ក្រុង។..................

ហេតុការណ៍ និងមូលហេតុនៃការសុំឲ្យផ្ដល់រូបមន្តនៃការអនុវត្តន៍បណ្ដោះអាសន្ន ដោយហេតុ
ថា:យោងសេចក្ដីសម្រេចបញ្ចប់ក្នុងសាលក្រមលេខ......ឆ្នាំ២០.......ខែ......ចុះថ្ងៃទី........របស់សាលាដំបូង
ខេត្តនៃសេចក្ដីសម្រេចបានចែងថា......ត្រង់ចំណុចទី.......ក្រុង/:សាលក្រមនេះមានអានុភាពអនុវត្តជាបណ្ដោះ
អាសន្នត្រង់ចំណុចទីនៃសេចក្ដី......

សម្រេចបញ្ចប់។

អាស្រ័យដូចបានសម្រាបជូនខាងលើ សូម**លោកចៅក្រម** មេត្តាពិនិត្យ និងសម្រេចតាម
នីតិវិធីដោយក្ដីអនុគ្រោះ។

សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ធ្វើនៅ........ឆ្នាំ២០.........ខែ.........ថ្ងៃទី..............

**ស្នាមមេដៃស្ដាំ**

**ឈ្មោះ**

ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្ន**

**ម្ចាស់បំណុល**

ឈ្មោះ ៖

អាសយដ្ឋានផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ។...........ខេត្ត..........ស្រុក........ឃុំ......

**អ្នកតំណាងដោយអាណត្តិ**

ឈ្មោះ៖លោក លោកស្រី ៖/

អាសយដ្ឋានការិយាល័យ ៖..............................

ឈ្មោះការិយាល័យមេធាវី..............................ក្រុមហ៊ុនមេធាវី ៖/ក្រុមមេធាវី/

**កូនបំណុល**

ឈ្មោះ ៖

អាសយដ្ឋានផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ។...........ខេត្ត..........ស្រុក........ឃុំ......

សេចក្តីដូចមានកំណត់សូម**ឯកឧត្តម លោកជំនាញប្រធាន**/សម្រេចតាមការស្នើរសុំដោយក្តីអនុគ្រោះ។

សូម**ឯកឧត្តម លោកជំនាញប្រធាន**/ទទួលនូវសេចក្តីគោរពគោលដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ធ្វើនៅ........ឆ្នាំ២០.........ខែ.........ថ្ងៃទី..............

**អ្នកតំណាងដោយអាណត្តិ**